# ទំនៀមទំលាប់

## និង

# ពិធីបុណ្យផ្សេងៗ

## របស់ជនជាតិខ្មែរ



រក្សាសិទ្ធ

MARYKNOLL
Date......2004.......
306.69596
ទំន
ក្ប.២

# ទំនៀមទំលាប់

00011668
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

និង

# ពិធីបុណ្យផ្សេងៗ

## របស់ជនជាតិខ្មែរ

C 2000

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១_ | អារម្ភកថា | |
| ២_ | ទំនៀមទំលាប់សង់ផ្ទះ និងឡើងផ្ទះថ្មីបែបខ្មែរ | ១ |
| ៣_ | របៀបអារក្ខក្នុងវេលាមានជំងឺ | ៩ |
| ៤_ | ពិធីឡើងអ្នកតាក្នុងខែពិសាខជាដើម | ១៧ |
| ៥_ | ក្បួនហៅព្រលឹង | ២៦ |
| ៦_ | ពិធីលើករាសី | ៣៦ |
| ៧_ | ទំនៀមសូត្រមន្តរំដោះគ្រោះ | ៣៧ |
| ៨_ | ពិធីពលិការព្រះពិស្ណុការជាគ្រូដើមខាងវិជ្ជាជាង | ៣៩ |
| ៩_ | ព្រះរាជពិធីគជេន្ទ្រាសុពាស្នាន | ៤៣ |
| ១០_ | ព្រះរាជពិធីពិភទ្ធសច្ចាតីផឹកទឹកសម្បថលាងអាវុធ | ៤៨ |
| ១១_ | បទពំនោលអំពីឧត្បាទចង្រៃ | ៥៣ |
| ១២_ | សេចក្តីអធិប្បាយអំពីឧត្បាទ | ៦៨ |
| ១៣_ | ពាក្យសូត្របូជា | ៧៣ |
| ១៤_ | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | ៧៧ |
| ១៥_ | កំណត់ហេតុ | ៨៥ |
| ១៦_ | អត្ថបទសែនក្រុងពាលី | ៨៧ |


MARYKNOLL
00011668

# អារម្ភកថា

មានសេចក្ដីបញ្ជាក់ពីទស្សនៈវិទូម្នាក់ថាៈ ក្នុងលោកនេះគ្មានអ្វីរមតៈទេសូម្បីតែ « អារ្យធម៌ ទាំងឡាយដែលមានជីវិតរស់រវៀនកកើតឡើងក៏រលត់សាបសូន្យទៅវិញដែរ ( lescivilisations sont mortelles)។

ប្រសិនបើយើងលើកគំនិតនេះ យកមកភ្ជាប់នឹងបញ្ហាទាក់ទងនូវសង្គមខ្មែរ យើងអាចសន្និដ្ឋានថាទស្សនៈនេះប្រាកដត្រឹមត្រូវមែន ។

ការពិតគឺតាំងពីសម័យអាណានិគមបារាំង « ឆ្នាំ១៨៦៣»រហូតដល់បច្ចុប្បន្នកាលនោះ សង្គមខ្មែរ បានទទួលនូវការវិវឌ្ឍន៍គ្រប់វិស័យទាំងអស់ ។ការផ្លាស់ប្ដូរនេះ សអោយឃើញថា លក្ខណៈនៃវប្បធម៌អារ្យធម៌ខ្មែរក៏ដូចវប្បធម៌-អារ្យធម៌នៃប្រទេសនានាក្នុងសកលលោកដែរមានដំណើរប្រែប្រួលពីភាពមួយទៅភាពមួយជានិច្ច ។

ទ្រឹស្ដីរបស់អ្នកនិពន្ធខាងលើនេះ ធ្វើអោយយើងមានគំហើញមួយថាថ្វីត្បិត តែទំព័រប្រវត្តិសាស្ត្រខ្មែរ បានផ្លាស់ប្ដូរទ្រង់ទ្រាយយ៉ាងណាក៏ដោយ ពីសម័យមុនក្លឹងចូលស្រុក ពោលគឺសម័យបុរេប្រវត្តិរហូតដល់សម័យប្រវត្តិសាស្ត្រដែលបានចាប់ ផ្ដើមឡើងនៅដើមសតវត្សទី ១ ក្រោមឥទ្ធិពលនៃវប្បធម៌ក្លឹង ហើយពីសម័យនោះមកដល់សព្វថ្ងៃនេះ ដែលខ្មែរទទួលអានុភាពវប្បធម៌របស់ពួកអឺរ៉ុប លក្ខណៈនៃប្រភពវប្បធម៌ដើមរបស់ខ្មែរ ក៏ពុំទាន់រលត់សាកសូន្យដែរ ដោយ ហេតុថាវប្បធម៌ខ្មែរ បច្ចុប្បន្ននេះជាការរួមសង្ខាសរវាងវប្បធម៌ខ្មែរ-មន និង វប្បធម៌បរទេសជាពិសេសវប្បធម៌ឥណ្ឌា-ចិននិងអឺរ៉ុប ជាដើម ។ ជាឧទាហរណ៍ការនិយមពុទ្ធសាសនាពីសំណាក់ជនជាតិខ្មែរក៏មិនអាចលុបបំបាត់ស្នាមនៃជំនឿលើទេវតានៃព្រហ្មញ្ញសាសនាឬក៏ជំនឿជូនតាខ្មែរ-មន ដែលមានអាយុច្រើនពាន់ម៉ឺនឆ្នាំមុនសម័យប្រវត្តិសាស្ត្រ ។ លើសពីនេះ

លើសពីនេះទៀត ទេពកោសល្យរបស់ជនជាតិខ្មែរ គឺការចេះក្រឡៃអ្វីដែលខ្ចីពីបរទេស អោយស្របតាមមនោសញ្ចេតនារបស់ខ្លួន ឬ លក្ខណៈវប្បធម៌ប្រចាំជាតិ ។ ពោលគឺខ្មែរគ្រាន់តែខ្ចីពីបរទេស ដែលខ្លួនត្រូវការតែប៉ុណ្ណោះ ពិសេសគឺអ្វីៗដែលអាច នាំមកចំពោះខ្លួននូវផលប្រយោជន៍ ។

ម៉្យាងទៀត ការសិក្សាឈ្មោះទេវតាក្នុងក្បួនជិះឧត្បាត ឬក្បួនព្រះរាជពិធីភទសច្ចារអាចបង្ហាញអោយយើងដឹងដែរថា ប្រពៃណីទាំងពីរនេះជាសំណល់នៃវប្ប ធម៌សម័យមុនអង្គរ និងអង្គរ ។ ក្នុងសម័យនេះហើយ ការទ្រទ្រង់ថែរក្សាវប្បធម៌- អារ្យធម៌ខ្មែរជាការចាំបាច់បំផុតប្រឈមមុន និង ការវិវឌ្ឍន៍មិនឈប់ឈរនាសម័យនេះ ។

ម៉្យាងទៀតអ្នកមានគំនិតផ្នែកស្រាវជ្រាវណា ក៏ដូចជាមួយណាសុទ្ធសឹងជា មានគោលគំនិតចំបងតែមួយខាងលើនេះដែរ ។ ឧត្តមគតិនេះហើយដែលធ្វើអោយ យើងពុះពារឧបសគ្គគ្រប់ប្រភេទ ខិតខំប្រមែលប្រមូលកំណត់ហេតុនានា ដែលបានចងក្រងឡើងដោយក្រុមជំនុំទំនៀមទំលាប់ខ្មែរនាឆ្នាំ១៩៣៣ ហើយយកមកបោះពុម្ពជាសៀវភៅ ដើម្បីបន្សល់ទុកជាកេរ្តិ៍ ដល់កុលបុត្រកុលធីតាជំនាន់ក្រោយគ្រប់មជ្ឈដ្ឋាន ។ ក្នុងសម័យនេះហើយកូនឯកសារនេះដែល អ្នកកំពុងអាចទាំងអស់គ្នា ជាកំរងអត្ថបទនានាស្តីពីលក្ខណៈផ្សំនៃវប្បធម៌ខ្មែរ-ឥណ្ឌា ដែលជាមូលដ្ឋាននៃខេមរជាតិ។ទន្ទឹមគ្នានេះ ដើម្បីជាគំនិតចំពោះមិត្តអ្នកអានយើងគ្រាន់តែបន្ថែមពតិមានខ្លះនូវទំព័រចុងក្រោយបង្អស់ នៃកូនឯកសារតូចនេះ ដោយគ្មានកែប្រែអ្វី ទាំងអស់ដែលស្ថិតនៅក្នុងសំណៅដើម ។

ជាអវសាន្ត យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរដល់នាយកមជ្ឈមណ្ឌលស្រាវជ្រាវផងដែល-វប្បធម៌-អារ្យធម៌ខ្មែរនូវទីក្រុងប៉ារីសដែលបានផ្តល់អត្ថបទនានាជូនខ្ញុំ ដើម្បីបំពេញគេគោលបំណងពីមិត្តអ្នកអានជាទីមេត្រកទាំងឡាយ ។

# ធំនៀមទំលាប់សង់ផ្ទះនិងឡើងផ្ទះថ្មី បែបខ្មែរ

កាលនឹងសង់ផ្ទះថ្មីត្រូវរោយរើសគ្រឿង ដែលមានលក្ខណៈមិនល្អតាមដែលបុរាណាចារ្យធ្លាប់កាន់មកដូច្នេះ

ប្រការ១ _ រើសលក្ខណៈសសរគឺ « ក » ឈើសសរ ដែលកាប់រំលំទៅបាក់ដកទាំងបណ្តូលបកផងហៅថា ដកសណ្តូត ។ « ខ »សសរដែលមានថ្នាំង ឬ ភ្នែកនៅគល់ កាលយកទៅសង់កប់លប់ទៅនៅឃើញថ្នាំង ឬ ភ្នែកនោះនៅក្បែរដី ហៅថាមាន់កកាយ « គ » សសរដែលមានថ្នាំងឬភ្នែកនៅគល់ខ្ពស់ពីដីឡើងប្រមាណ១ហត្ថហៅថា ជ្រូកដុស។«ឃ»សសរដែលថ្នាំង ដម្រង់ទៅហើយធ្លាយបណ្តូលត្រង់កន្លែងឯណានីមួយហៅថា ធ្លាយបណ្តូល ។

« ង » សសរដែលថ្នាំងឈ្លួសទៅឃើញសំបកកប់នៅក្នុងសាច់ឈើហៅថា ពាំសំបក ។

សសរដែលមានលក្ខណៈដូច្នេះ ជារបស់ចង្រៃរោយទោសដល់ម្ចាស់ផ្ទះលោកក៏ហាមមិនរោយយកធ្វើផ្ទះ ។

គ្រឿងឈើក្រៅអំពីនេះ មិនមានរើសទេ រោយតែល្មមប្រើការបានក៏បានហើយ ។

ប្រការ២ៈ _ មើលថ្ងៃខែ ដែលនឹងសង់ផ្ទះថ្មី ។ កាលរកគ្រឿងផ្ទះយកមកតែងឈ្លួសសិទ្ធិបានសព្វគ្រប់ហើយត្រូវមើលថ្ងៃខែ ដែលនឹងសង់ដូចមានសេចក្តីដែលបុរាណាចារ្យលោកចងទុកជាពាក្យកាព្យតទៅនេះ ៖

- នេះនៅស្រដីទោះសង់គ្រឹះថ្មីអោយមើលពារពេលលក្ខណ៍ - ឬក្ស ផ្សំកុំសង់លើហិន មធ្យម អោយឧត្តមមធ្យម នាកនិតតំនោលនៃសាស្ត្រាព្រឹទ្ធាចារ្យពិនិត្យទាយទុកជាច្បាប់ កំលុង ទ្វាទសមាស ស្រេចស្រាប់ដោយច្បាប់តំនោល នៃសាស្ត្រនោះហោង ។

-ខែចេត្រសង់គ្រឹះពុំជាសែនសោយសោកាណលប់ពន់ពេកក្រៃ ។កើតក្តី អប្រិយ៍ចង្រៃក្តៅ ចិត្តពេកក្រៃ ក្សិណក្ស័យព្រាយព្រាត់គ្នាគ្មី ។

- ខែពិសាខសង់គ្រឹះប្រពៃ ច្រើនក្រៃមាសប្រាក់ទាំងឡាយ ។

-ខែជេស្ឋសង់គ្រឹះអន្តរាយ មាសប្រាក់ខ្ចាត់ខ្ចាយ អាត្មាក្សិណក្ស័យ

-ខែអាសាធសង់គ្រឹះឥតជ័យ ទ្រព្យធនក្សិណក្ស័យ ហោចហិនវិនាស ។

-ខែស្រាពណ៍សង់គ្រឹះអំនោយផាបានមាសប្រាក់កែងកងមានលាភមានជ័យ ដ៏កន្លងមាន សម្បត្តិទ្រព្យផង ឥតឯគណនា ។

-ខែភទ្របទសង់គ្រឹះពុំផា ព្យាធិបិន្ថាច្រើនចម្កាត់ក្រៃ ។

-ខែអស្សុជសង់គ្រឹះឥតជ័យ ច្រើនជល្លោះក្រៃក្តៅចិត្តពុំជា ។

-ខែកក្តិកសង់គ្រឹះបាសឹង មហាសួស្តិ៍ចូលទ្រព្យធនធាន ។

-ខែមិគសិរសង់គ្រឹះជាស្ថាន សួស្តិ៍កល្យាណ យសស័ក្តិសម្បត្តិ ។

-ខែបុស្សសង់គ្រឹះជៀងជាតិ ចូលកេរកងរ័តន៍មាសប្រាក់សព្វគ្រប់

-ខែមាឃសង់គ្រឹះពុំជា កាចចង្រៃមោះហិមា ក្រែងភ្លើងនូវឆេះសូន្យសោះ។

-ខែផល្គុនសង់គ្រឹះឥតមោះមាន លាភចំពោះដូចចិត្តចិន្តា ។

## មើលធិសនាគ

សិទ្ធិការ្យនេះនូវស្រដីទិសសំដៅនាគខែផល្គុន ចៃត្រ ពិសាខ នាគបែរត្បូងទៅទិសបស្ចិម កន្ទុយទៅទិសបូព៌ផ្ទៃ ទៅទិសឧត្តរ ខ្នងទៅទិសទក្សិណ ពិសទៅទិសពាយ័ព្យ កាលនឹងផ្ទះអោយរង្គុយ ជិតរណ្តៅប្រែមុខទៅទិសបូព៌បាដីទៅទិសឧត្តរជ្រែងសសរទៅទិសពាយ័ព្យ ហើយលើកសសរជ្រុងពាយ័ព្យ ជាដំបូងកុំបីលើក សសរឯទៀតមុនឡើង ។

-ខែជេស្ឋ -អាសាធ- ស្រាពណ៍ នាគបែរត្បូងទៅទិសឧត្តរ កន្ទុយទៅទិស ទក្សិណផ្ទៃទៅទិសបូព៌ខ្នងទៅទិសបស្ចិម ពិសទៅទិសឥព្សាន កាលនឹងជីករណ្តៅ អោយបែមុខទៅទិសទក្សិណជ្រែងចុងសសរទៅទិសព្សានហើយលើកសសរជ្រុងព្សានជាដំបូង ។

-អស្សុជ-កត្តិក នាគបែរត្បូងទៅទិសបូព៌ កន្ទុយទៅទិសបស្ចិម ផ្ទៃទៅទិស ទក្សិណខ្នងទៅទិសឧត្តរ ពិសទៅទិសអាគ្នេយ៍ កាលនឹងជីករណ្តៅអោយវែងទៅទិសបស្ចិម បាដីទៅទិសទក្សិណជ្រែងចុងសសរទៅទិសបូព៌ ហើយលើកសសរជ្រុងអាគ្នេយ៍ជាដំបូង ។

ខែមិគសិរ-បុស្ស-មាឃនាគបែរត្បូងទៅទិសទក្សិណ កន្ទុយទៅទិសឧត្តរផ្ទៃទៅទិសបស្ចិម ខ្នងទៅទិសបូព៌ពិសទៅទិសនិរតីកាលនឹងជីករណ្តៅអោយបែរមុខទៅទិសឧត្តរ បាដីទៅទិសបស្ចិម ជ្រែងចុងសសរទៅទិសនិរតី ហើយលើកសសរជ្រុង និង ដីជាដំបូងហោង ។

ឯបើអ្នកឯណាបានធ្វើផ្ទះតាមក្បួនបង្គាប់ដូច្នេះ នឹង កើតសេរីសួស្តីមានទ្រព្យ ខ្ញុំកំដរ គោ ក្របី ដំរី សេះ នឹង មានជ័យជំនះឈ្នះអស់ចង្រៃឧបទ្រពទាំងឡាយហោង ។

## ប្រការ ៣ : **ប្រុងផ្ទះនឹងសែនក្រុងពាលី**

កាលបើថ្ងៃខែបានហើយ អោយរៀបក្រុងផ្ទះ គឺអោយយកសសរកន្លោង ទាំង៣ ដើមឬទាំងប៉ុន្មាន ដើមទៅដាក់ផ្តេកនៅកណ្តាលទីដែលនឹងសង់ផ្ទះយកឈើដើងរមាំង « ឈើកល់»ទល់កល់ក្បាលសសរទាំងនោះ អោយខ្ពស់បន្តិចឡើង ហើយរៀបសែនក្រុងពាលី

វណ្ណាប់សែន គឺជម៤ថ្លែម « ខ្លះហៅថាក្លែម» ៤បង្អែម១ថាស ចំអាប១ ថាសទឹកអប់១ គូស្លាបារី១គូ«ពីរជើងពាន » សំពត់អាវព្រៃថ្មី១មួយប្រដាប់ ។ គ្រឿងសំអាងមានកញ្ចក់ក្រាស់ជាដើម ១ប្រដាប់ ទឹក១ផ្តិល ។ អោយធ្វើព្វែត១ទំហំ១ហត្ថ១ទះ «គឺ១ហត្ថនឹង៥ធ្នាប់៤ជ្រុងស្មើ ហើយធ្វើជាពៃមូល១តូចដាក់ត្រង់កណ្តាលពៃធំនោះ ជាសម្រាប់ក្រុងពាលីធ្វើពៃច្រមុះជ្រូក « គឺពៃ៣ជ្រុង»៤ដាក់ត្រង់ជ្រុងទាំង៤នៃពៃធំជាសម្រាប់ព្រះភូមិនឹងនាងធរណី ។ «តែអ្នកខ្លះថាអោយធ្វើត្បែត១ទំហំដូចខាងលើនឹងធ្វើពៃច្រមុះជ្រូក១ទំហំ១ហត្ថផ្សេងពីគ្នា « អោយរៀបដាក់បាយសបាយ ក្រហមនឹងញាំភ្លា ក្នុងពៃរំបាលនោះ ហើយរៀបដាក់ទៅទី១ដ៏សមគួរបើកឆ័ត្រ ឬក្លស់ បាំងពីលើ»។នឹងមានភ្លេង១វង់នៅប្រចាំលេងថ្វាយក្រុងពាលី ។

« ព្រះនារាយណ៍បែកភាគ១០ដង » ។

លំដាប់នោះអាចារ្យថហាយបង្គំ៣ដងផ្តើមសូត្រអញ្ជើញទេវតាមកស្ថិតនៅក្នុងខ្លួនដើម្បីធ្វើការអោយជាមង្គល កុំអោយមានមោះថ្លោះការថា «សិរោមេពុទ្ធទេវ ញ្ចលលាតេព្រហ្មទេវតា បរមេស្វរហត្ថយំនារាយណញ្ចពិស្ណុការ » អោយសូត្រ៣ដងចប់ច្រួចទឹកម្តង ។

រួចអោយសូត្រតទៅទៀតថា « ឧមរាពាធិតេជោវិនរក្ខេសសរសសវេរិភោសនស្មិគហណំលលាតេព្រហ្មទេវតា បរមេស្វរហត្ថយំនរាយកញ្ចេវហត្ថិច្ចរូបេនពិស្ណុការទេវករាហិកាការោសព្វការសព្វកិច្ចាសព្វកម្មាព្រះមង្គលាឧមនមោពុទ្ធ័ស្ស៍ នមោ ធម្ម័ស្ស៍ នមោ សង្ឃ័ស្ស៍ អាគច្ឆន្តុបរិភុញ្ជន្តុ ស្វាយ៤ ។ អោយច្រួចទឹកម្តង ។ សូត្រអញ្ជើញព្រះភូមិ«ទេវតាដែលរក្សាផែនដី» ថា «ឧមព្រះភូមិរាជទេពា ឧមព្រះភូមិលក្ខណ - ឧមព្រះភូមិរាជា ឯហិពុរអាគច្ឆន្តុភុញ្ជន្តុតេសំបូជានុភាវេនសព្វទុក្ខសព្វសោកសព្វរោគសព្វភ័យសព្វឧបទ្ទវចង្រៃវិនាសសាយសព្វលាភំភវន្តុតេ ។

ច្រូចទឹកម្តងសូត្រសែនថ្វាយក្រយាបូជាថា « ឧម បទុមត្តរោចបូរពាយំ អត្តនិយេច ទេវតា ទក្ខិណោ កស្សបោ ពុទ្ធោទើបអញ្ជូខ្ញុំអញ្ជើញក្រុងពាលី ព្រះភូមិ នឹងនាងគង្ហីង ព្រះធរណី ចូលអ្នកអញ្ជើញមកយកក្រយាបូជាសារពើទៀនធូបផ្កាលាបុប្ផាគន្ធវិលេបនៈ ស្លាម្លូស្រូវអង្ករ ចេករំពៅត្រាវដំឡូងល្ហុសណ្តែកទាំងឡាយ យើងខ្ញុំរៀបបូជាថ្វាយអ្នកហោង ។ ត្បិតយើង ធ្វើបុណ្យសង់ផ្ទះគេហដ្ឋាន៥នេះក៏សូមអោយបានសេចក្តីសុខសេចក្តីចំរើនជានាប់ឆុតដូចសេចក្តី ប្រាថ្នាហោង » ។

អោយជីករណ្តៅខាងត្បូងកន្លែងដែលសង់ផ្ទះចម្ងាយពីជើងសសរប្រមាណ១ហត្ថ ទំហំ រណ្តៅល្មមចុះពែជីរៅ១ចំអាម លើកពែដាក់ក្នុងរណ្តៅនោះបើខាងខ្មៅ អោយផ្ងាពែបើខាង រនោចអោយផ្កាប់ពែច្រូចទឹក ហើយសូត្រថា«ឧមព្រះពិស្ណុការព្រះភូមិព្រះធរណីដ៏មានឫទ្ធិចេស្តា នាមនាងអស្សមុខា តែងតែរក្សាព្រះធរណីផ្ទៃក្រោមនេះណានាងមានវេប្រវាប់សិទ្ធិសក្តិឫទ្ធក្លា បានជ័យចេស្តានាមក្រុងពាលីទ្រើសទ្រង់អំណាចប្រសើរឯង អាចមែនមានឫទ្ធិសូមអោយទទួល ភោជនផ្កាភ្ញីទទួលវន្ទីយើងខ្ញុំនេះណា សូមសុខសួស្តីសូមជ័យរក្សាសូមមគ្គផលាបានដូចបំណង សូមឈ្នះទុក្ខសោកសូមឈ្នះទាំងរោគសូមឈ្នះភ័យផង

សុខហើយឬ ? អ្នកទាំងពួងឆ្លើយថាសុខហើយ ។

សូមឈ្នះចង្រៃអោយបាត់ហ្មត់ហ្មងប្រសើរកន្លងដូចខ្ញុំប្រាថ្នា។ចប់ប៉ុណ្ណោះហើយអាចារ្យធ្វើឧបកិច្ចសួរថា ៖ កើតសម្បត្តិហើយឬ ? ឆ្លើយថាកើតសម្បត្តិហើយ បានកុសលផលបុណ្យ ហើយ ។

បានអ្វីជាបន្ទាល់ ? ឆ្លើយថាយកបោ៊ាជាបន្ទាល់ ។

ដល់មកត្រង់នេះអោយអ្នកទាំងពួងស្រែកហ៊ោ ព្រមគ្នាផុតសំឡេងហ៊ោរហើយអ្នកភ្លេងលេងភ្លេងពាបទ ជាស្វរេចពិធីសែនក្រុងពាលី ។

១- ពាក្យនេះចំឡងមកច្រើនតហើយគង់ជាខុសឃ្លៀងឃ្លាតច្រើន

២-បើធ្វើការក្រៅអំពីសង់ផ្ទះមានមង្គលការជាដើមអោយថា ចេញឈ្មោះការនោះ ។

បូជាក្រុងពាលីហើយគេនាំគ្នាលើកសសរផ្ទះនោះឡើងធ្វើតទៅដរាបដល់ហើយ ។

ផ្ទះដែលធ្វើថ្មីនោះមុន ដែលនឹងឡើងនៅហាមផ្តាច់មិនអោយមនុស្សស្រីឡើងគេថាចង្រៃអ្នកខ្លះហាមទាំងលោកសង្ឃផងមិនអោយឡើង ។

## ប្រការ ៤ : **ពិធីឡើងផ្ទះ**

កាលធ្វើផ្ទះរួចហើយគេរកវេលាឡើងផ្ទះថ្មី លុះរកបានហើយត្រូវរៀបប្រដាប់គ្រឿងឡើងផ្ទះតាមទំនៀមគឺបង្អែម១ថាស ចំរាប១ថាស ស្រូវគង់១ការ៉ុង បន្លែ,ផ្លែឈើ ។ ប្រដាប់ធ្វើសំពត់គ្រប់ធ្មេញឈើ ។ ប្រដាប់ធ្វើស្រែចំការ « កាបិត កណ្តៀវ , ញើ,ល្អី ។ ប្រដាប់ស្លៀកពាក់= ហិបដាក់សំពត់ - មួក-ឆ័ត្រ ។ គ្រឿងមាស ប្រាក់ ។ គ្រឿងស្អាងខ្លួន-ប្រេងម្សៅ, កញ្ចក់ក្រាស់,កន្ត្រៃកាំបិតកោរ ។ គ្រឿងដំណេក កន្ទេល ពូក ខ្នើយ មុង នឹងស្លាបារី ប្រអប់ស្លាបាយប្រលឹង ថ្នបស់ថ្នាំគឺ «ថ្នកិនថ្នាំ « ក្អមទឹកសរិទ្ធបើគ្មានអោយយកផ្តិល សំរឹទ្ធ ឬ ផ្តិលលុងហិនបំជួស១កុយ ភ្លុក,សង្ខ ,ផ្លែដូងទុំ បិទមាស១ផ្លែ ត្រឡាចបិទមាស១ ឆ្នាញ់សំបុរបី១គ្រឿង សារពើយុទ្ធ « គ្រឿងចំបាំង » ។ល។ របស់អំបាលនេះអោយរៀបនៅមុខទីផ្ទះថ្មី ។ អាចារ្យអ្នកនាំឡើងផ្ទះត្រូវរើសរកស្រី២នាក់មកសន្មតិអោយឈ្មោះជាថ្មីថា នាងស្រី «ដើម្បីសិរី១នាងរ័តន៍ដើម្បីអោយកើតសេចក្តីត្រេកអរ១នាងសួស្តី«ដើម្បីអោយកើត « សេចក្តីសួស្តី១

នាងកែវ ដើម្បីអោយកើតមាសប្រាក់ កែវកង១ នាងគង់ «ដើម្បីអោយគង់ជីវិតនឹងគង់ទ្រព្យសម្បត្តិ,១ នាងជ័យ « ដើម្បីអោយកើតជ័យជោគមង្គល ១ ។ ហើយរើសរបស់សំខាន់ៗអោយស្រីអំពូលនេះកាន់ហែរឡើងផ្ទះ គឺនាងស្រីកាន់ក្អមឬផ្តិលទឹកនាងរ័តន៍អោយកាន់គ្រឿងស្លានាងសួស្តីអោយកាន់សំពត់អាវនាងគង់ អោយកាន់ពូកកន្ទេល នាងកែវអោយកាន់មាសប្រាក់កែវកងនាងជ័យអោយ កាន់គ្រឿងភ្ញុកកុយ ។

ពួកអ្នកក្រៅពីនេះអោយកាន់ទ្រព្យរបស់ផ្សេង ៗ ដូចពោលខាងលើដើរដង្ហែអ្នកម្ចាស់ផ្ទះជុំវិញផ្ទះ៣ជុំឯអ្នកម្ចាស់ផ្ទះមានគេបាំងឆ័ត្រអោយផង ។ វេលានោះមនុស្សចាស់ខ្លះប្រមាណ២,៣នាក់ត្រូវឡើងទៅលើផ្ទះមុនកាលពួកអ្នកដង្ហែបាន៣ជុំហើយ អ្នកនៅលើផ្ទះ«ធ្វើជាស្រែកសួរមកថាអ្នកណាមកពីណាគ្នាច្រើនម្ល៉េះ » ។ អ្នកឆ្លើយថា«លើងមកពីឆ្ងាយនាំគ្រឿងឧបភោគបរិភោគមានមាសពេជ្រកែវកងជាដើម ជាច្រើនណាស់ណាមករកទីលំនៅនៅដោយឮថានៅទីនៅទីនេះមានផ្ទះ១ទំនេរយើងចង់មកនៅផ្ទះនេះ តើជាល្អមយើងនៅបានសេចក្តីសុខសប្បាយឬទេៈអ្នកនៅលើផ្ទះឆ្លើយតបថា « អើបើដូច្នោះអញ្ជើញមកនៅចុះផ្ទះនេះអ្នកណាបាននៅហើយអ្នកនោះបានសេចក្តីសុខសប្បាយចំរើនទ្រព្យសម្បត្តិបរិបូណ៍គ្រប់ប្រការហោង។លំដាប់នោះអ្នកហែរនាំគ្នាឡើងលើផ្ទះ ។

## ប្រការ ៥ : **រៀបសែនចងដៃម្ចាស់ផ្ទះ**

កាលឡើងមកលើផ្ទះគ្រប់គ្នាហើយ ត្រូវរៀបសែនរំលឹកដល់ជីដូនជីតាដែលចាកឋានទៅហើយនឹងព្រះភូមិដែលជាម្ចាស់ទឹកដីសូមអញ្ជើញមកសេពសោយគ្រឿងក្រយាបូជាហើយ

ចូរអោយសព្វសាធុការពរដល់កូនចៅដែលមកនៅក្នុងទីនេះអោយបានសេចក្ដីសុខសប្បាយ ។ល។ ស្រេចហើយអាចារ្យយកអំបោះសជ្រលក់ក្នុងប្រេងម្សៅក្រអូប យកចងដៃអោយ ប្ដីប្រពន្ធម្ចាស់ផ្ទះអោយពរជ័យអោយបានសេចក្ដីសុខសប្បាយ នឹង សេចក្ដីចំរើនធនធានគ្រប់ប្រការ ។ ជូនកាលគេបង្វិលពពិលផង ។ ឯរបស់ដែលជាល័ក្ខដែលនាំមកឡើងផ្ទះថ្មីអោយទុកចង្ក្រាននៅទិសបូពិទាំងឃ្លូវ អោយទុកទិសអាគ្នេយ៍ អង្ករ ថ្នាំ អោយទុកទិសទក្សិណស័ង្ខអោយទុកទិសនិរតី « ហរតី»កាំបិតព្រា ថ្ម អោយទុកទិសបស្ចិម ភ្លុក ដែក អោយ ទុកទិសពាយ័ព្យ ស្រូវគង់ទុកទិសឧត្តរឆ្នា ទែន កែវ « ឬស្រីមានគិភបើមាន » អោយទុកទិសឦសាន ពួកកន្ទេលស្រានូវគ្រឿងសារពើពុទ្ធអោយទុកឮ ដល់ស្ថានកណ្ដាលហោង ។

## ប្រការ ៦ : **ចំរើនបរិត្ត**

វេលាល្ងាចម៉ោង៦ព្រលប់ ដែលបូរាណហៅថា ពេលគោចូលក្រោលនិមន្តព្រះសង្ឃ៤,៥រូបមកចំរើនបរិត្ត។ឯរបៀបចំរើនបរិត្តនោះព្រះសង្ឃសូត្រធម៌ ដែលធ្លាប់ប្រើសូត្រមន្តតាមចប្បាប់ដែលហៅថាសកបរិត្ត ដែលលោកដកយកអំពីគម្ពីរព្រះសុត្តន្តបិដក មករួបរួមជាសៀវភៅសម្រាប់សូត្រមន្តទូទៅក្នុងពិធីទាំងពួង ។ តែក្នុងពេលឡើងផ្ទះនេះគួរសូត្រមង្គសូត្រ១ គាថាឥតវស្សាំវស្សិស្សាមិ១,សោរត្ថលទ្ធោ១, ជយន្តោ១, ជាកុំខានព្រោះធម៌អំបាលនេះ សំដែងអំពីជ័យមង្គលមង្គលសេចក្ដីសុខសេចក្ដីចំរើនសមគួរដល់កិច្ចនេះដោយពិត ។

# ជំនឿអារក្ខ ក្នុងវេលាមានជម្ងឺ

ជនជាតិខ្មែរនេះ មានទំនៀមរាប់អានបូជាទេវតាខ្មោចអារក្ខអ្នកតា បង់បត់ ជាដើម មកជាអង្វែងហើយការរាប់អានបែបនេះ មានប្រឡាយមកតែអំពីទំនៀមទម្លាប់ក្នុងព្រហ្មញ្ញសាសនា ដែលជាសាសនា ចាស់ជាងគេ មួយយ៉ាងសឹងបញ្ញត្តិអោយ គោរពរាប់អានទេវតាអារ័ក្ខអ្នកតាបង់បត់នឹងភូតបិសាចផ្សេងៗជាច្រើនស្ទើរតែរាប់ ពុំអស់យកជាសរណៈទីពឹង ។ ក៏ប៉ុន្តែការដែលរាប់អានបូជាដូច្នោះជាអោយគុណឬ អោយទោសដល់ការរាប់អានយ៉ាងណា នៅក្នុងផ្លូវរបស់អ្នកដែលស្វែងរកសរណៈ ទីពឹងបែបនោះនឹងគប្បីពិចារណាដោយខ្លួនឯង ។

ពាក្យថាខ្មោចក្នុងទីនេះ ជាអសាធារណនាមត្រូវនឹងពាក្យក្នុងភាសាមគធថា «អមនុស្ស» ប្រែថា មិនមែនមនុស្ស បើនឹងចំណែកជាពួកចេញទៅមានច្រើនពួកជា អ្នកមានឫទ្ធិមានអំណាចផ្សេងគ្នា ហៅឈ្មោះតាមដែលប្រើហៅក្នុងភាសាខ្មែរគឺ ទេព្វរក្ខអរក្ខមេបា អ្នកតាបង់បត់ ព្រាយអាប ធ្មប់ភូត បិសាចម្រេញគង្វាល។ល។ ពួកគន្ធព្វ យក្ស សសុរ ក្នុងបាលីលោករាប់រួមក្នុងពួកអមនុស្សគឺខ្មោចនេះដែរ ។

ខ្មោចអំបាលនោះ កាលយើងទទួលគោរពរាប់អានយកជាគ្រូបាធ្យាយហើយ ត្រូវប្រព្រឹត្តឱនលំទោនទៅនឹងឱវាទនឹងទំនៀមទម្លាប់ នឹងត្រណមរបស់ខ្មោចនោះជាដ៏រាបតែកាលណាប្រព្រឹត្តមិនជិតដល់ខ្មោចនោះ ក៏នឹងខឹង មកធ្វើអោយឈឺដោយខ្លួនឯងឬប្រើខ្មោចដទៃមកធ្វើក្នុងកាលនោះតែខ្មោចអារ័ក្ខខ្មោចមេបាចាស់ទុំនឹងបងបត់ ជាខ្មោចដែលធ្លាប់ទម្លាប់គ្រាន់បើ

កាល បើនិងធ្វើអោយឈឺក៏ធ្វើតែអ្នកដែលជាកូនសិស្សរបស់ខ្លួន សឹងប្រព្រឹត្តកន្លង ទំនៀមទម្លាប់ខ្លួន។ខ្មោចក្រៅអំពីនេះមានអ្នកតាជាដើម ជាខ្មោចសាហាវដើរធ្វើគេមិនរើសមុខគឺតែឃើញសចិត្តនឹងអ្នកណា ទោះបីជាកូនសិស្សក្តីមិនមែនកូនសិស្សក្តី ក៏អាចធ្វើអ្នកនោះអោយឈឺអោយស្លាប់ទៅបាន ។

ត្រណមខ្មោចនោះមានផ្សេងៗគ្នា គឺខ្មោចខ្លះហាមមិនអោយស៊ីផ្លែត្រឡាច នឹងមិនអោយមុជក្រោមទ្រើងត្រឡាចខ្មោច ខ្លះហាមមិនអោយស៊ីសាច់សត្វនេះសត្វនោះមាន អណ្តើកជាដើមខ្មោចខ្លះ ហាមមិនអោយយកសំពត់ស្លៀកមកទទូរក្បាល រហូតដល់ទៅមិនអោយមុជក្រោមឈើ ឬ ខ្សែដែលហាលសំពត់ស្លៀកនឹងមិនអោយមុជក្រោមផ្ទះ បើមានការដែលត្រូវមុជអោយយកសំពត់ ក្រៅពីសំពត់ស្លៀកទទូរក្បាលហើយមុជទៅបាន។ រឿងត្រណមខ្មោចនេះមានច្រើនបែបច្រើនយ៉ាងផ្សេងៗពីគ្នា មិនអាចនឹងរៀបរាប់អោយសព្វគ្រប់បានទេរៀបរាប់មកគ្រាន់ជាតួយ៉ាងប៉ុណ្ណោះ ។

ទំនៀមខ្មែរដោយច្រើន កាលមានអ្នកណាមួយឈឺនៅលើផ្ទះហើយបើដឹង សបដ្ឋានរបស់រោគថាឈឺមកពី ហេតុនេះហើយគេក៏ចាត់ការព្យាបាលទៅតាមហេតុ ឬ តាមអាការរោគនោះទៅ ។ បើគេមិនបានសមដ្ឋាននៃរោគច្បាស់ទេបានព្យាបាលព្រាវទៅដូច្នេះហើយមិនជល់មិនកប់គេរមែងពឹងរកគ្រូហ្មឬហោរអោយគន់គូរមើលអោយថាត្រូវខ្មោចធ្វើអ្វីឬក៏ឈឺដោយមានគ្រោះថ្នាក់ដូចម្តេច ?

គ្រូហ្ម ឬ ហោរ នោះក៏ទទួលគន់គូរមើលតាមក្បួនដែលធ្លាប់រៀនសូត្រមក ជួនកាលគេប្រគំភ្លេងបញ្ចូលខ្មោចសួរក៏មាន ។ ក៏ប៉ុន្តែវិធីគន់គូមើលរបស់គ្រូហ្ម ឬ ហោរនោះមានច្រើនយ៉ាងអ្នកខ្លះសួរពីថ្ងៃខែឆ្នាំនឹងចំនួនអោយអ្នកជំងឺ ហើយវាយលេខគន់គូមើលក៏មាន

អ្នកខ្លះសួរដូចគ្នានេះហើយ បើកក្បួនមើលក៏មានអ្នកខ្លះសួរ ហើយរាប់ម្រាមដៃមើលរួច ទើបទាយប្រាប់ថា ត្រូវនេះត្រូវនោះធ្វើតាមបែបបទ ដែលក្បួនបើកឱកាសអោយទាយ ។ ពួកអ្នកមើលនោះ មិនដែលទាល់ម្តងសោះ តែគេសួរហើយ ចេះតែមានរឿងប្រាប់គេជាដរាប គឺជួនកាលថាត្រូវអារ័ក្សធ្វើ ជួនកាលថាត្រូវអ្នកតាធ្វើ ជួនកាលថាខុសមេបាចាស់ទុំ ជួនកាលថាខ្មោចព្រៃធ្វើ ជួនកាលទទួលថាខុសបំណន់ ។ល។ ស្រេចហើយតែបែបបទ របស់ក្បួននោះត្រូវអោយទាយដូចម្តេចក៏ទាយដូច្នោះទៅ ជួនកាលក៏ត្រូវជួនកាលក៏ខុសនឹងយកជាកំណត់ទៀងទាត់ណាស់ពុំបាន ។

ទីនេះនឹងពណ៌នា ចំពោះតែរឿងរក្សាជម្ងឺដែលត្រូវខ្មោចអារ័ក្សធ្វើ ។ ពាក្យថាអារ័ក្សឬអារក្សប្រែថា រក្សាវេងមកកាលយកមកប្រើជាឈ្មោះប្រភេទនេះត្រូវប្រែថា«ខ្មោចដែលរក្សាវេងមក» ហេតុដែលបានឈ្មោះដូច្នោះមកពីទំនៀមទម្លាប់មានខ្មោចនោះរៀបរាប់មក តាំងពីជីដូន ជីតា ពីព្រេងនាយមកហើយខ្មោចនោះក៏តែងតែតាមថែរក្សាវេងមកដែរ ។ តែជួនកាលគេហៅថាខ្មោចចប់ចួរឬហៅថា ខ្មោចដែលជួរបុគ្គលខាងមាតានឹងខាងបិតាធ្លាប់រាប់អានវេងមក។ តែបើចំណែកខាងស្តេចវិញ ហៅថា ព្រះចំណាំ ។ ខ្មោចអារ័ក្សនេះសម្រាប់ជនជាតិខ្មែររមែងមានគ្រប់ត្រកូលតែបើនិយាយសម្រាប់រូបបុគ្គលមួយ ៗ អ្នកខ្លះគេបោះបង់ចោលមិនរាប់អានក៏មានដែរចំណែកឯវង្សត្រកូលរបស់អ្នកនោះក៏គង់នៅមានរាប់អានជាធម្មតា ។

ហេតុដែលរាប់អានខ្មោចអារ័ក្សមានរឿងព្រេងដំណាលថា : ជិពួកអ្នកដែលមិនខ្លាចបាបបានធ្វើអកុសលកម្មផ្សេង ៗ មានសម្លាប់គេលួចគេជាដើមវេលាស្លាប់ ហើយរមែងធ្លាក់ទៅសោយទុក្ខ ក្នុងនរកជាអង្វែងពាន់ឆ្នាំ លុះលោះពីនរកនោះមកកើតជាប្រេតអសុរកាយខ្មោចភូតបិសាចផ្សេងៗ ជាច្រើនពួកពាសពេញទាំងផែនដី តែងសោយទុក្ខវេទនាអត់អាហារស្រេក

ឃ្លានជានិច្ច ។ នៅស្រុកខ្មែរយើងនេះមានកាលសម័យមួយនោះ មានពួកក្មេងឃ្វាលគោក្របីជាច្រើននាក់តែងតែវេចបាយទៅស៊ីឃ្វាលក្របីតែរាល់ៗថ្ងៃ វេលាស៊ីវាក៏ជួបជុំជប់លៀងគ្នាលៀងគ្នា ស៊ីផឹក ច្រៀងរាំ យ៉ាងសប្បាយតាមភាសាកូនក្មេងពាលគ្រានោះមានពួកខ្មោចខ្មោចមកក្រវែលមើលក្មេងរំបាលនោះ ក្រែងមានចាក់បាយ ចំណី ដែលសេសសល់ចោលនឹងចោល នឹងបានរើស៊ី កាលទៅឃើញក្មេងលេងសប្បាយដូច្នេះ ខ្មោចក៏លបចូលទៅក្នុងរូបក្មេងម្នាក់ក្មេងនោះ ក៏ក្រោកឡើងរាំរងើសរងាសវាសដៃវាសជើង ដោយឥតអៀនខ្មាស់ មានអាការរហាក់ដូចជា មនុស្សស្រវឹងស្រាទាំងនិយាយចេញចាកថា យើងសប្បាយណាស់សុំអោយជប់លៀងយើងតែយ៉ាងនឹងរាល់ៗថ្ងៃ ទៅយើងឃ្វាលក្របីកុំអោយព្រួយពីរឿងបាត់ឡើយ ។ តាំងពីនោះមកក្មេងរំបាលនោះ ក៏នាំគ្នាជប់លៀងបែបនោះ រៀងដរាបមកមកខ្មោចទាំងរំបាលនោះ ក៏បកចូលក្មេងពួកនោះតែរាល់គ្នាម្នាក់ម្តងៗ។ ចំណែកឯគោក្របីខ្មោចរំបាលនោះក៏រក្សាអោយ មែនមិនមានខ្ចាត់បាត់ទៅឯណាឡើយ ។ ដល់យូរទៅខ្មោចទាំងនោះបែកប្រាជ្ញដើរធ្វើអ្នកស្រុកអោយឈឺជាច្រើនគ្នា ដើម្បីយក របស់សំណែនបរិភោគហើយវាមកចូលក្មេងឃ្វាលក្របីនិយាយថា យើងចេះមើលជម្ងឺ អោយជាក្នុងមួយរំពេចតែត្រូវរៀបជប់លៀងស្រាបាយអោយយើងព្រមទាំងមានភ្លេងតូរ្យតន្ត្រីយ៍ លេងប្រគំអោយជាទីសប្បាយចិត្តយើង ជាងកាលដែលជប់លៀងសព្វដងនេះទាំងអោយគេដាក់សំពត់អាវប្រាក់ថ្វាយជារង្វាន់ដល់រូបរបស់យើងផងនោះយើងទើបទទួលមើល ។ពាក្យនេះមិនបាត់ស្ងាត់បាន ឮជ្រួតជ្រាបទៅដល់អ្នកស្រុកច្រើនឡើងៗ ដោយលំដាប់ ។ ពួកអ្នកដែលមានជម្ងឺព្ធដំណឹងដូច្នេះក៏រលះរលាំងទៅអញ្ជើញពួកក្មេងរំបាលនោះក្មេងណាមួយមកបញ្ជាន់ជប់លៀងតាមបែបនោះ

ជម្ងឺអំបាលនោះក៏ចេះតែជាទាំងអស់ ។ មិនតែប៉ុណ្ណោះខ្មោចនោះវាបានដើរធ្វើអ្នកធំៗ មានមន្ត្រីសេនាបតីនឹងស្តេចជាទីបំផុត ។ ដល់ស្តេចប្រឈួនក៏ទ្រង់រក្សាព្រះរោគនោះតាម ទំនៀមដែលធ្លាប់ព្យាបាលមក ក៏មិនជាសះដូចសព្វដងស្តេចទើបត្រាស់អោយទៅយកក្មេងអំបាលនោះមួយ មកជប់លៀងបញ្ជាន់តាមទំនៀមរបស់វា ព្រះរោគក៏ជាទៅមួយរំពេច ។ គ្រានោះព្រះមហាក្សត្រត្រាស់ថាៈ ប្រពន្ធអញឈ្មោះជុំទាវម៉ៅស្លាប់ទៅយូរណាស់ហើយបើឯងអាចទៅយកមកបានហើយ អញពិសោធមើលបើឃើញពិតមែននោះអញនិងជឿឯង ។ ក្មេងនោះទូលថាសុំអោយរៀបជប់លៀងចុះនឹងទៅយកមកថ្វាយបាន ។ស្តេចក៏អោយរៀបចំគ្រឿងជប់លៀងយ៉ាងត្រកាលមានទាំងភ្លេងប្រគំតាមទំនៀមហើយ ទ្រង់អោយយកសំពត់អាវនឹងគ្រឿងប្រដាប់មាសពេជ្ររបស់ជុំទាវម៉ៅ យកមកដាក់លាយឡំគ្នានឹងរបស់អ្នកដ៏ទៃរួចទ្រង់អោយជប់លៀង បញ្ជាន់តាមទំនៀមខ្មោច ក៏ចូលមកក្នុងកូនក្មេងនោះភ្លាម ចូលមកក៏តាំងតែយំគក់ទ្រូងគក់ស្មាសំដែងអាការៈអាឡោះអាល័យយ៉ាងខ្លាំង ស្តេចឆ្ងល់ក៏ត្រាស់សួរថា អ្នកដែលមកចូលនេះឈ្មោះអ្វីខ្មោចនោះទូលថា ឈ្មោះជុំទាវម៉ៅ ។ ស្តេចត្រាស់ថាបើជាជំទាវម៉ៅមែនស្គាល់របស់អំបាលនេះឬទេ? បើស្គាល់អោយរើសរៀបដាក់ដោយចំណែកទៅមើល ។ ខ្មោចនោះក៏រើសយកសុទ្ធតែរបស់ជំទាវម៉ៅមកដាក់ដោយឡែកផ្សេងៗ ។ ស្តេចទតឃើញដូច្នោះក៏ទ្រង់ជឿខ្លងហើយទើបត្រាស់អោយជំទាវម៉ៅទៅអញ្ជើញព្រះវរបិតារបស់ព្រះអង្គ ដែលសុគតទៅហើយមកពិសោធដូចគ្នានោះខ្មោច ក៏ធ្វើអោយឃើញជាក់ស្តែងព្រះអង្គក៏រឹងរឹតតែទ្រង់ជឿណាស់ ឡើងស្តេចក៏ត្រាស់សុំអោយព្រះវរបិតានឹងជំទាវម៉ៅ មកនៅថែរក្សាព្រះអង្គ ។ ដោយហេតុនេះទើបមានចំប៉ូរខ្មោចអារក្សហៅថាជំទាវម៉ៅឬស្រីខ្មៅនឹងព្រះវរបិតាមកដល់សព្វថ្ងៃនេះ ។ ចំណែកឯក្មេងឃ្វាលក្របីអំបាលនោះ ក៏ជាប់ជារូបអារក្សមើលគេរៀងដ៏រាបមកដ៏រាបលុះអស់ជីវិតកាលទៅ

មើលអ្នកណាក៏យកអ្នកនោះជាកូនសិស្សហេតុនេះ ខ្មោចអារ័ក្ខឈ្មោះថាជិទាវម៉ៅ និងព្រះវរ ទើបមានពាសពេញទាំងស្រុកខ្មែររូបណាជាន់ក៏មានឈ្មោះនេះជាធម្មតា។ តែមិនចំពោះមានតែពីរ ឈ្មោះទេនៅមានឈ្មោះផ្សេងៗទៀតច្រើនដូចយ៉ាងឈ្មោះកន្ទោងខៀវជិទាវតី ឬ តីសង្រែងសំ រោងសក់ធំក្រចុំសក់ស្វាយជាដើម ។

# របៀបរណ្តាប់លៀងអារ័ក្ខ

កាលមានជម្ងឺនៅលើផ្ទះអោយគ្រូហ្ម ឬហោរមើលទៅថាត្រូវខ្មោចអារ័ក្ខដែលជាចំបប្ចូរ ខាងម្តាយ ឬ ជាចំបួរខាងឪពុកធ្វើក្តី ឬ ថាត្រូវខ្មោចព្រៃដ៏ទៃធ្វើគេត្រូវរៀបលៀងអារ័ក្ខ ដើម្បី អោយអារ័ក្ខជួយអង្វរខ្មោចនោះ អោយលើកលែងធ្វើក្តីអ្នកម្ចាស់ជម្ងឺត្រូវរៀបរណ្តាប់លៀងអា រ័ក្ខតាមទំនៀមក៏គេទំនៀមរៀបរណ្តាប់ថ្វាយខ្មោចអារ័ក្ខនេះដែរ ដូចគ្នាក៏មានផ្សេងគ្នាចេញទៅ ខ្លះ ដោយមានបញ្ចូលរបស់នេះ របស់នោះមកទៀតតាមសណ្តាប់របស់ខ្មោចនោះក៏មាន ។ ក្នុងទីនេះនឹងបានរៀបរៀងគ្រឿងដង្វាយមួយយ៉ាងទុកជាតួយ៉ាងគឺៈ បាយ បាយសីមួយគូសស្លា ធមិ មួយគូ ទឹកអប់មួយគូ ។ មានផ្កាស្រស់ផ្សេងៗមានផ្កាចំប៉ីជាដើម ដោតប្រដាប់នៅបាយសី។ របស់អំបាលនេះ អោយរៀបដាក់លើហឹង ឬ លើគ្រួនទាំងមានគ្រឿងសំណែនគឺៈចំរាបមួយ ថាស បង្អែមមួយថាស នឹង មានមាន់ស្ងោរ ឬ ក៏ក្បាលជ្រូកស្ងោរ មានស្រា មួយដប បាយមួយចាន នឹងមានតែមួយសម្រាប់ ចាប់គ្រឿងសំណែនដាក់សែន អោយ ខ្មោចព្រៃផ្សេងៗ ផង ។

ក្នុងការលៀងអារ័ក្ខនេះមានមនុស្សស្រីឬប្រុសម្នាក់មកអង្គុយកណ្ដាលចំណោមសម្រាប់អោយអារ័ក្ខចូលជាន់ដូចពោលខាងដើមមនុស្សនេះ បើប្រុសហៅថា រូបអារ័ក្ខបើស្រីហៅថារូបមេបព់មានគ្រឿងប្រដាប់សម្រាប់រូបអារ័ក្ខ គឺពោកមួយបិទទៀនធំមួយខ្លះក៏បិទទៀនស្នែងក្របីមួយនឹងមានសំពត់ហូលមួយអាវព្រៃមួយកន្សែងព្រៃក្រហមមួយ ដាក់ទង់មួយនឹងផាហ៊ឹមួយដាក់មង់មួយដឹកលំពីមុខអារ័ក្ខ ។

មានភ្លេងខ្មែរមួយវង់គឺះ ស្គរពីរ ទ្រមួយ ចាប៉ីមួយ ប៉ីពកមួយ ប៉ីអរមួយមានអ្នកភ្លេងគ្រប់ចំនួននេះនឹងមានអ្នកច្រៀងម្នាក់

ដល់ថ្ងៃលៀងអារ័ក្ខ ប្រមូលរកនឹងធ្វើរៀបចំគ្រឿងប្រដាប់អំបាលនេះបានសព្វគ្រប់ហើយវេលាព្រលប់គេក៏រៀបលេងអារ័ក្ខនៅលើផ្ទះបើផ្ទះនោះធំទូលាយ ឬក៏នៅរោងហោចទៅនៅទីវាលមុខផ្ទះ ក៏បាន ។ រូបអារ័ក្ខត្រូវរៀបតែងខ្លួនអោយស្អាតបាតចូលទៅអង្គុយនៅកណ្ដាលទីដែលគេរៀបចំទុកសម្រាប់ ។ ពួកអ្នកភ្លេងក៏ផ្ដើមលេងភ្លេងអ្នកច្រៀងក៏ច្រៀងអញ្ជើញខ្មោចអំបាលនោះមកចូលរូប ។ លេងភ្លេងមួយស្របក់ទៅនឹងមានខ្មោចមួយមកមកចូលរូបរូបនោះក៏យកសំពត់ផាហ៊ុំខ្មៅ មកទទូរពុំនោះសោតក៏យកក្រម៉ាព្រៃមកជួតក្បាលជួនកាលយកសំពត់អាវព្រៃមកស្លៀកពាក់ហើយ ទើបខ្មោចចូលជាន់ជាន់មួយស្របក់ទៅអ្នកភ្លេងបង្អន់ភ្លេងល្ហើយៗមានស្រីចាស់ម្នាក់ ហៅតាមភាសាខ្មោច ថាស្នំចូលទៅអង្គុយជិតម្ខាងសំពះសួរថាអស់លោកណាដែរដែលអញ្ជើញមកនេះ ខ្មោចនោះក៏ប្រាប់ឈ្មោះខ្លួនថាយើងឈ្មោះនេះចូលមក គឺបើជាព្រះវរក៏ប្រាប់ថាព្រះវរបើថាជំទាវម៉ៅ ។ល។ តាមឈ្មោះរបស់ខ្លួន ។ ស្នំទើបសួរតទៅទៀតថា ឥឡូវនេះផ្កា ឬកូនចាបឈើដូច្នេះតើត្រូវអស់លោកណាធ្វើ?ខ្មោចនោះបើខ្លួនធ្វើក៏ធ្វើឆ្លើយប្រាប់ថាយើងធ្វើបើខ្លួនមិនធ្វើ នឹងឆ្លើយថា យើងមិនបានធ្វើទេ ។ បើថាខ្លួន

ធ្វើស្មឹស្សួរតទៅទៀតថា អ្នកនោះធ្វើទាស់ខុសពីរឿងអ្វី? ទើបបានអស់លោកធ្វើ ។ មានហេតុទាស់ខុសដូចម្តេចខ្មោចនោះក៏ឆ្លើយទៅតាមរឿង ។ លំដាប់នោះស្មឹក៏និយាយអង្វរសុំឬអោយលើកលែងធ្វើទៅសុំអោយសះជាពីថ្ងៃនេះទៅយើងខ្ញុំបានរៀបគ្រឿងក្រយាហារមកថ្វាយសេពសោយបរិបូណ៌គ្រប់ហើយ សូមអញ្ជើញសេពសោយបើមានត្រូវការអ្វីទៀតសូមអោយប្រាប់មកចុះនឹងបានរៀបថ្វាយ។បើខ្មោចនោះ ថាខ្លួនមិនបានធ្វើគឺខ្មោចឈ្មោះនេះ ឈ្មោះនោះជាអ្នកធ្វើស្មឹក៏និយាយសុំអោយខ្មោចនោះទៅជួយនិយាយអង្វរខ្មោច អ្នកធ្វើនោះអោយលើកលែងធ្វើទៅគេរៀបគ្រឿងបូជាហើយ ។

ប៉ុណ្ណោះហើយក៏ចាប់លេងភ្លេងថ្មីច្រៀងអញ្ជើញខ្មោចដ៏ទៃ មកចូលទៀតដូចមុនដ៏រាបទាល់តែអស់ខ្មោចអារ័ក្សរបស់ខ្លួន ដែលធ្លាប់លៀងមកទាំងប៉ុន្មាន ។ ក្នុងវេលាកំពង់បញ្ជាន់ខ្មោចនោះនិង ស្តោះព្រួសអោយអ្នកជម្ងឺនឹងចងខ្សែកខ្សែខ្សែចង្កេះអោយអ្នកជម្ងឺនោះ ដើម្បីការពាមិនអោយខ្មោចដ៏ទៃក្រៅមកធ្វើ ។ ប៉ុណ្ណោះសន្មតថាចប់រឿងលៀងអារ័ក្សហើយ ។

វេលាលៀងអារ័ក្សហើយ គេចាប់បាយចំណីដាក់ពៃអោយមនុស្សម្នាក់យកទៅដាក់ក្រៅរបងផ្ទះជូនអោយខ្មោចព្រៃផ្សេងៗសេពសោយ ។

កាលលៀងដូច្នេះហើយបើអារ័ក្សនោះធ្វើមែនអាចនឹងជា ដោយច្រើនរៀងលែងតែធ្ងន់ស្រាលពេក ទៅនឹងដោះគំនួចរបស់ខ្លួនមិនរួច ស្លាប់ទៅក៏មានជាច្រើន ឬ មានខ្មោចដ៏ទៃបានឫទ្ធិអំណាចខ្លាំងមកធ្វើខ្មោចអារ័ក្សទប់ទល់អំណាចគេមិនបានជម្ងឺនោះស្លាប់ទៅក៏មានជាច្រើន ។

# ពិធីឡើងអ្នកតា
# ក្នុងខែពិសាខជាដើម

ពាក្យថា«អ្នកតា»ក្លាយចេញមកពីពាក្យថា «ទេវតា»ក្នុងជាន់ដើមប្រហែលជាហៅថាអ្នកទេវតាយូរៗមកកាត់ចោលទេវចេញនៅត្រឹមតែអ្នកតា ហើយហៅជាប់រៀងមកដល់សព្វថ្ងៃនេះ ដោយហេតុមនុស្សបូរាណកាល និងនិយាយចេញឈ្មោះអ្នកធំច្រើនដាក់ពាក្យថាអ្នកនៅខាងដើម ដូចយ៉ាងហៅព្រះពុទ្ធថាអ្នកព្រះពុទ្ធហៅព្រះ សង្ឃថាអ្នកព្រះសង្ឃរឬអ្នកយើងហៅ ស្តេចថាអ្នកព្រះបាទជារម្ចាស់ចូរមើលសាស្ត្រាបូរាណឬមើលសិលាចារិកបូរាណនឹងប្រទះឃើញជាច្រើន ។ ពាក្យថាអ្នកតាក្នុងទីនេះបូរ...លោកសំដៅយកភូមិទេវតា គឺទេវតាជាន់ទាបដែលអាស្រ័យនៅ ថានមនុស្សលោកនេះ ។

មូលហេតុដែលរាប់អានអ្នកតារហូតដល់ទៅខ្មោចអារ័ក្ខបិសាចផ្សេងៗជាប់មកពីទំនៀម ទំនៀមទម្លាប់មនុស្សក្នុងជាន់ដើម ពីក្នុងសម័យដែលមិនទាន់កើតមានអ្នកប្រាជ្ញមានព្រះពុទ្ធជាដើមក្នុងលោក មានអ្នកល្ងង់ខ្លៅច្រើនជាអ្នកប្រកបដោយសេចក្តី តក់ស្លុតក្នុងរឿងស្លាប់នឹង រឿងគ្រែងមិនសមប្រកបច្រើន ហេតុនោះកាលណាគេ ឃើញអ្វីប្លែកចំឡែកអស្ចារ្យក្នុងចិត្តដោយស្មានថាគង់ជាមានអានុភាពជួយខ្លួនបានដូច្នេះដូច្នោះទេដឹងទើបនាំគ្នាធ្វើការបួងសួង បន់ស្រន់ទៅផ្សេងៗសុំអោយសំរេចតាមសេចក្តីប្រាថ្នារបស់ខ្លួនរហូតទៅដល់ព្រៃភ្នំក្រុំថ្មក៏យកជា

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P.

សរណាទីពឹងដែរដូចមាន ប្រាកដក្នុងខេមាខេមាសរណាបទីបិតាថា ពហុំវេ សរណំយន្តិ បព្វតានិ វនានិចអរាវាមរុក្ខចេត្យា និមនុស្សាភយកធីតា «ប្រែថា » មនុស្សទាំងឡាយជាច្រើន កាលមានសេចក្តីភិតភ័យគ្របសង្កត់ ហើយរមែងដល់នូវភ្នំខ្លះព្រៃខ្លះទីសួនច្បារខ្លះរុក្ខចេតីយ គឺដើមឈើធំៗកាលគេរាប់អាចជាចេតិយ៍ខ្លះជាសរណាទីពឹងដូច្នេះ ។រួមសេចក្តីទៅជាសរណាទីពឹង របស់សត្វលោករកទីបំផុត គ្មានជារបស់មានរូបក៏មានជាររបស់ឥតរូបក៏មានមានតាំងពីថានបាតាលរហូតដល់ថានសួគ៌ហើយមិនកំណត់នៅនឹងចំនួនតែប៉ុណ្ណោះលោកនេះនៅមានដ៏រាបណាសរណាវត្ថុរបស់សត្វនិងកើតមានថ្មី ៗប្លែកឡើងទៀតជាច្រើន (ដ៏រាបនោះក្នុងសាសនាព្រហ្មណ៍ក៏ បញ្ញត្តិថាធាតុវត្ថុទាំងពួង មាន ធាតុបី : ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ជាដើមសុទ្ធតែមានទេវតាស្ថិតនៅប្រចាំទាំងអស់ នាំអោយសេចក្តីអាក្រក់ សេចក្តីល្អដល់មនុស្សលោកដូចយ៉ាងធាតុដីមាននាងធរណីព្រះភូមិ- ក្រុងពលី ជាអ្នកនៅប្រចាំធាតុភ្លើងមាន « ព្រះអគ្គី»នៅប្រចាំធាតុធាតុខ្យល់មានព្រះពាយនៅប្រចាំ។ល ។ អ្នកណាត្រូវការអ្វីក៏ធ្វើការបួងសួងបន់សុំអោយសំរេចតាមសេចក្តីរបស់ខ្លួនហេតុនោះទើបកើតមានជជាទំនៀម បួងសួងនឹងបន់លៀងទេវតាអ្នកតាអារ័ក្ខខ្មោចបិសាចផ្សេង ៗ តាមដែលខ្លួនធ្លាប់រាប់អាន។ប្រទេសកម្ពុជាយើងក៏ធ្លាប់រាប់អានតាមទំនៀមនេះជាអង្វែងមកហើយដែរ មើលទៅបើស្រាវជ្រាវរកមុខប្រសប់ដើមក៏គង់ជាមិនប្រទះឃើញថាមានមកពីកាលណា«១-ចូរមើលសេចក្តីពិស្តារក្នុងរឿងសាសនាប្រវត្តិព្រះមហាពិច្ចកាសេមដែលបោះពុម្ពនៅព្រះរាជបណ្ណាល័យ »តែមានសេចក្តីក្នុងគម្ពីរចាមពោធិវង្សត្រង់បរិច្ឆេទទី ១៥ ខ្សែ៩ ថាក្នុងសម័យដែលស្តេចខ្មែរតាំងក្រុងនៅស្រុកលវោ (លពបូរី) គ្រានោះមានស្តេច១អង្គទ្រង់ព្រះនាមលវរាជាទ្រង់ជ្រាបថានៅនគរបរិភុញ្ជ័យ«នគរលាវ»មានអ្នកតា១ ពួកកែណាស់នៅផ្នែរស្ទឹងសលុយនរីអ្នកតានោះ មានមាន់ស១មាន ឫទ្ធិណាស់ដែរមានពាក្យទំនាយ

ថាអ្នកតានិងមាន់នោះមានជីវិតរស់នៅដ៏រាបណា នគរបរិភុញ្ញ័យក៏រុងរឿងដ៏រាបនោះព្រះបាទលវរាជាទ្រង់ជ្រាបដូច្នោះ ទើបត្រាស់ដឹងអ្នកតាដែលនៅប្រចាំក្រុងលពបូរី អោយទៅសម្លាប់អ្នកតានិងមាន់សនោះបង់។អ្នកតាលពបូរីទៅសម្លាប់បានតែមាន់ហើយ ត្រឡប់មកវិញព្រះបាទលវរាជទ្រង់សោមនស្សណាស់ទ្រង់បូជាដោយសក្ការយ៉ាងឧឡារិក ។ ថ្ងៃក្រោយត្រាស់អោយទៅសម្លាប់អ្នកតានោះទៀតអ្នកតាលពបូរីក៏ដំណែងខ្លួន ជាសាមណេរកាត់ទៅរកអ្នកតាបរិភុញ្ញ័យៗដឹងខ្លួនក៏និរមិត្រខ្លួនជាក្រពើបបួលគ្នាទៅច្បាំង ក្នុងស្ទឹងដល់ច្បាំងទៅសាមណេរអ្នកតាចាញ់ប្រៀបត្រូវក្រពើអ្នកតាខាំស្លាប់ទៅសេចក្តីនោះ ជ្រាបដល់ស្តេចលពបូរីត្រាស់អោយទៅយកសពសាមណេរអ្នកតាមកដុតរើសឆ្អឹងបញ្ចុះក្នុងចេតិយ៍ ។ អតោបដ្ឋាយកម្ពុជាតាបិតាំទេវតារូបំ បូជេន្តិមានុសេន្តិរយំអម្ពា កំនភារក្ខទេវតាតិដោយហេតុនេះចាប់ផ្តើមតាំមពីនោះមកប្រជុំ ដែលនៅប្រទេសកម្ពុជា ក៏នាំគ្នាបូជារាប់អានអ្នកតានោះ តាមសមគួរដ៏ថានជាអ្នកតាដោយគិតថា «នេះជាអ្នកតារក្សារគនរបស់យើងទាំងឡាយ» ។ ពាក្យថាអ្នកតារក្សានគរត្រូវដឹងពាក្យមគធៈថានគររារក្ខទេវតាហើយត្រូវនិងពាក្យដែលយើងសព្វថ្ងៃថាអ្នកតាម្ចាស់ស្រុកឬគេហៅថាអ្នកតាក្លាំងមឿង ។

ពាក្យថាក្លាំងមឿងប្រែថា កណ្តាលស្រុកគឺអ្នកតាកណ្តាលស្រុកតែតាមសំដីដែលអ្នកស្រុកហៅឬសរសេរច្រើនថាឃ្លាំងមឿងសឹងក្លាយមកពីពាក្យថាក្លាងមឿងនោះឯង ។ ដែលហៅថាអ្នកតារក្សាស្រុកក្តី អ្នកតាម្ចាស់ស្រុកក្តីអ្នកតាក្លាងមឿងក្តីសម តាហេតុនោះហើយព្រោះថាក្នុងក្រុងក្នុងស្រុកក្នុងនិគមជនបទនីមួយៗ ក្នុងប្រទេសកម្ពុជា សុទ្ធតែមានអយកតាប្រចាំទាំងអស់គ្មានខ្វះចន្លោះស្រុកឯណាមួយទេ១១ ដូចយ៉ាងនៅភ្នំពេញនេះមាននៅទៀតព្រះដំណាក់ផែនិងវត្តភ្នំ។អ្នកតាទាំងនោះមានទាំងប្រុស ទាំងស្រី ហើយមានឈ្មោះផ្សេងៗគ្នាតែអ្នកតាខ្លះគ្មាន

ឈ្មោះគេហៅតាមតំបន់ទីលំនៅដែលអ្នកតានោះនៅក៏មានដូចយ៉ាងអ្នកតានៅវត្តស្លែងគេហៅថាអ្នកតា ស្លែងដូច្នេះជាដើមពេលចំពោះតែអ្នកតាធំៗ ដែលល្បីកេរ្តិ៍ឈ្មោះមានមនុស្សកោតក្រែងច្រើនអ្នកតាប្រុស ឈ្មោះអ្នកតាព្រះចៅ អ្នកតាព្រះកន្លោងអ្នកតាដំបងដែកអ្នកតាក្រហមកណ្តាអ្នកតាទសមរអ្នកតាពិឃណោសអ្នកតាឃ្លាំងមឿងជាដើម ។អ្នកតាស្រីឈ្មោះយាយទេពជំទាវតីសង្រេងស្រីខ្មៅសំពោងសក់ធំជាដើម ។

« ១ » ចូររមិលសាស្រ្តាប្រណិធានដែលសម្រាប់សូត្រស្បថនៅសាលាតុលាការសព្វថ្ងៃនេះ។

ឱកាសដែល និងឡើងអ្នកតានោះចំណែកទៅតាមកាលជាពាគីឡើងជាកំសាន្តស្រុកក្នុងវេលាដើមឆ្នាំជារាល់ឆ្នាំនោះ១យ៉ាងឡើង កាលដែលស្រុកមិនសុខសប្បាយដោយមានកើតជម្ងឺអហិវាតករោគជាដើម១យ៉ាងឡើង ក្នុងកាលធ្វើកិច្ចឬធ្វើរបររកស៊ីធំៗនោះ ១ យ៉ាង ។

ឯទំនៀមឡើងអ្នកតាជាកំសាន្តស្រុកនោះតាមប្រក្រតីក្នុង១ឆ្នាំ គេរៀបឡើងម្តងហើយច្រើនឡើងខែពិសាខ ដូចយ៉ាងទំនៀមព្រាហ្មណ៍រមែងនិមន្តព្រះឥសូរ១ព្រះនារាយណ៍១ព្រះពិឃណោស១ព្រះច័ន្ទ១ព្រះកម្ពាយន៍និងភ្លុក_កុយយកទៅតាំងនៅមុខអ្នកតាឃ្លាំងមឿង ។

( ឥសូរនារាយណ៍ពីរនេះជាឈ្មោះព្រះជាម្ចាស់ក្នុងសាសនាព្រាហ្មណ៍ព្រះពិឃណោសជាបុត្រព្រះឥសូរខ្លួនជាមនុស្សឬទេវតាក្បាលជាក្បាលដំរីលោកនេះ មានរឿងថាកាលនៅពីកុមារតូចព្រះឥសូររៀបពិធីកោរជុកត្រាស់អោយទេវតាទៅអញ្ជើញ ព្រះនារាយណ៍ទេវទូតនោះទៅដល់ឃើញព្រះនារាយណ៍កំពង់ផ្ទំស្កល់ក៏ផ្ទំដាស់ព្រះនារាយណ៍ក្រោកឡើង ទេវទូតក៏ក្រាបទូលតាមដំណើរព្រះនារាយណ៍ខ្ទាល់ផ្តាស្សាថា កោសក់អាកូនកំបុតក្បាលនោះឬ?ក្បាលព្រះពិឃណោសក៏កំបុតទៅតាមព្រះវាចានោះមែន រកមិនឃើញព្រះឥសូរអោយរកក្បាលមនុស្ស ឬ

ក្បាលទេវតាបែបដូចគ្នាមកតតែរកមិនបានទៅឃើញតែដំរី១ស្លាប់ ទេវតាក៏កាត់យកក្បាលដំរីនោះមកថ្វាយព្រះឥសូរ ។ ទ្រង់តជាប់ហើយរស់នៅដល់សព្វថ្ងៃនេះ ហេតុនេះគេទើបធ្វើរូបព្រះពិឃណេសដូច្នេះ ។ ព្រះច័ន្ទ មិនដែលប្រទះឈ្មោះក្នុងក្បួនព្រាហ្មណ៍ ។ មានតែឈ្មោះព្រះខ័ន្ទកុមារ ឬ ហៅថា សន្ទរកុមារ ឬហៅម៉្យាងទៀតថាករតិកេយៈជាបងប្អូនពោះមួយគ្នា នឹងព្រះពិឃអេសចូលមើលសេចក្តីពិស្តារក្នុងរឿងសាសន៍ប្រវត្តិ ។ ព្រះកម្ពាយន៍ជាឈ្មោះព្រះថេរៈមួយអង្គក្នុងសម័យពុទ្ធកាលលោកនេះ មានរឿងដំណាលថារូបឆោមល្អណាស់ស្រីក្តីប្រុសក្តីកាលឃើញលោកហើយអត់ស្រឡាញ់លោកមិនបានដូចយ៉ាងរឿងសោរេយ្យសេដ្ឋី ឃើញលោកក៏នឹកស្រឡាញ់គិតតែក្នុងចិត្តថា អញនឹងបានប្រពន្ធអោយមានរូបល្អដូចយ៉ាងលោកក្នុងខណៈនោះសោរេយ្យ សេដ្ឋីក៏ក្លាយទៅជាស្រីដោយហេតុនេះជាដើម លោកទើបអធិស្ឋានខ្លួនលោកអោយអាក្រក់ពោះធំក៏រួញជាប់ស្នាពួកអ្នកលេងវេទមន្តគេគសាងរូបលោកឡើងសម្រាប់ប្រើជាស្នេហ៍ ជាដើម ។លំដាប់នោះព្រះរាជគ្រូសូត្រប្រកាសអញ្ជើញទេវតានូវអ្នកតា ម្ចាស់ស្រុកផ្សេង១ ចប់ហើយទើបព្រាហ្មណ៍ប្រាំបីអង្គប្រសិទ្ធិពលិការបូជាយកទឹកស្រង់ព្រះស្រោចលើភ្លុកកុយ អំបាលនោះរួចនិយាយប្រតិអធិស្ឋានដល់ទេវតាទាំងប្រាំបីទិសនឹងអ្នកតាក្លាំងមឿងនោះសូមអោយចំរើនព្រះជន្មវស្សាដល់ព្រះមហាក្សត្រធិរាជអោយបានព្រះជន្មវែងជាអង្វែងទៅអោយស្តេចស្ថិតនៅក្នុងសិរីរាជសម្បត្តិជាសុខក្សេមក្សាន្តសម្រានព្រះរាជហឫទ័យសព្វទិនទិវារាត្រី នឹងសូមអោយបណ្តាព្រះរាជវង្សានុវង្ស នឹងសេនាមាត្យមន្ត្រីរហូតដល់អាណាប្រជានុរាស្ត្រទាំងសម្ពាយ អោយបានសេចក្តីសុខសប្បាយនឹងសេចក្តីចំរើនទូទៅគ្រប់១គ្នា នឹង សូមអំណាចទេវានុភាពចូរបណ្តាលអោយមានភ្លៀងធ្លាក់ត្រូវតាមរដូវកាលតាំងពីដើមឆ្នាំរហូតដល់ចុងឆ្នាំនេះ ដើម្បីអោយអស់អាណាប្រជានុរាស្ត្រធ្វើស្រែចំការច្បារដំណាំអោយផលសំបូរឡើងក្នុងព្រះនគរ ។

មិនតែឡើងអ្នកតានៅទីក្រុងប៉ុណ្ណោះចាងហ្វាងក្រុម ព្រះរាជមន្ទីរធ្វើចុហ្មាយប្រាប់ទៅចៅហ្វាយខែត្រចៅហ្វាយស្រុកទាំងអស់អោយបង្គាប់អស់លោកអាណាប្រជានុរាស្ត្រអោយឡើងអ្នកតាផ្សេងៗដែលមាននៅក្នុងតំបន់ស្រុកនោះៗព្រមក្នុងថ្ងៃជាមួយគ្នា ដើម្បីប្រយោជន៍ដូចពោលហើយ ។

ឯទំនៀមដែលរាស្ត្រឡើងអ្នកតានោះគេច្រើនកំណត់ធ្វើនៅថ្ងៃ អង្គារ ឬ ក៏ថ្ងៃណាមួយកាលដល់រដូវខែពិសាខគឺថ្ងៃមួយកើតខែពិសាខទៅគេរមែងរៀបចំមានជួសជុលខ្ទមអ្នកតាជាដើមហើយបូជាក្នុងថ្ងៃណាមួយ តែអ្នកដែលកាន់ទំនៀមបូជាក្នុងថ្ងៃ អង្គារឬថ្ងៃសៅរ៍នោះបើថ្ងៃមួយកើតនោះជាថ្ងៃអង្គារឬថ្ងៃសៅរ៍គេក៏នាំគ្នាធ្វើនៅថ្ងៃនោះតែម្តងអ្នកស្រុកខ្លះគេលឿនទៅបូជាក្នុងថ្ងៃសៅរ៍ដ៏ទៃទៅក៏មានតែទំនៀមខែត្រពោធិសាត់ គេកំណត់ឡើងនៅថ្ងៃមួយកើតខែពិសាខជាដ៏រាបរាល់ឆ្នាំ ។

ចំណែករបៀបគ្រឿងដង្វាយអ្នកតានោះ មិនដូចគ្នារមែងប្រព្រឹត្តទៅតាមទំនៀមទម្លាប់របស់អ្នកតានោះ ៗ គឺអ្នកតាណាធ្លាប់សោយរបស់អ្វីគេក៏ថ្វាយរបស់នោះភោជនាហារដែលថ្វាយដោយច្រើននោះ គឺបាយសម្ល ត្រីសាច់ផ្សេងៗមានសាច់មាន់សាច់ទាសាច់ជ្រូកជាដើម ។ អ្នកតាអ្នកតាខ្លះចូលចិត្តសោយសត្វព្រៃគេក៏រកសត្វព្រៃនោះៗមកសម្លាប់ធ្វើជាអាហារ បូជាហើយនឹងមាននំចំណីផ្សេងៗផង។ដល់វេលាបូជាគេក៏នាំគ្នាយកក្រយាហារអំបាលនោះទៅឯខ្ទមអ្នកតាបើជាអ្នកតាមានរូប«គឺមានមនុស្សជារូបសម្រាប់អោយអ្នកតាចូល»គេក៏យកអ្នកជារូបនោះទៅបញ្ចូលអ្នកតាគឺគេលេងភ្លេងខ្មែរ មាន ស្គរ ទ្រ ចាប៉ី ប៉ីអរ នឹងអ្នកចម្រៀង ឯពួកអ្នកភ្លេងលេងភ្លេងទៅអ្នកច្រៀង ក៏ច្រៀងអញ្ជើញអ្នកតាអោយចូលរូប ហើយនឹងទទួលសែនសោយក្រយាហារដែលសែនព្រេនថ្វាយ ក្នុងកាលឥឡូវនេះ កាលអ្នកតាចូលមកហើយ គេនិយាយប្តឹង

សូមអោយអ្នកស្រុកទាំងអស់គ្នា មានព្រះមហាក្សត្រជាដើរហូតដល់សត្វពាហនៈសត្វចិញ្ចឹមទាំងពួងអោយបាននូវសេចក្តីសុខសប្បាយ កុំអោយមានរោគាព្យាធិរបៀតបៀនឡើយនឹងសូមអោយមានទឹកភ្លៀងធ្លាក់មកបរិបណ៌ត្រូវតាមទំនៀមតាំងពីដើមរហូតដល់ចុងឆ្នាំអ្នកតាក៏ឆ្លើយទទួលថានឹងជួយអោយសុខសប្បាយតាមដែលសុំនោះរួចហើយគេក៏ចាប់ចំណីអាហារអំបាលនោះដាក់នៅពែលើកទៅដាក់ថ្វាយនៅខ្ទមអ្នកតាសល់ ក្រៅអំពីនោះក៏លៀងគ្នាបរិភោគហើយត្រឡប់មកផ្ទះរៀងខ្លួន ។

ក្នុងពេលដែលស្រុកមិនសុខសប្បាយ ដោយមានកើតជំងឺអហិវាតករោគជាដើមនោះក៏មានទំនៀមឡើងអ្នកតាដែរគឺមានក្នុងវេលាណា គេរៀបចំធ្វើក្នុងវេលានោះរបៀបដែលឡើងអ្នកតាក្នុងពេលដែលស្រុកមិនសប្បាយនេះមានន័យផ្សេងគ្នាអំពីទំនៀមឡើងអ្នកតាដោយធម្មតានោះខ្លះសូម្បីទំនៀមឡើងអ្នកតាក្នុងពេលដែលស្រុកមិនសប្បាយនោះក៏នៅមានរបៀបផ្សេងគ្នាដោយស្រុកចេញទៅទៀតក្នុងទីនេះ នឹងមានរៀបតាមក្បួនរបស់លោកឈ្មោះ ស៊ុនសាំង មេឃុំចាស់នៅឃុំគោកព្រីងស្រុករំដួល «ខែត្រស្វាយរៀង» ដែលបានផ្ញើមកអោយព្រះរាជបណ្ណាល័យដែលបានពិនិត្យឃើញថាអ្នកស្រុកទាំងពួងច្រើនធ្វើដូច្នេះ គឺដំបូងឡើងរៀបធ្វើរោងបុណ្យមួយខ្នងនៅទីជិតខ្ទមអ្នកតានិងធ្វើខ្ទមអ្នកតាជាថ្មីឬគ្រាន់តែជួសជុលអោយ ជិតស្រួលបួលឡើងគេរៀបគ្រឿងបណ្ណាការឡើងអ្នកតាគឺធ្វើជារូបរទេះគោរទេះ ក្របីនឹងរូបគោក្របី ដំរី សេះជាពាហនៈបញ្ជូនខ្មោចបីសាចអោយទៅស្រុកឆ្ងាយៗ នឹងដំឡើងទង់ប្រាំបីទិស រានទេវតាប្រាំបីទិសច្រមប្រាំបីទិស ប្រដាប់ពៃថែងមួយស្រូវមួយចានអង្ករមួយចានជមបួនស្លាធមិបួនទៀនធូបនឹងទឹកអប់មួយគូប្រអប់ស្លាកំណាល់សំពត់ស ក្រហម ប្រាក់បួនស្លឹក ឬ បួនសេននឹងស្លកបង្អែមមួយចំអាបមួយ ។

វេលារសៀងនាំគ្នាទៅលេងភ្លេងបីបទថ្វាយ «បើមានរូបចតូវបញ្ចូលរូបផង ដើម្បីសួរយកការផ្សេង ៗ » ដល់ប្រលប់និមន្តព្រះសង្ឃមក សូត្រមន្តព្រឹកឡើងថ្វាយចង្ហាន់សង្ឃដារឆ្លងរួចហើយធ្វើកិច្ចនាំគ្នាជញ្ជូនសង្ឃឹក នឹងរបស់ភស្តុភារដែលសែនអោយខ្មោចនឹងរទេះទឹមសត្វអំបាលនោះចេញពីទីអ្នកតាទៅតាមផ្លូវធ្លា ដល់ចុងស្រុកឈប់រៀបសច្ចាធិស្ឋានសូមអោយខ្មោចបីសាចកំណាចអំបាលនោះត្រឡប់ទៅស្រុកទៅទេសវិញទៅ យើងរៀបសែនបូជាដោយក្រយាហារនឹងយានពាហនៈមូលមកសព្វគ្រប់ព្រម ហើយខ្មោចជិតយកបាយខ្មោចឆ្ងាយយកអង្ករហើយយកមួយក្តាប់គ្រវាងប្រចេរចេញទៅ ហើយត្រឡប់មកវិញកាលមកដល់រោងអ្នកនៅរោងធ្វើជាឧបកិច្ចសួចថាទៅអស់ហើយឬ ? អ្នកដែលជូនទៅឆ្លើយថាលោកទៅអស់ហើយអ្នកតាអោយយើងរាល់គ្នាសុខសប្បាយទាំងអស់ហើយ ។

ទំនៀមឡើងអ្នកតា ក្នុងការធ្វើកិច្ចការឬធ្វើរបររកស៊ីនោះគឺឡើងក្នុងវេលាធ្វើបុណ្យធំៗធ្វើមង្គលការផ្សេងៗធ្វើរបររកស៊ីធំៗ ដែលត្រូវធ្វើក្នុងទីព្រៃទីទឹកដូចយ៉ាងទាក់ដំរីបេះផ្លែក្រវាញនេសាទត្រីជាដើម ក៏មានទំនៀមឡើងអ្នកតាដែរ តែអ្នកតាក្នុងប្រភេទនេះមានជាពីរយ៉ាងគឺអ្នកតាធម្មតានោះម៉្យាងអ្នកតាបាយ៉ាបគឺអ្នកតាទឹកនោះម៉្យាងអ្នកតាបាយ៉ាបនោះ គេប្រើបន់ចំពោះតែក្នុងវេលាទៅនេសាទត្រីអ្នកតានេះមាននៅក្នុងទីទឹកមានបឹងជាដើមអ្នកតាលើម៉្យាងអ្នកតាបឹងម៉្យាងក៏ឃើញគួរដែរ។ការដែលមានទំនៀមឡើងអ្នកតាក្នុងពេលដូច្នេះបើជារករបរនៅព្រៃភ្នំក៏ដើម្បី ចៀសចាកក្តីអន្តរាយ មានដំរីព្រៃចខ្លាខាំ ពស់ចឹកជាដើម ហើយសូមអោយរករបរនោះឆុតឆាប់ដូចសេចក្តីប្រាថ្នាបើជានេសាទត្រីក៏ ដើម្បីចៀសចាកក្តីអន្តរាយដូចគ្នានោះមានកុំអោយត្រូវក្រពើខាំពស់ចឹកជាដើម ។ បើជាធ្វើការមង្គលទាំងពួងនោះក៏ ដើម្បីជាមង្គលរហូតទៅ កុំអោយមានអ្នកឯណាមួយ ដល់នូវគ្រោះថ្នាក់ មានឈឺក្បាល វិលមុខជាដើម ។

របៀបឡើងអ្នកតាក្នុងពេលដូច្នោះមានគ្រឿងដង្វាយតែល្មមសមគួរគឺមានបាយសម្លរ ញាំ ភ្លាប្លួបចំណើត្រីសាច់មាន់ មួយរៀបដាក់ពៃហើយរុចទៀនធូបដាក់សែនអោយអ្នកតាត្រូវ ដូចប្តេចក៏នាំគ្នាបន់សុំអោយសម្រេច ដូច្នេះទៅតែអ្នកតាខ្លះមានទំនៀមធ្លាប់សោយអ្វីគេក៏រក របស់នោះមកថ្វាយចំពោះយ៉ាង។តែទំនៀមសែនអ្នកតាបាយ៉ាបនោះ មានរបៀបផ្សេងទៅទៀត «រៀបរៀងតាមក្បួនរបស់អាចារ្យឈ្មោះងែត ទិត្យ នៅស្រុកកំពង់សៀមខែត្រកំពង់ចាម» អ្នក ដែលនឹងទៅនេសាទត្រីនៅទីបឹងជាដើម ត្រូវរៀបចំសែនថ្វាយអ្នកតាបាយ៉ាបគឺធ្វើខ្ទមអ្នកតាមួយ នៅទីដែលនឹងនេសាទត្រីនោះហើយ ធ្វើប្រទាសពីរចងនៅខ្ទមអ្នកតាម្ខាងមួយនឹងយកផាឱបមក ធ្វើជាកន្ទុយទង់ចងជាមួយគ្នានោះនឹងមានបំពង់ទឹកបួនចងព្យួរថ្វាយ រួចហើយនាំគ្នាយកបាយ សម្លរ ប្លួប ចំណើត្រី សាច់ មាន់ទា ស្រាមកដាក់រុជទៀន ធូបសែនថ្វាយអោយអ្នកតាអោយរក ស៊ីមានលាភច្រើន។កាលគេចាប់បានសត្វចំឡែក។ដូចយ៉ាងក្រពើជាដើម គេក៏កាត់យកក្បាលទៅ ថ្វាយអ្នកតានោះ។ក្នុងថ្ងៃត។ទៅក្នុងរវាងដែលនៅរកស៊ីនោះគប្បីឧស្សាហ៍រុជទៀនធូបថ្វាយរាល់ ថ្ងៃ។មួយទៀត ក្នុងវេលាដែលធ្វើរបរទៅនោះមានទំនៀមអោយកាន់ត្រណមផ្សេង។មានមិន អោយបំភ័យគ្នាអោយខ្លាចជាដើម កាលណាបើធ្វើអោយខុសត្រណមឬធ្វើអោយខុសអំពីដែល សន្យានឹងអ្នកតាចំណាំតែមានគ្រោះថ្នាក់មកដល់ អ្នកនោះដូចយ៉ាងទំនៀមឡើងអ្នកតាបេះផ្លែ ក្រវាញនៅខែត្រពោធិសាត់បើបន់សុំបេះបីថ្ងៃហើយ មិនធ្វើតាមនោះដល់ថ្ងៃទីបួនទៅបេះទៀត ដោយមិនបន់អនុញ្ញាតជាថ្មីនិងប្រទះក្តីអន្តរាយមានខ្លាខាំឬពស់ចឹកជាដើមជាមិនខានដោយហេតុ គ្រោះថ្នាក់ដូច្នេះគេទើបនាំគ្នាពលិការអ្នកតាដូចពោលមក ។

# ក្បួនហៅព្រលឹង

ទំនៀមចាស់ទុំអំពីបូរាណ តែងប្រព្រឹត្តរៀងមកគឺបើកាលណាមានអ្នកណាមួយឈឺជាទម្ងន់ដល់ភ្លាំងភ្លេចស្មារតីមានសតិពុំបរិបូណ៌គេសំគាល់ឃើញថា អ្នកនោះមានព្រលឹងពុំនៅក្នុងខ្លួនហើយគេរមែងធ្វើពិធីហៅព្រលឹង អោយមកស្ថិតនៅក្នុងខ្លួនអ្នកជម្ងឺនោះវិញ។រីឯព្រលឹងនោះចេញទៅបាត់អំពីរូបកាយដូចដែលគេសំគាល់នោះឬមិនបានចេញទៅ។បើថាព្រលឹងចេញទៅមែនការធ្វើពិធីហៅបែបនោះ ព្រលឹងត្រឡប់មកវិញឬមិនបានមកវិញទេនោះជាបញ្ហាជ្រៅ១ជាន់ទៅទៀតទុកអោយអ្នកប្រាជ្ញជាន់ខ្ពស់លោកវិនិច្ឆ័យចុះក្នុងទីនេះ យើងនឹងមិនវិនិច្ឆ័យទេគ្រាន់តែអធិប្បាយរៀបរៀងទៅតាមទំនៀមទម្លាប់បូរាណប៉ុណ្ណោះ ។

តាមទំនៀមបូរាណ កាលបើមានអ្នកជម្ងឺដូច្នេះគេរមែងរៀបពិធីហៅព្រលឹងតែច្រើនរៀបហៅតែអ្នកជម្ងឺនោះនៅក្មេងបើអ្នកជម្ងឺនោះចាស់ហើយ គេមិនធ្វើទេរបៀបគ្រឿងហៅព្រលឹងនោះ អោយរៀបដូច្នេះអោយរៀបក្រាលសំពត់តាំងអំពី ចំលោកអ្នកជម្ងឺទៅដល់មាត់ទ្វារហើយនឹងចងសំពត់ធ្វើជាពិតាន ហើយយកផ្កាស្លាមកចងផ្កាឈើ មកចងធ្វើជារំយោលរួចធ្វើជម៤,ស្លា៣,ម្លូ៣,អង្ករ១សៀន,ទៀនពីរ,ប្រាក់១បាទ ,សំពត់ស១គូដាក់ឆ្វេងស្តាំ ផ្លែឈើពីរតោកអោយរៀបដាក់កន្ទោងហើយដាក់ក្នុងតោកបង្អែម២តោកអោយរៀបដាក់កន្ទោងហើយដាក់ក្នុងតោកបាយព្រលឹង១ចាន អំពៅ១ចាន ។ ដល់វេលាហៅព្រលឹងអោយម្នាក់កាន់ចានបាយព្រលឹងម្នាក់កាន់ចេកម្នាក់កាន់អំពៅ ។ អ្នកដែលកាន់អំពៅនោះជាអ្នកហៅព្រលឹងតឬស្វូត្រហៅតាមក្បួនដែលលោកចងទុកដូចមានតទៅៈនឹងហៅតែ១ថ្ងៃក៏បានឬនឹងហៅ ៣ថ្ងៃ ក៏បានស្រេចហើយ

តែនឹងសង្កេតមើលអ្នកជម្ងឺនោះបើឃើញថាគ្រាន់បើហើយនឹងហៅតែ១ថ្ងៃក៏បានបើមិនគ្រាន់បើ អោយគប្បីហៅតទៅដរាបគ្រប់ ៣ ថ្ងៃ ។ កាលធ្វើរួចខ្មោះជម្ងឺនោះចំណាំតែត្រឡប់ជាធូរស្បើយ ស្បើយឡើងវិញ ។ វេលាហៅរៀបចប់ហើយអោយម្នាក់កាន់ឈ្នាងធ្វើជាដើរទៅជញ្ជាត់ព្រលឹង ទៅតាមព្រៃផ្សៃខាង១ផ្ទះនោះហើយ ចាប់យកសត្វតូច១អ្វី១ដូចយ៉ាងពីងពាងជាដើមមកបោះ អោយអ្នកជម្ងឺ នោះក្នុងវេលាដែលព្រលឹងចប់ហើយហើយព្រលឹងមកវិញហើយ ។

# ពាក្យហៅព្រលឹង

បេសិទ្ធិការ សិទ្ធិសម្ភារះបារមីកន្លងតថាគតតស្ស ពុទ្ធស្សជាច្បង ទសបារផង ម៉ឺជ្រោបជ្រែងរក្សា ។ សិទីព្រះពុទ្ធព្រះធមិបរិសុទ្ធ ព្រះសង្ឃសទ្ធាចាំសិលរត់ទោស នភកវា ទាំងរត្តិបហា ព្រះភូមិប្រក្រតី ព្រះពាយព្រះគង្គ ព្រះគុណឧត្តុង្គឧត្តម សួស្តីព្រះព្រហ្ម ព្រះឥស្សរព្រះនារាយណ៍សោតនៃ ព្រះឥន្ទធិបតីទាំងរស់ទេវតា ។ ទាំងទេវបុត្រ ប្រសើរបរិសុទ្ធ ចេត្តារទាំងព្រះឥសី សទ្ធិសាស្ត្រាព្រះពៃ ស្រពណ៍ ជាចំរើនសួស្តី ។ ទាំងនាគរាជ រឹងរិទ្ធរំណាច ព្រះធរណី ព្រះរាម ព្រះលក្ខណ៍ សួគិសុខរិទ្ធិរុងរឿងជ័យ ស្រីឥតងថ្មីបាន ។ អញ្ជើញឥសីអ្នកប្រើសិទ្ធិជាតិជាប្រ ធានអញ្ជើញអ្នកហោង យើងផ្សងឆ្ពោះថ្កាន រាល់ទេពពិមាន ព្រៃត្រឹងសួគ៌ា។យើង ខ្ញុំសូមពរ ទាំងទេពនិករទូទាំងទិសារ ទាំងហិមពាន្ត ស្ថិតស្ថានគោហា ទូររាល់រា កាសគង្គសួគិសព្វ ។ អញ្ជើញអ្នកគណ ចូលមកឆាប់រ៉ា ទាំងសព្វទាំងគ្រប់ ផ្សផ្សងឆ្ពោះថ្កាន ពិមានសាយសព្វ អញ្ជើញគោរពចំរើនសួ ស្តី ។ យើងយករស់អ្នក ប្រធានសិទ្ធិសក្តិ ជាអ្នកដើមក្តី យកព្រះគង្គា ទុកជាសាក្សី

យកព្រះធរណីទុក ជាពេជ្ជាណោ ។ ព្រះឥន្ទអោយពរ ព្រះព្រហ្មបវរ អោយសុខ

ក្សេមក្សាន្ត ទាំង លោកុត្តរ ព្រះអង្គអោយពរ អោយសុខជោគជ័យ ជ្រោមជ្រែងរក្សា

ករុណា ប្រពៃ ព្រះពុទ្ធច្រើនក្រៃ ស្តេចស្តែងចេស្តារ ។ អស់អង្គអរហន្ត ប្រសើរលើលេ

លន់ តើងសូមករុណា អ្នករាជអោយពរ បវរសុខសា បាយបរិបូណ៌ ព្រាកដ

គាប់ក្សេមក្សាន្ត ។ ទាំងទេពនិមន្ត ប្រសើរលើសលន់ ព្រះប្រាជ្ញរបាន អ្នក

គើយចូលមក អញ្ជើញអ្នកធ្យាន សូមពរសុខសាន្ត សប្បាយហ្មត់ហ្មង។ យើងខ្ញុំសូមអធិដ្ឋ

សូមពរប្រសិទ្ធិ ប្រសើរកន្លង សូមតេជតេជះ តបះនោះផង សូមជ្រោងជ្រែងបោង

គាប់ការរក្សា ។ សូមអ្នកក្រវើន ចម្រុងចម្រើន យើងខ្ញុំនេះណា សូមទិតទេវតោ

ឡសព្រហ្មជៀងជួយ រក្សាបំពេញបរិបូណ៌ ។ យើងខ្ញុំអធិស្ឋាន ផ្សំផ្សងឆ្លោះថ្កាន កុំអ្នកផ្សង

ផ្សូ បើកទិព្វចន្ទា ករុណាអាសូ សូមជួយមកចូល ព្រះលើងបាសផ្លែ ។ សូមអស់ទេវតា

ស្ថិតស្ថាននានា កំលុងព្រឹក្សព្រៃ និតនៅស្រះស្រង់ កំពង់ជលស័យ ទទួលនាយនៃ ចូរស្តាប់

ខ្ញុំហោង ។ ព្រះនារាយព្រះឥសូរ ស្តែងស្តេចបន្ទូល បន្តក់គ្រប់គ្រង ព្រះបរបសូរបន្ទូល

ប្រើផង បុត្រអញស្នេហ៍ស្នេង ពីវរៈមេត្រី ។ អោយអញស្រែកហៅ ព្រួលេចទូ ទៅ

ដល់ព្រៃគីរី ទាំងហិមពាន្ត ដល់ស្ថានឥសី ដល់បន្ទូលទី យក្ខអាសូរ៉ា ។ អញកាន់រំពៅ

ដង្កោយ ស្រែកហៅព្រួសូរសព្ទសាយ ជ្រួតជ្រាតទៅដល់ បណ្តូលទីឆ្ងាយ ក្នុងក្រៅសប្បាយ

កក្រើកពេញ្យាហា ។ ព្រះបាទទសរដ្ឋ ប្រសើរព្រាកដ នៅបូពិទិសា គន្ធ័ពយោយៅ

តែងទៅវន្ទា ស្តេចស្តែងនេះជា អម្ចាស់សិរសី ។ ព្រះបាទវិរុឡ្ហ មហារាជសោយ ស័ក្តិទ

ក្សិណទិសា អស់យក្ខកប្ប័ន្ធ នូវវន្ទអភិវាទវរ វន្ទីបាទបង្គំប្រណិបត្តិ ។

ព្រះបាទវិរុបក្ខ មហារាជសិទ្ធិស័ក្តិ រុងរឿងពេកក្កាត់ នៅទិសបស្ចិមមា សោយរាជសម្បត្តិ នាគនៃយកវត្ត ថ្វាតថ្វាយបង្គំ ។ ព្រះបាទវេស្សវណ្ណ នររាជ សោភ័ណ សោយសុខភិរម្យ នៅទិសឧត្តរបវរ សុខសមយកថ្វាយបង្គំ ខ្លបខ្លាច បារមី ។ អស់ទាំងអារក្ខ ទាំងខ្មោចប្រេតយក្ខ អាសូរបីសាច សព្វស្ថាននា១ ព្រឹក្សា គិរី អស់អាសុលរី សឹងតែខ្លបខ្លាច ។ ទាំង៤ក្សត្រា រឹងរិទ្ធិចេស្តា រិទ្ធិអំណាច សព្វសុខសួគិសល មណ្ឌលសោយរាជ្យ អង្គអញឯងអាច សូមជួយមេត្រី ព្រះ ខាតខាមា អគ្នេយ៍ទិសា ចម្រើនរិទ្ធិព្រះសៅរ៍ លោកស្ថិតនៅទិសនិរតី សូមជួយមេត្រី ចម្រើនជេយ្យា ។

ពាយ័ព្យទិសទី សម្តេចព្រះស្រី សំមានទេវា នៅទិសឦសាន មែនមាន ចេស្តា សេពសោយសុរា សូមជួយមេត្រី ព្រះអាទិត្យព្រះច័ន្ទ ប្រសើរសោភ័ណ ព្រះមាតុលី នាងមេនល្លា ទេវតាឥសី ឥស្សរធិបតី សូមជួយជេយ្យា អស់ហ្វីន លោកធាតុ យើងខ្ញុំអភិវាទ ដល់ស្ថានអ្នកណា សូមជ័យសួស្តី រិទ្ធិចេស្តា ចម្រើនទីឃាយុ យិនសិទ្ធិ ។

អញ្ជើញទេវតា សោឡស្សសួគ៌ា ចម្រើនសួស្តី យកព្រះគង្គា ជាតិជាសាក្សី យកព្រះធរណី មកជាពេជ្ជាណ ។ ព្រះបរមសូរ ព្រះអង្គបន្ទូល អោយ អញឯងធ្យាន បន្ទិចបន្ត រៀងទុកនៅប្រាណ អញឯងអញមាន មេត្រីស្នេហា ។ អញកាន់អំពៅ អញហោយស្រែកហៅ ដោយតេជះចេស្តា អញមានមេត្រី ឥត បីក្រោធា អ្នកកើយយាត្រា មកស្ថានលំនៅ ។ អស់ញាតិកា ចាស់ទុំមេបា សន្តានសាច់ធៅ រៀបអស់សារពើ ផ្លែឈើចាំនៅ សឹងចែកអំពៅ ទង់អ្នកនាស្ថាន ។ អោយអញឯងហៅ អ្នកកើយកុំទៅ

វិលវិញមកថ្កាន មេបាត្រេកអរ សាទរក្បៀមក្សាន្ត កុំបីអ្នកមាន គិតចរយាត្រា ។ ស្ថានអ្នកនៅ
អាយ អ្នកកើយសប្បាយ សុខសល់មហិមា អ្នករែងដើរលេង ដោយល្បែងស្នេហា
អស់ញាតិកា ព្រៀង លានសាទរ ។ ស្រឡាញ់ស្នេហ៍ស្និទ្ធ មូលមួយគំនិត មេត្រីត្រេកអរ
ព្រលឹង ថ្លៃអើយ អ្នកកើយបីចរ វិលវិញបរិបូណ៌ ដូចសព្វដង ។ ញាតិផៅទន្ទឹង បបក់
ព្រលឹង អ្នកកើយមកហោង កុំអ្នកចេញទៅ ព្រៃស្ថាននោះផង មកនៅនឹងបង
ប្អូនញាតិកា ។ ព្រលឹងមាសើយ កុំអ្នកនៅឡើយ ដោយពាក្យអញវ៉ា អ្នកកើយ
ផ្លូវព្រៃ ក្រៃក្រក្តាត់ណា សឹងតែបន្លា ស្បូវស្បាកនោះផង ។ អ្នកកើយសឹងខ្លា
រមាសមហិមា សាហាវណាស់ហោង សឹងតែដំរី រាជសីហ៍នោះផង មានខ្លា
ដម្បង រខិនខ្លាធំ ។ ខ្លាត្រីសោតណា សាហាវសោះសា មានទាំងខ្លាឃ្មុំ សព្វ
សត្វយង់ឃ្នង ដោយដងព្រៃភ្នំ អ្នកកើយអ្នកកុំ ដើរទៅម្នាក់ឯង ។ សឹងតែគោ ព្រៃ
ក្របីក្រាសក្រៃ គ្រវីចស្នែង សាហាវដេញដល់ ជាញដល់ឥតក្រែង
គគ្រឹកគគ្រេង សព្វព្រៃព្រឹក្សា ។ សត្វច្រើនដេរដាស សឹងតែរមាស រមាំងស្វាន
ស្វា ចចកឆ្កែព្រៃ ច្រើនក្រៃក្តាត់ណា អោយអ្នកយាត្រា វិលវិញមកថ្វាត់ ។

ដំរីសេះសិង្ហ ជញ្ជ័ចទ្រហឹង ដេរដាសប្រកិត ចុះប្រេងគួរខ្លាច ពុំអាច
ចូលជិត មុខគួរអោយគិត មកស្ថានវិញណា ។ ព្រលឹងមាសសើយ កុំអ្នកទៅ ឡើយ
ស្តាប់ពាក្យអញវ៉ា អ្នកកើយផ្លូវទៅ សឹងសៅបន្លា សសិតផ្លាញផ្លា រញ្ជាកន្លង ។
ទ្រីគីទ្រីគា នបក្សីបក្សា ច្រើនក្រៃពេកហោង ឪឡូវខ្លែងខ្មោច ទោមទោចយំកង
ខ្លែងស្រាកស្រែកផង លួងលោមព្រលឹង ។ ល្មង់មេអំបៅ ដោយដងព្រៃជ្រៅ
ស្រែកយំទ្រហឹង សឹងតែសត្វខ្មោច លួងលោមព្រលឹង ក្នុងព្រៃស្ងាត់ឈឹង

សឹងសត្វហិង្សា ។ មានប្រេញគង្វាលសុក់ព្រាញ ច្រួញច្រាល កាចក្រៃបបិបាទិទុយមៀមមុម ភ្នែកធំសោះសា សំបើមក្តាត់ណា មុខគួរខ្លាចក្រៃ ។ ព្រលឹងមាសសើយ កុំអ្នកទៅឡើយ វិលវឹងមករាយ ដប្បន់ស្ថានយើងថ្មីផ្តើងប្រពៃ មុខគួររាល័យ រាលោះក្តាត់ណា ។ អ្នកមើលពួកព្រំពួក ព្រៃចៀបចំខ្ពស់ ខ្មោយពស្ត្រា វិលវឹងមកស្ថាន សម្រានរាគ្នា អោយអ្នកយាត្រា វិលវឹងមកផ្ទាត់ ។ អ្នកកើយកុំទៅ វីស្ថានព្រៃជ្រៅ យំបាកពេកក្តាត់ នឿយណាស់ល្អិតល្អៃ សន្ធៃក្នុងចិត្ត មុខគួរអោយគិត មកស្ថានវិញណា ។ អញកាន់រំពៅ អញហោយស្រែកហៅ សត្វព្រៃព្រឹក្សា សព្វច្រកជ្រលង ដោយដងរាទ្វា ព្រលឹងយាត្រា មកឆាប់កុំផ្សង ។ កុំដើរឯព្រឹក កុំបានចិត្តនឹក ដើរឯថ្ងៃត្រង់ ព្រលឹងមាសសើយ អ្នកកើយកុំផ្សង អញឯងធ្យានត្រង ហៅអ្នកមកបោង ។ កុំទៅដោយទឹក ជ្រាលជ្រៅពន្លឹក សាហាវកន្លង កាចកាភោគ្គា ជាអាហារផង ដោយឆ្នេរដោយដង សមុទ្ទនោះឯង ។ ព្រលឹងមាសសើយ កុំអ្នកទៅឡើយ ស្តាប់ពាក្យអញថ្លែង អញនឹងប្រាយ ប្រាប់សណ្តាប់សម្តែង ដំណើរដំដែង ដ៏ប្អាលមាតា ។ អ្នកកើយមកឆាប់ វិលវឹងក្រឡាប់ ឋានយើងវិញណា អញមានមេត្រី ឥតបីក្រោធា អោយអ្នកយាត្រា មកស្តាល់លំនៅ ។

ក្នុងព្រៃព្រឹក្សា សឹងខ្មោចមាយា វាលួងលោមហៅ ទោះខ្មោចព្រៀងលាន សន្តានសាច់ផៅ វាលួងលោមហៅ កុំដោយគេឡើយ ។ អ្នកកើយពាក្យខ្មោច វែងលួងអន្លោច ពាក្យផ្អែមជាត្រើយ ពាក្យនោះសឹងប្រែ ឥតពិតឡើយ ព្រលឹងមាសសើយ កុំអ្នកយាត្រា ។ អ្នកកើយព្រៃក្រៅ សមុទ្ទជ្រាលជ្រៅ វាសឹងហិង្សា ព្រលឹងមាសសើយ អ្នកកើយមកវ៉ា អ្នកស្តាយនរណា នឹងទៅដោយគេ ។ ក្នុងព្រៃព្រឹក្សា

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

សឹងខ្មោចមាយា រាជភូតស្រាយស្រែ សកើយអ្នកត្រេច ទៅម្តេចដោយគេ មកនៅនឹងមេ បាឯងនាស្ថាន ។ គេលួងកុំទៅ ទោះខ្មោចញាតិផៅ គេហៅប៉ុន្មាន គេទៅជាខ្មោច អាសោចសាមាន្យ កុំឱ្យអ្នកមាន ចិត្តចរទៅឡើយ ។ អស់បងប្អូនអ្នក មេបារួមរ័ក ស្រឡាញ់ឥតស្បើយ អញ្ជូកាន់អំពៅ បោយហៅមកហើយ ព្រលឹងមាសសើយ កុំអ្នកផ្សងផ្សា។ អញស្រែកខ្លាំងហៅ ឮសាយដល់ក្រៅ លំនៅទិសបូព៌ា ព្រលឹងមាសសើយ អ្នកកើយកុំយូរ អ្នកមកអោយចូល នៅនឹងមេបា ។ កុំទៅអាគ្នេយ៍ បីសាចស្រាយស្រែ លួងលោមយាម ព្រលឹងមាស អ្នកកើយយាត្រា អ្នកមកវិញណា កុំទៅព្រាតព្រាយ ។

ទក្សិណទិសឬ្ស សឹងខ្មោចអប្រិយ៍ បីសាចទាំងឡាយ សឹងយក្សអាសូរ ច្រើនសល់រាយមាយ សឹងតែខ្មោចព្រាយ រំបល់នោះផង ។ និរតីទិសឬ្ស សឹងខ្មោចអប្រិយ៍ ទ្រូស្តទ្រើសយង់ឃ្នង អ្នកដោយពាក្យអញ វិលវឹងមកថ្កាន មកស្ថានយើងហោង សុខកល់ក្សេមក្សាន្ត ។ ពាយ័ព្យទិសសោត កុម្ភទ្ធពីរោធកាច ក្រែងប្រមាណ សំបើមសប្បាយ មហាហារបាន ដាលេដេញរុករាន មុខគួរអោយស្ញែង ។ ឧត្តរទិសា សឹងខ្មោចមាយា រាជភូតសម្លែង ព្រលឹងមាសសើយ ប្លោះហើយលេះលែង ស្តាប់ពាក្យអញថ្លែង វិលវឹងយាត្រា ។ ឥសាន្តសោតសឹង រាសិរសោតរឹង កាចក្រៃមហិមា ព្រលឹងមាសសើយ អ្នកកើយមកវ៉ា រវសញ្ញាតិកា ទន្ទឹមរង់អ្នក ។ ញាតិអ្នកឯងអោយ អញស្រែក ដង្ហោយសំណេះលោម លៀរួសរកខ្ចីខ្ចាន អញកាន់អំពៅ ចំរើនសួ ដង្ហោយស្រែកហៅ ទិសទាំងប្រាំបី ។ ឮដល់អាកាស ទេព្តាទាំងផ្តាស ចម្រើនរិទ្ធិ ទាំងព្រៃហិមពាន្ត ទាំងស្ថានគីរី ទាំងមហាប្រថពី ប្រាសាទគុហា ។ អោយអ្នកចូលមក ឆ្លងឆក អំពី ជ្រលងជលសា ពីព្រៃពីបឹង ពីស្ទឹងពារា ពីព្រែកនានា ដងអូរនោះផង។

ព្រលឹងមាសសើយ សព្វថ្ងៃជាត្រើយ ស្រងំានកន្លង មុខគួរតែសៀង សព្វដើមឈើផង សឹងខ្មោចសោតហោង ដម្លៃងកាឡា ។ ខ្លះធ្វើភ្នែកធំៗ ខ្លះខ្លួនប៉ុនភ្នំអង្រង់សីរសា រំសាយទាំងសក់ ស្លើតស្លន់នេត្រា សំបើមក្ដាត់ណា ខមហើយយំផង ។ ខ្លះលៀនអណ្ដាត ចង្កូមសព្រាត ខ្លះទាក់កចង ខ្លះចោលចុះមក នឹងថ្មគ្រួសផង ខ្លះកាន់ដម្បង ក្រវីដេញដល់ ។ ខ្លះស្ទុះខ្លះលោត កំពស់ដើមត្នោត ខៀវរស់ឥន្ទ្រីយ៍ សម្បុរសជ្រីក អាក្រក់អប្រិយ៍ អ្នកកើយទៅថ្វី វិលវឹងមកវ៉ា ។ អណ្ដាប់នោះទៅ កណ្ដាលព្រៃជ្រៅ ស្ងប់ស្ងាត់សឹង តែសត្វខ្មោច លន្លោចចរចា ប្រាប់ពស់ប្រាប់ខ្លា ប្រាប់បាស្កន់ផង ។ សព្វស្ថានមាត្រា សឹងតែបន្លា ចម្រូងនោះផង សឹងគ្រួសខ្សាច់ ក្ដៅសឹងផ្ដៅសឹងវល្លិផង កម្រក្ដាត់ហោង កុំអ្នកយាត្រា ។ ទាំងទាកទាំងឈ្លើង ជាន់ជាប់ដោយជើង មុខគួរណាយណា ដើរមដេចសឹងឈាម រអាមរអារ សង្វៀរបាទា ពុះពងជាំក្រំ ។ សឹងយក្ខអាសណី វាដើររកឆី ដោយដងព្រៃភ្នំ ព្រលឹងមាសសើយ ម្លោះហើយអ្នកកុំ ដើរដោយព្រៃភ្នំ ត្រមោចម្នាក់ឯង ។ ញាតិផៅចាំនៅ អ្នកកើយកុំទៅ ត្រេចព្រៃកន្លែង អញកាន់អំពៅ បោយហៅក្ដែងៗ អ្នកកើយអញឈ្វេង យល់សព្វមាត្រា ។ អោយអ្នកមកឆាប់ វិលវឹងក្រឡប់ ស្ថានយើងនេះណា តេជះបារមី រិទ្ធីចេស្ដា តេជះគាថា ចម្រើនពរថ្លៃ ។ អាយុវណ្ណំ សុខំពលំ សិទ្ធិវិជេយ្យ ភវន្តុមេធម្មេ ថ្លាថ្លៃ រស់ទេព្វភព ត្រៃសឹងជ្រោមសាទរ ។ ព្រះពុទ្ធរក្សា ព្រះធម៌ករុណា ព្រះសង្ឃ អោយពរ ព្រះឥស្វរសាយ ព្រះនារាយណ៍វរ ព្រះឥន្ទ្រអោយពរ ព្រះព្រហ្មអោយជ័យ ។ ទេព្ដអោយសុខ ប្រសើរសួស្ដី លែងទុក្ខលែងភ័យ សឹងជ្រោមអោយពរ បវរថ្លាថ្លៃ បង្ហាញផ្លូវព្រៃ អោយអ្នកយាត្រា ។ ចម្រើនបារមី ចម្រើនរិទ្ធិច ម្រើនសុខាអោយយស

សម្បត្តិ ច្រើនក្តាត់មហិមា អោយលាភអោយ អាយុយឺនជាត្រៃយ ។ អញបោយហៅចប់ព្រលឹងប្អូនដណ្តប់ ចូលមកគ្រប់ហើយ ឥតទុក្ខឥតភ័យ ចង្រៃបៀតឡើយ ញាតិផៅអ្នកកើយ មូលមកកុះករ។ ខ្លះកាន់ផ្លែឈើ រៀបសព្វសារពើ ទទួលអោយពរ សម្ទេះសម្បាលត្ររាលត្រេក អររមីមេកកុះករ ទទួលអ្នកហោង ។

អញហៅអ្នកណា ជុំញាតិកាវង្សា ផៅផងអញផ្តែផ្តាំ ផ្តេចពាក្យពេជន៍ជាម្តងនោះគេល្បួងលោម កុំអ្នកដោយទៅ ។ ទេព្តទេពរ័ក្ស នៅអស់អារក្ខ ធំតូចក្មេងក្រៅលោកបើកមកហើយ អ្នកកើយកុំទៅ អ្នកវិលមកនៅ និង ញាតិផៅផង ។ ព្រះបរមសួរព្រះអង្គបន្ទូលផ្តាំផ្តេច ហើយហោងទោះ ខ្មោចបិសាចនូវរាជភូត ក្រែងខាងល្បួងលងវាលោមវិលវល់ ថ្ងៃនេះឯងណា កាលពារពិលា ឧត្តមមង្គល ព្រលឹងប្រាំប្អូន ដណ្តប់សព្វគ្រប់មកដល់ ចូលក្នុងបណ្តុលលំនៅ គ្រឹះឋានអញហៅ បីថ្ងៃហើយអញ តូចដៃជុំញាតិជុំបងជុំប្អូន ជុំដូនជុំតា អោយស្បើយសោះជា ពីថ្ងៃនេះទៅហោង ។ ឧមស្រូបមហាស្រូបទើបគ្រូប្រើអញស្រូប ព្រលឹងតូចមើល អំពីកំពូលភ្នំ ទើបគ្រូប្រើ អញស្រូបព្រលឹងធំមើល គេយកទៅទុក ដោយដើមឈើធំ ទើបគ្រូប្រើស្រូប ព្រលឹងអ្នកនេះហើយគេយកទៅទុក ដោយអារក្ខនោះផង ទើបគ្រូប្រើអញស្រូប ព្រលឹងអំពីព្រៃទើប គ្រូប្រើអញស្រូប ព្រលឹងអំពីអារក្ខ អំពីឆ្អប ទើបគ្រូប្រើអញស្រូប ព្រលឹងអំពីគេកប់ សន្ធប់នៅថ្មមហាសិលា ទើបគ្រូប្រើអញស្រូប ព្រលឹងគេយកទៅកប់នៅមហាប្រថពី ទើបគ្រូប្រើអញស្រូប ព្រលឹងគេយកទៅកប់នៅផ្លូវខ្មោច ទើបគ្រូប្រើអញ ស្រូប ព្រលឹងគេយកទៅកប់ពាសក្នុងឆ្នាំងបាយថ្ម ទើបគ្រូប្រើអញស្រូប ព្រលឹងគេយកទៅទុកនៅមាត់ស្ទឹងមាត់បឹង ទើបគ្រូបប្រើអញស្រូបព្រលឹងគេ យកទៅទុកនៅអារក្ខដម្បូកហែងថ្មដា

ទើបគ្រូប្រើអញស្រូប ព្រលឹងគេយក ទៅកប់នៅរន្ធក្តាម ទើបគ្រូប្រើអញតាមស្រូប ព្រលឹងអំពីគង្គា មហាសមុទ្ទ ហេតុនេះព្រះមន្តអញឆុតស្រូប ព្រលឹងទាំង ១៩ គ្រប់នូវរូប នេះឯងហោង ទាំងព្រលឹងមយីមាយាគេយកទៅទុក ដោយអារក្ខជុមការ សព្ទស្ថាននានា គេយកទៅទុក ដោយនាភូមិស្រែនោះផង ទើបគ្រូប្រើអញស្រូប ព្រលឹងទាំង អំពីមាត់គោ ក្របី មាត់ត្រីសព្វសត្វ អម្រិតបក្សី ខ្លែងស្រាកទីទុយ មៀមឪឡរ ទើបគ្រូប្រើអញស្រូប ព្រលឹងអ្នកដ៏មានជម្ងឺដម្កាត់នោះហោង ។ ឧមសិទ្ធីស្វាហះ ស្តាប់ បង្គាប់ អញជាគ្រូបាធ្យាយ ។

# ពិធីលើករាសី

វេលាដែលរាសីរបស់គេ ធ្លាក់អាប់មានតែសេចក្តីមិនស្រួលកើតឡើងញយៗ និងធ្វើអ្វី ច្រើនតែមិនសម្រេចក្តីប្រាថ្នា ឬ កាលនឹងធ្វើការដែលសំខាន់ៗនោះ ចង់អោយសម្រេចផុតឆាប់ ទៅដូចបំណងក្តីប្រាថ្នា នឹងអោយឡើងយសស័ក្តិធំជាងប្រក្រតីនោះ ទៅក្តីពួកអ្នកដែលជឿ ក្បួនខ្នាតនេះគេរមែងរៀបចំធ្វើពិធីលើករាសីរបស់ខ្លួនអោយរុងរឿងភ្លឺថ្លាឡើង ។ ក៏ប៉ុន្តែការ ដែលធ្វើដូច្នេះនឹងយកជាពិតប្រាកដណាស់ពុំបានជួនកាលគេក៏ឃើញអោយផលមកមែន ជួនកាល ក៏ស្ងួនឡូហើង ទៅតែនិស្ស័យបនុស្សយើងទេតើ កាលមានបំណងដូចម្តេចហើយនឹងធ្វើខ្លួនឯង ទៅតែប្តងមិនកើតក៏តោងរាវរកនេះ រកនោះមកជួយក្រែងលោសម ប្រកបក៏នាំគ្នាធ្វើតៗមក ទាល់តែជាប់ជាទំនៀមត្រង់ពិតឬមិនពិតនោះទុកមួយអន្លើសិន ។

រីឯរបៀបធ្វើនោះ មានរបៀបផ្សេងៗពីគ្នាតាមគតិរបស់អាចារ្យអ្នកជាដើមការអោយ ធ្វើតែ ក៏មិនខុសឆ្ងាយពីគ្នាប៉ុន្មាន លើសខ្វះគ្នាត្រឹមមួយមុខពីរមុខប៉ុណ្ណោះ កាលនឹងប្រមូល បែបរំបាលនោះមកសំដែង ក្នុងទីនេះអោយអស់ជើងតែប្តងក៏ឃើញថាយឺតយូរណាស់ ឬថាផុត វិស័យនឹងប្រមូលមកក៏បាន។ ហេតុនេះទើបសូមនាំមកបែបមួយមកសំដែងទុកជាតួយ៉ាងតែល្មម សមគួរដូច្នេះអោយធ្វើបាយសីធំមួយ កំពស់ជិហ៊ារអ្នកសាម៉ីខ្លួន បាយសីប៉ាក់ឆាមមួយគូរស្លាធមិ ស្លាធមិមួយគូរ ទឹកអប់មួយគូរ ទៀនប្រាំ ធូបប្រាំផ្កាប្រាំ លាជប្រាំថ្វាយជាពុទ្ធបូជា ។ នឹងរៀប ចំគ្រឿងសំណែនគីពែរាយប្រាំវូត កន្ទោង៥ ដាក់បាយ ម្ហូប ចំណីតាម ទំនៀមឆ័ត្ររូតប្រាំ នឹង រូបស្នងខ្លួនមួយដាក់ក្នុងពែនោះ១២ ។ និងរៀបស្លាធមិប្រាំបីទឹកអប់អោយរៀបដាក់អមសងខាង អ្នកសាម៉ីខ្លួនម្ខាងបួនៗ ។

អោយរៀបសែនហើយនិមន្តលោកចំរើនបរិត្តលើករាសីទៅតាមទំនៀមដែលធ្លាប់សូត្ររៀងមក ដូចគ្នា នឹង ពិធីសូត្រមន្តរំដោះគ្រោះហ៍ ។

# ទំនៀមសូត្រមន្តរំដោះគ្រោះ

អ្នកដែលមានជម្ងឺឈឺមកយូរថ្ងៃហើយ រក្សាព្យាបាលដូចម្ដេចហើយមិនជាគេរមែងរកគ្រូឬហោរគន់គូរមើលហេតុដែលបណ្ដាលអោយឈឺនោះបើមើលទៅត្រូវថាមានគ្រោះថ្នាក់នោះគេរមែងនិមន្តលោកមកសូត្រមន្តរំដោះគ្រោះហ៍នោះអោយបានជាសះស្បើយល្ហើយទៅ ។

ក្នុងកិច្ចនេះត្រូវរៀបរណ្ដាប់ផ្សេងៗតាមទម្លាប់របស់គ្រូអាចារ្យដែលធ្លាប់ធ្វើ រៀងមក ក៏ប៉ុន្តែទម្លាប់របស់គ្រូអាចារ្យនោះមិនដូចគ្នាខ្លះមានគ្រឿងប្រដាប់ច្រើនខ្លះមានគ្រឿងប្រដាប់ដាក់ក៏ល្មមសមគួរ ។ ក្នុងទីនេះនឹងរៀបរៀងតាមបែបមធ្យមល្មមអោយអ្នកទីទាល់ក្រធ្វើបានផងដូចមានតទៅនេះ :-

អោយរៀបគ្រឿង ពុទ្ធបូជា គឺ បាយសីប៉ាក់ឆាមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូទៀនប្រាំ ធូបប្រាំ លាជប្រាំ ផ្កាប្រាំ ។នឹងរៀបគ្រឿងបូជាទេវតា គឺស្លាធម៌ប្រាំបី ទឹកអប់ប្រាំបីអោយរៀបដាក់សងខាងខ្លួនអ្នកជម្ងឺម្ខាង ៤ ។ នឹងធ្វើពែមួយហៅថា ពែមឈូស បណ្ដោយប្រវែងមួយហត្ថអ្នកជម្ងឺ ទទឹង ប្រវែងមួយចំអាមអ្នកជម្ងឺ អោយរៀបដាក់បាយ សម្លរ ញាំភ្លា នំចំណីក្នុងពែនោះតាមទំនៀម នឹង សូនរូបមួយដោយម្សៅ គឺជារូបស្នងខ្លួនអ្នកជម្ងឺអោយរៀបអោយរៀបដាក់ក្នុងពែនឹងមានប្រើ ឬ ស្បូវស្ងួតប្រមាណមួយក្ដាប់ទុកនឹងដុតរូបនោះ ។ សំពត់ប្រវែង ៤ ហត្ថ អ្នកជម្ងឺ ។ នឹងមានអង្ករវាល់ដោយនាឬដោយចានតូចៗចំនួនស្មើនិងអាយុ

អ្នកជម្ងឺបើមានសេស ខែ ថ្ងៃ ប៉ុន្មាន អោយវាល់ប៉ុណ្ណោះដាក់ទៅទៀត។នឹងវាល់ទឹកអរប់ចំនួនដូចគ្នានេះ ដាក់ក្នុងថ្ពិលធំមួយនឹងមានពូនភ្នំខ្សាច់មួយពូនដាក់នៅថាស ។

របស់អំបាលនេះ អោយយកទៅរៀបដាក់នៅមុខកន្លែងលោកស្វូត្រមន្ត ។ ដល់វេលានិមន្តលោកមកស្វូត្រមុន និង ស្វូត្រមន្តអាចារ្យរៀបសែនប្រចេគ្រោះថ្នាក់នោះអោយស្បើយល្ហើយ ហើយយកភ្លើងអុជប្រីឬស្បូវដុតរូបម្សៅនោះជាឧបកិច្ចថាបានដុតអ្នកជម្ងឺនោះហើយហើយជូនពៃនោះទៅតាមទិស ។

# ពាក្យសែន

អញ ខ្ញុំ ស្វូមអញ្ជើញទេវតា នវព្រះបរម មេស្វូរព្រះពិស្ណុការ ព្រះមេត្យវព្រះកាលទើបអញ្ជើញព្រះ អាទិត្យ ព្រះច័ន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បត៍ ព្រះសុក្រ ព្រះសៅរ៍ ព្រះរាហូ ព្រះកេតុ ។ ទើបអញ្ជើញគ្រូព្រះរាមអគ្នេយ៍ទក្សិណ ព្រះលក្សណ៍និរតី រាពណ៍បស្ចឹមសិតា ពាយ័ព្យសិភាយុ ឧត្តរ ហនុមាន ឦសាន ពិភេកទើបអញ្ជើញអ្នកមកយកក្រយ៉ា បូជា អញ ខ្ញុំ ស្វូមស្មាលាទោសអ្នកហោង ។ ទោះឈើក្បាលត្បូង ឈើកណ្ឌ៍ឈើទ្រូង ស្វូមស្មាលាទោស កុំអ្នកប្រកួតទោះឈើថ្កាត់ ចូលរមួតរមួលចង្កោរក្អែរក្អួតទោះឈើ ដោយចាក់ឈើច្បាក់សាច់ស្ងួត បំពង់ក ស្ងួតខាន់ ខះទឹកមាត់ ទើបអញ្ជើញអ្នករំដោះគ្រោះដម្កាត់រោគា អោយបាត់វិនាសទៅហោង បពិត្រវឹងថ្វាត់ទៅដោយស្ថានទីទៃហោង ឱនមោពុទ្ធស្សនមោធម្មស្ស នមោសង្ឃ ស្សហុលោ ហុលោ ស្វាហាយ ចរណាយចេញទៅ ។

លំដាប់នោះគេរៀបសូត្របន្ត គឺសូត្រធមិយោងគ្រោះបាំតាមទម្លាប់ដែលសូត្ររៀងមក ហោង ។

# ពិធីពលិការព្រះពិស្ណុការជាគ្រូដើម ខាងវិជ្ជាជាង

ពាក្យថា « ពិស្ណុការ » នេះជាឈ្មោះអ្នកណា ? គួររោយពិចារណាស្រាវជ្រាវរក ។ តាមដែលធ្លាប់ដឹងមក ពិស្ណុជាឈ្មោះព្រះនារាយណ៍សឹងបែកចេញមក ពីពាក្យដើមថាវិស្ណុនឹងថា គេបូជាព្រះនារាយណ៍មើលទៅ ក៏ដូចជាមិនមែនព្រោះ មិនប្រាកដក្នុងទីណា ព្រះនារាយណ៍ជាជាងកសាងផ្ទះសំបែងជាដើមសោះ មានប្រទះតែថា ទេវបុត្រ១អង្គ ឈ្មោះវេសកម្មជាជាងរបស់ព្រះឥន្ទ្រ ដូចមានប្រាកដ ក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនរន្លើថា កាលព្រះឥន្ទ្រត្រូវការនឹងកសាងអ្វីរមែង ត្រាស់ប្រើព្រះវេសកម្មទេវបុត្រ រោយទៅកសាងជាដរាបសូម្បីពាក្យថាវេសកម្ម នេះក៏រមែងរែងបានសេចក្តីសមរឿងថា ការកសាងទីលំនៅឃើញដែរជាអ្នកកសាងទីលំនៅ ។ ដោយសេចក្តីសន្និដ្ឋានឃើញថា ដែរប្រើជាពិស្ណុការនោះគង់ឃ្លៀងក្លាយបែកពីពាក្យថាវេសកម្មនោះឯង ។

វិធីនេះនឹងពណ៌នាពីរបៀបបូជាពិស្ណុការ ឬ ព្រះវេសកម្មនោះតទៅជាងខ្មែរកាលនិងកសាងរបស់ដែលសំខាន់ ដូចយ៉ាងប្រាសាទវិហារ ផ្ទះ នឹងធ្វើទូកធំ ៗ ជាដើម មាន

ទំនៀមរៀបពលិការ បូជាព្រះពិស្ណុការ ដែលជាគ្រូសាងដើមដោយមានគតិកាន់មនុស្សលោកយើងនេះដែលនឹងចេះការវិជ្ជាជាងធ្វើសារពើកិច្ចការទាំងពួងអាស្រ័យដោយព្រះពិស្ណុការ ឬ ព្រះវេសកម្មប្រសិទ្ធិប្រសាច អោយមកធាតុកាលរកនឹងធ្វើអ្វីតែងបូជាគ្រូដើមនោះ សូម្បីអោយការនោះសម្រេចទៅដោយស្រួល កុំអោយមានគ្រោះថ្នាក់ហ៍ក្មេងមានស្លាប់ ឬ ក៏មុតដៃមុតជើង ជាដើមទំនៀមនេះក៏ចេញមកតែពីគតិព្រហ្មញ្ញសាសនានោះមកទៀត ។

ក៏ឯរបៀបរៀបគ្រឿងពលីការនោះ តាមក្បួនបូរាណលោកកំណត់ទុកជា៣ យ៉ាងផ្សេងគ្នាដោយធំនឹងតូចដូច្នេះ ៈ

## របៀបទី១

កាលនឹងធ្វើការធំមានប្រាសាទវិហារជាដើមត្រូវរៀបពលីការយ៉ាងធំកាលនោះគឺៈ -

រាន៥ ថ្នាក់១ មានរបស់ពលីការ ដាក់បូជានៅរាន នោះបាយសី៥ ថ្នាក់១គូ បាយសីប៉ាក់ឆាម១គូ ស្លាធម៌ ជប៤ ទឹករប៉ា៤ ទៀន៥ ធូប៥ ផ្កា៥ លាជ៥ សំពត់ សរក្រាលរាន៥ហត្ថ ប្រាក់៤បាត ឬ ក្រដាសមាសក្រដាសប្រាក់ក្បាលជ្រូក២នឹងមានភ្លេងពិណពាទ្យ១វង់ ។

ដល់វេលានឹងពលីការត្រូវយកគ្រឿងប្រដាប់ធ្វើការទាំងប៉ុន្មាននោះ មានដឹងដែកឈូសពន្លាកជាដើមមករៀបតាំងនៅមុខរានទេវតា ។ មេជាងផ្ដើមសូត្ររាភាធនា អញ្ជើញព្រះពិស្ណុការដ៏ជាគ្រូជាងនិងទេវតាដែលរក្សាទីកន្លែងដែលសាងនោះសូមអោយអញ្ជើញមកទទួលសេពសោយគ្រឿងពលីការ នឹងសូមអោយជួយប្រសិទ្ធិការ នេះអោយសម្រេចទៅដោយរួសរានកុំអោយមានគ្រោះថ្នាក់ មានមុតដៃមុតជើងជាដើមឡើយ ។ចប់ហើយអ្នកភ្លេងលេងភ្លេង៣ដង តាមទំនៀមជាសូរេច ។

## របៀបទី ២

កាលនឹងធ្វើការជាយ៉ាងកណ្តាល មិនតូចមិនធំត្រូវរៀបគ្រឿងពលីការយ៉ាងកណ្តាលមានពន្លកធំជាដើមដូច្នេះ :-

ភានទេវតាពថ្នាក់១ មានគ្រឿងពលីការគឺ : បាយសីប៉ាកឆាម៤ ស្លាធមិ៤ ជម៤ ទឹករបប់៤ ទៀន៥ ធូប៥ ផ្កា៥ លាជ៥ សំពត់សរ៥ហត្ថ នឹងប្រាក់៦ស្លឹង ឬ ក្រដាសមាស ក្រដាសប្រាក់ ។ នឹងមានសំពត់ជាតី២បន្ទាត់ ទំហំទទឹងបណ្តោយ១ហត្ថ ៤ជ្រុង គូរជាយន្តក្បាល ៤ បញ្ចុះអក្ខរសិទ្ធលីវលោធ្វើបានជាភាងហើយ អោយយកទៅបិតត្រង់ខ្លង់ នឹងមាត់តគ្នាខាងក្បាល១ ខាងកន្ទៀ១ ។ មេជាងត្រូវរៀបពលីការដូចពោលហើយ ខាងលើ។

## របៀបទី៣

កាលនឹងធ្វើផ្ទះគប្បីរៀបគ្រឿងពលីការដូច្នេះ : -

ភានទេវតាពថ្នាក់ ១មានគ្រឿងពលីការគឺ: បាយសីប៉ាកឆាម១គូ ស្លាធមិ១គូ ជម១គូ ទឹករបប់១គូ ទៀន៥ ធូប៥ ផ្កា៥ លាជ៥ សំពត់សរ៥ហត្ថ នឹងក្រដាសមាស ក្រដាសប្រាក់ ។ នឹងមានសំពត់ជាតីប្រមាណ១ហត្ថ៤ជ្រុង គូរយន្តក្បាល ៤ តែតម្រាខ្លះអោយគូរយន្តគ្រូច ។ អោយយកសំពត់យន្តនេះទៅបិទជាប់នឹងមេដំបូលស្រេចហើយ ទើបរៀបពលីការដូចពោលខាងលើ ។

អំពីនេះនឹងងអធិប្បាយអំពីសំពត់យ័ន្តបន្ថិចតទៅទៀត ដើម្បីនឹងបំបាត់ សេចក្តីសង្ស័យរបស់អ្នកខ្លះដែលអាចនឹងកើតសង្ស័យឡើងបានត្បិតមានក្បួនខ្លះ ថាអោយគូរយ័ន្តក្បាល៤ក្បួនខ្លះថាអោយគូរយ័ន្តក្រូចបញ្ចុះបាលីវត្តកបរិត្ត ដើម្បីការពារកុំអោយភ្លើងឆេះផ្ទះនោះ

ដោយអាងយករឿងក្នុងវដ្តកបរិត្តដែលថា កាលព្រះពុទ្ធអង្គនៅជាព្រះពោធិសត្វកើតជាកូនសត្វក្រួច វេលាមួយនោះមាតាបិតាមិននៅទទួលមានភ្លើងព្រៃឆេះមកដល់ទៀបសំបុក កូនក្រួចនោះភ័យក៏ភាវនាវដ្តកបរិត្តភ្លើងក៏រត់ទៅមិនបានឆេះដល់សំបុក ។

តាមសេចក្តីសន្និដ្ឋានថាយ័ន្តក្បាល៤នោះ ជារបស់ដើមមានមកអំពីបូរាណកាលដល់មកវេលា ដែលខ្មែរកាន់ព្រះពុទ្ធសាសនា សេរជាសពាញ្ញេស្រុកយើង ទើបកើតមានទំនៀមធ្វើយ័ន្តក្រួច១យ៉ាងឡើងទៀតដោយសេចក្តីនិយមដូចពោលហើយ ។

សំពត់នោះអ្នកខ្លះហៅថា « សំពត់ព្រះភូមិ»អ្នកខ្លះហៅថា« សំពត់ព្រះពិស្ណុ ការ» ។

ការពលីការព្រះពិស្ណុការនេះគេតែងធ្វើក្នុងវេលាដែលនឹងប្រុងរបស់ ដែលត្រូវធ្វើនេះគឺពីព្រឹក ត្រូវរៀបបូជាព្រះពិស្ណុការ ដល់ថ្ងៃរសៀល ត្រូវរៀបបូជាក្រុងពាលី ។ តែបើនឹងធ្វើក្នុងវេលាដែលប្រមូលគ្រឿងទព្វសម្ភារៈមកសព្វគ្រប់ហើយ ចាប់ផ្តើមនឹងឈូសសិតគ្រឿងនោះក៏ធ្វើពិធីពលីការព្រះពិស្ណុការតែម្តង ដល់វេលាឈូសសិតស្រេចហើយ នឹងប្រុងត្រូវសែនក្រុងពាលីឃើញទំនងជាងនឹងពលីការ ក្នុងថ្ងៃជាមួយគ្នា តែម្តងក្នុងវេលាប្រុងនោះឃើញមិនសូវសមព្រោះការបានធ្វើមកពាក់កណ្តាលហើយ ទើបមកធ្វើជាក្រោយបើនឹងមានគ្រោះថ្នាក់អ្វីអាចនឹងរួចទៅហើយក៏បានព្រះពិស្ណុការ នឹង ចាប់ទោសថាមិនអើពើនឹងបូជារំលឹកដល់លោកក៏បានខនេះនឹងគួរយ៉ាងណាអ្នករាប់អានទំនៀមទម្លាប់បូរាណគួរជាពិចារណាមើល ។

# ព្រះរាជពិធីគជេន្ទ្រាសុពាស្ថាន

«គឺពិធីប្រកក់ប្រសិទ្ធិសេនាទាហាននឹងដំរីសេះដែលជាព្រះរាជពាហនៈ» ព្រះរាជពិធីនេះ លើកលែកឈប់ធ្វើមកយូរហើយ តែក៏មិនបានបោះបង់ចោលទាំងអស់ នៅសល់ភាគខ្លះនៅមានធ្វើដល់សព្វថ្ងៃនេះហេតុនោះទើបគួរសើររើយកហេតុដែលកើតមានឡើង នឹង ហេតុដែលនាំអោយលើកលែងធ្វើពិធីនោះមកសំដែង ក្នុងទីនេះគ្រាន់ជាតួយ៉ាងដល់អ្នកដែលមិនធ្លាប់ដឹងដូចមានតទៅនេះ -

ព្រះរាជពិធីនេះ ដោយគំនិតដើមរបស់លោកអ្នកផ្តើមធ្វើឡើង ដើម្បីអោយ មហាជនដែលនៅក្រោមអំណាចមានសេចក្តីស្វាមីភ័ក្តិស្រឡាញ់ព្រះរាជាធិបតី ឬ ប្រជាធិបតីជាម្ចាស់ផែនដីរបស់ខ្លួន ហើយជាទីញញើតកោតក្រែងដល់សត្រូវនឹងជា សេរីសួស្តីដល់ព្រះនគរផង ហេតុនោះព្រះមហាក្សត្រអំពីបូរាណទើបនិយម ធ្វើមកជាច្រើនប្រទេសផងគ្នាប្រទេសកម្ពុជាយើងអំពីបូរាណកាលក៏ធ្លាប់ធ្វើហើយ មកដែរតាមដែលពួចាស់ទុំនិយាយមកថាទើបនឹងឈប់ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចនរោត្តមបរមទេវាវតារ « ព្រះសុវណ្ណកោដ្ឋ»។ដោយសារហេតុដែលមានព្រះរាជពិធីនេះអាស្រ័យរឿង « ទីឃាវុជាតក»ដែលមានបកក្នុងគម្ពីរនិបាតជាតកជារឿងដែលព្រះបរមសាស្តាទ្រង់នាំមកត្រាស់សំដែង អោយតួយ៉ាងដើម្បីផ្សះផ្សាពួកភិក្ខុសង្ឃដែលរឹកវរបែកសាមគ្គីគ្នាមានសេចក្តីសង្វេបដូច្នេះថាកាលទីឃាវុកុមារនៅក្នុងព្រះឧទរនៃព្រះមាតាបិតាចេះតែមានប្រាថ្នាចង់ទតចតុរង្គសេនា នឹងចង់សោយទឹកដែលលាងជិរះព្រះខ័នព្រះបាទពីឃីតិកោសលបានធ្វើឧបាយកល១យ៉ាង អោយគ្រះបាទព្រហ្មទត្តចាត់ការរៀបក្បួនចតុរង្គសេនា

នឹងងលាងជំរះព្រះខ័នព្រះនាងក៏បានឃើញក្បួនចតុរង្គសេនានឹងបានសោយទឹកជំរះព្រះខ័នសោយដូចប្រាថ្នា ។

ដោយហេតុមានសេចក្ដីចែងនៅក្នុងទីឃាវុជាតក ដូច្នេះព្រះមហាក្សត្រអំពីបូរាណទើបនិយមការប្រជុំចតុរង្គសេនាមករៀបហែរជាក្បួនទ័ព នឹងការលាងជំរះព្រះខ័នយកទឹកចែកគ្នាផឹកដោយសំគាល់ថាជាកិច្ចអោយកើតសេរីសួស្ដីជ័យមង្គល នឹង អោយចំរើនពាក្យសត្យូវម្ចាប់ញៀវវេរា មិនអោយមានផ្ដួចគិតប្រទុស្តរាយគ្នា នូវគ្នាដូចយ៉ាងព្រះបាទព្រហ្មទត្តនឹងទីឃាវុកុមារ ។ របៀបក្បួនចតុរង្គសេនានោះដូចម្ដេចខ្លះក្នុងរឿងទីឃាវុជាតកក៏មិនអានពោលទុកដោយល្អិតដែរ ក្នុងព្រះវិន័យព្រះពុទ្ធអង្គទ្រង់បញ្ញត្តិសិក្ខាបទ១ថា «ភិក្ខុឯណាទៅមើលក្បួនចតុរង្គសេនាភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ»តែបៀបក្បួនចតុរង្គសេនានោះដូចម្ដេចខ្លះក៏គ្មានពោលទុកដោយពិស្ដារដែលមានតែពាក្យញែកថាសេនាដំរី១ពួកសេនាសេះ១ពួកសេនារថ១ពួកសេនាដើរជើង១ពួកប៉ុណ្ណោះ ។ ពោលតាមទំនៀមទម្លាប់ ដែលធ្វើក្នុងប្រទេសកម្ពុជានេះកាលជិតដល់រដូវធ្វើពិធីនេះហើយសេនាបតីក្នុងក្រុងមានចុតហ្មាយ បង្គាប់ទៅចៅហ្វាយស្រុក ចៅហ្វាយខែត្រនឹងប្រទេសរាជទាំងឡាយអោយកេណ្ឌសេនាទាហានចាស់ៗដែលធ្លាប់ធ្វើសេនាទាហានមកហើយ នឹង ប្រុសកម្លោះដែលមានលក្ខណៈជាទាហាន នឹងមានថ្វី ដៃពូកែ គឺពូកែគុន ពូកែដាល់ ពូកែចំបាប់នឹងសាច់ស្វិតនឹងកេណ្ឌមនុស្សពល អោយមកជួបជុំក្នុងក្រុងទាំងខ្លួនចៅហ្វាយស្រុកចៅហ្វាយខែត្រឬប្រទេសរាជ « អ្នកគ្រប់គ្រងស្រុកចំណុះ » ព្រមទាំងអ្នករាជការរងៗចុះទៅក៏ត្រូវមកជួបជុំត្រង់ក្នុងឱកាសជាមួយគ្នានោះចំណែកឯដំរីសេះគោបើរបស់ព្រះរាជទ្រព្យមាន នឹងគ្រប់គ្រងសេនាបតី ទាហានជើងគោក ត្រូវចេញដីកាចាត់កេណ្ឌ យកក្នុងស្រុកខ្លះក្នុងខែត្រក្រៅ ខ្លះមកបំពេញអោយខាងរាងតែបាន ល្មមធួន ការគ្មានកំណត់ ប្រមាណចំនួនជា

ដាច់ខាតទេស្រេចហើយតែរាជការចិញ្ចឹមបម្រុងទុកនឹងកេរ្យកេណ្ឌមកបានប៉ុន្មាន ក៏ធ្វើប៉ុណ្ណោះ ទៅតែតាមសេចក្ដីបំណងផ្ដើម ត្រូវការអោយបានចំនួនច្រើនជាបំផុត បានច្រើនប៉ុន្មាន ក៏តែជាកិត្តិយសប៉ុណ្ណោះ គ្រឿងអាវុធយុទ្ធភណ្ឌនឹងទង់ផ្សេងៗ ត្រូវប្រើរបស់ព្រះរាជទ្រព្យ ។ កាលសេនាទាហាន នឹងសត្វពាហនៈអំបាលនោះមកជួបជុំហើយ ដល់ថ្ងៃនឹងធ្វើព្រះរាជ ពិធីត្រូវសេនាបតីក្រសួងយុទ្ធនាធិការ ជាអធិបតីចាត់រៀបជាក្បួនបែបយ៉ាងក្បួនសឹកបូរាណ ។

របៀបក្បួនចតុរង្គសេនានោះ ទោះបីលើកលែងធ្វើមកជាអង្វែងហើយក៏ពិត តែមិនបែនដល់ទៅផុតរលត់គ្មានអ្នកណាដឹងដំណើរទំនងសោះនោះក៏ទេដែរ នៅមានមនុស្សជាច្រើនក្នុងសម័យនេះដែលធ្លាប់ឮចាស់ទុំនិយាយត ៗ មកខ្លះដែរ មិនតែប៉ុណ្ណោះនៅមានរូបភាពដែលព្រះមហាក្សត្របូរាណទ្រង់អោយធ្លាប់ទុកនៅប្រាសាទបាយ័នក្រុងនគរធំនឹងប្រាសាទនគរវត្តត្រង់របៀបខាងត្បូងល្មមទុកជាគំរូបានហើយ តែក្បួនចតុរង្គសេនា ដែលមានពោលក្នុងរឿងទីយាវូជាតកហើយនឹងក្បួនតុរង្គសេនា ដែលនិយមធ្វើក្នុងប្រទេសកម្ពុជានេះ គង់ជាមានរបៀបខុសគ្នាខ្លះមិនខានដូចគ្នាតែត្រង់មានសេនា៤ពួកប៉ុណ្ណោះ ។

ក្បួនចតុរង្គសេនានោះពោលតែឈ្មោះគឺក្បួនដំរី១ពួក ក្បួនសេះ១ពួក ក្បួនរថ១ ពួក ក្បួនពលថ្មើជើង១ពួក ក្នុង១ពួក ត្រូវការអោយមានចំនួនច្រើនជាទីបំផុត តែក្នុងទីនេះសូមពោលដោយសង្ខេបគ្រាន់តែតួយ៉ាងប៉ុណ្ណោះ ។

ប្រយោជន៍ដែលលោកបង្កើតអោយមានព្រះរាជពិធីនេះឡើង ពោលដោយសង្ខេបក៏ដើម្បីទំនុកបម្រុងសេនា ទាហានជើងគោក នឹងសត្វពាហនៈ ដែលសម្រាប់ប្រើការក្នុងសង្គ្រាមអោយមានចំនួនច្រើនឡើង នឹងអោយខ្លាំងពូកែឡើងល្មមគ្រប់គ្រាន់ នឹងរក្សាស្រុកទេសបាន

នឹងដើម្បីដឹកនាំចិត្តសេនាទាហានទាំងនោះអោយក្លៀវក្លាឡើង អោយជាទីញកោតក្រែងដល់ប្រទេសដទៃ នឹងពួកប្រទេសរាជគឺស្រុក ចំណុះរបស់ខ្លួន ។

ការដែលអោយទទួលព្រះរាជទានទឹកព្រះពិភទ្ធសច្ចានោះ ដើម្បីអោយមានសេចក្ដីស្វាមីភក្ដិស្មោះត្រង់នឹងម្ចាស់ផែនដីរបស់ខ្លួន កាលធ្វើបានដូច្នេះហើយឈ្មោះថា ជាសេរីសួស្ដីជ័យមង្គលដល់នគរ ។

កាលដល់ថ្ងៃដែលនឹងធ្វើពិធីនោះវេលាព្រឹកក្បួនចតុរង្គសេនា ក៏លើកព្យុហយាត្រាការមុខព្រះពន្លាសឹងតាំងនៅខាងមុខព្រះបរមព្រះរាជវាំង ព្រះករុណាអម្ចាស់ជីវិតលើត្បូង ទ្រង់គង់លើព្រះពន្លានោះ ចន្ទច្ឆាយាចាំទតជាមួយនឹងប្រទេសរាជ នឹងមន្ត្រីខ្លះ ដែលមិនបាន ចូលក្បួនហែកាលហែផុតព្រះពន្លាទៅហើយ មានគើយ១ខ្ពស់មានព្រាហ្មណ៍១ពួក ឈរលើគើយនោះចាំរលាស់ទឹកមន្តបង្កក់ប្រសិទ្ធសត្វពាហនៈ នឹងសេនាទាហានអំបាលនោះតាំងពីដើមក្បួនរហូតដល់ផុតក្បួន ។

## លរស្នាដៃទាហាន ១៣

កាលក្បួនចេញទៅផុតឆ្ងាយបន្តិចហើយ ពួកទាហានខ្លះដែលមានស្នាដៃជិះសត្វពាហនៈត្រូវបត់ត្រឡប់មកវិញបរបំបោលថ្វាយព្រះករុណាទត គឺអ្នកពូកែជិះក្របីក៏បំបោលក្របីមកម្ដងមួយៗ ទាហានខ្លះពូកែដល់ទៅជិះឈរបាន ក៏ឈរបំបោលមក ។ អ្នកពូកែជិះសេះក៏បំបោលសេះមកអ្នកពូកែជិះដំរី ក៏បំបោលដំរីមក តែដំរីនោះកាលមកដល់ក្បាលទីហើយមានបរប្រជល់រាង ដែលគេធ្វើបំរុងទុកនៅទីនោះផង ដើម្បីបង្ហាត់ដំរីអោយចេះជល់ ចេះចាក់ស្ទាត់

ជាប្រយោជន៍ក្នុងការចូលធ្វើសង្គ្រាមដែលត្រូវប្រជល់ដំរីគ្នានឹង ដំរីសឹកគេអាចជល់យកជ័យជំនះបាន ។

កាលបរសត្វគ្រប់អស់ហើយព្រះករុណាស្តេចយាងចូលក្នុងព្រះបរមរាជវាំងក្បួនហែក៏លើកហែ ។

ដល់វេលារសៀលសេនាបតីទាហានជើងគោក ត្រូវជ្រើសរើសសេនាទាហានអំបាលនោះដែលមានស្នាដៃខ្លាំងពូកែក្នុងការលេងគុនដាល់-ចំបាប់មកផ្លូវហើយអោយទៅលេងថ្វាយព្រះករុណាទតព្រះនេត្រនៅទីព្រះលានក្នុងព្រះបររមព្រះរាជវាំងរួចហើយទ្រង់ព្រះរាជទានប្រាក់រង្វាន់ដល់អ្នកលេងទាំងនោះទាំងអ្នកឈ្នះទាំងអ្នកចាញ់ទាំងអ្នកស្មើគ្នាតែអ្នកជិះបានរង្វាន់ច្រើនជាងធ្វើតែដូច្នេះគ្រប់ ៣ ថ្ងៃ ដល់ថ្ងៃទី៤វេលាព្រឹកប្រជុំសេនាទាហាននឹងប្រទេសរាជអំបាលនោះអោយទទួលព្រះរាជទានទឹក ព្រះពិភទ្ធសច្ចារបៀបទទួលព្រះរាជទានទឹក ព្រះពិភទ្ធសច្ចានោះ នឹងមានពោលក្នុងលំដាប់តទៅ: -

ព្រះរាជពិធីគជេន្ទ្រាសុពាស្ថាននេះ តាមសេចក្តីនិយមត្រូវធ្វើរាល់ឆ្នាំ គឺក្នុង១ឆ្នាំធ្វើម្តងតែព្រះមហាក្សត្រទាំងឡាយដែលជាអ្នកគ្រប់គ្រងប្រទេសនោះ រមែងធ្លាក់នៅក្នុងអំណាចនៃគតិធម្មតាគឺជួនកាលមានតេជានុភាពរុងរឿងជួនកាលអាប់ឱនអំណាចថាសពហេតុនោះទើបមិនអាចនឹងបំពេញកិច្ចនោះអោយបរិបូណ៌តាមនិយមដើមបានមកក្នុងសម័យនេះគ្រឿងយុទ្ធភណ្ឌជាដើមបានប្រែប្រួលត្រឡប់ប្រើរបស់ដ៏ទៃជំនួសទៅហើយរបស់ចាស់នោះជារបស់កន្លង កាលកន្លងសម័យមកហើយប្រើការមិនបានទើបសម្រេចថា ត្រូវលើកលែងធ្វើនៅមានតែត្រឹមការប្រឡងដាល់ប្រឡងចំបាប់ដែលជាភាគ១ នៃការបង្វឹកសេនាទាហាហើយ រួមចូលក្នុងពិធីចូលឆ្នាំបានធ្វើរៀងរាបដ៏រាបមក ដល់រដ្ឋកាលបច្ចុប្បន្ន តែការប្រឡងដាល់ ប្រឡងចំបាប់នោះ

ក្នុងជាន់ដើមមានមនុស្សនិយម ច្រើនបានធ្វើកិច្ចលក្ខណៈមែនៗគឺអ្នកប្រឡងសុទ្ធតែបានរៀន បានហាត់ស្ទាត់គ្រប់គ្នាការលេងក៏មុខគួរអោយមើល អំណើសយូរមកហើយការនោះក៏រៀវរោយ ចុះមកទៀតមានមនុស្សជាច្រើន ដែលមិនបានហាត់អោយត្រឹមត្រូវតាមរបៀបតែដល់អំណាច សេចក្តីលោភចង់បានបំណាច់រង្វាន់ដែលទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន ដល់ពេលលេងក៏ទៅ សូមចុះឈ្មោះលេងការលេងបែបនេះ ទ្រង់ឈ្វេងយល់មិនមានប្រយោជន៍អ្វីដល់ព្រះនគរទើប ទើបទ្រង់ព្រះមេត្តាប្រោសអោយលើកលែងតាំងពី ព.ស ២៤៧៥ គ.ស ១៩៣២ មក ។ នៅ មានតែព្រះរាជពិធីព្រះពិភទ្ធសច្ចាដូចជាជូនជានឹងបានពោលតទៅ ។

# ព្រះរាជពិធីពិភទ្ធសច្ចា

# «គឺផឹកទឹកសំបថលាងអាវុធ»

ព្រះរាជពិធីនេះធ្វើតាមលំអាន ដែលពោលក្នុងរឿងទីឃាវុជាតកដែលបានសសំដែងមក ហើយនោះឯងដូច្នេះត្រូវយល់ថារឿងនេះជាខត្តិយប្រវេណីមានមកអំពីបូរាណកាល ។ និយាយ តាមទំនៀមក្នុងកម្ពុជានេះ គឺដំបូងអោយយកទឹកទៅតាំងអោយព្រះសង្ឃចំរើនព្រះពុទ្ធមន្ត៣ថ្ងៃ ជាមុនវេលាដែលនឹងផឹកមានចៅ ភ្នាក់ងារសូត្រពាក្យសំបថនឹងយកសាស្ត្រាអាវុធទៅក្លូវក្នុងទឹក ពុទ្ធមន្តនោះរួចទើបចែកអោយផឹក ។ ការដែលដាក់អោយព្រះសង្ឃចំរើនពុទ្ធមន្តក៏ដើម្បីចំរើន សេរីសួស្តីដល់អ្នកផឹកការដែលសូត្រពាក្យសំបថដាក់ ក៏ដើម្បីចងចិត្តអ្នកផឹកអោយតាំងនៅក្នុង

សេចក្តីសុច្ចរិតស្លូតត្រង់ ដ៏រាបទៅកុំអោយប្រែចិត្តក្បត់ប្រទុស្តរាយធ្វើតែពីរយ៉ាងនេះឃើញថាល្អមគួរការហើយតែហេតុម្តេចទើបយកសាស្ត្រាវុធមកក្លូវអោយផឹកទៀត ខនេះឃើញថាកើតដោយវិធីរបស់ពួកខត្តិយឬហៅថាក្សត្រ ដែលរាប់ថាជាជាតិអ្នកចំបាំងជាតិក្សត្រនេះមិនបានចិញ្ចឹមជីវិតដោយការកសិកម្ម ឬ ពាណិជ្ជកម្មដូចមនុស្សទាំងពួងទេ ជាអ្នកចិញ្ចឹមដោយកំលាំងសាស្ត្រាវុធនិយាយដោយសង្ខេប គឺជាអ្នកយេរកាន់អាវុធ ចាំការពារស្រុកទេសរបស់ខ្លួនមិនអោយសត្រូវខាងក្នុងនឹងខាងក្រៅកើតឡើងនឹងសម្រាប់ប្រទេសដ៏ទៃ ដែលប្រព្រឹត្តខុសគន្លងធម៌ឬច្បាប់របស់ក្សត្រនោះខ្លះដោយពេលដោយ សម័យដែលមានហេតុដូច្នេះកើតឡើងដោយហេតុនេះពួកក្សត្រទើបជាអ្នកសន្សំគ្រឿងសាស្ត្រាវុធ ដែលល្អវិសេសទុកសម្រាប់អង្គរបស់ខ្លះក៏យកមកទុកជិតរង្គសម្រាប់ការពារអង្គជាគ្រឿងធ្វើអោយក្សត្រនោះរុងរឿងសង្ហាស្គមដូចពាក្យបាលីថាខត្តិយសន្នោតបតិក្សត្រដែលទ្រង់គ្រឿងអាវុធ រមែងសង្ហាដូច្នេះរមែងប្រកាន់ថាអាវុធនេះល្អមានគុណវិសេសកាលមានហេតុអ្វី ដែលគួរនាំមកប្រកបអោយឃើញជាអស្ចារ្យក៏សន្មត់ថាអាវុធនោះមានបារមីរក្សាជាគ្រឿងជួយកំលាំងខ្លួន ដែលនឹងប្រហារកាច់កិនសត្រូវអោយបាននៅក្នុងអំណាចរបស់ខ្លួនហេតុនោះក្សត្រអំពីបូរាណ ទើបយកអាវុធមកក្លូវទឹកអោយអ្នកនៅក្រោមអំណាចនឹងធ្វើទោសដល់អ្នកគិតក្បត់ដូចពោលហើយដូច្នេះត្រូវយល់ថាការផឹកទឹកលាងអាវុធនេះជាទំនៀមរបស់អ្នកចំបាំងគឺក្សត្រមិនមែនជាទំនៀមរបស់ព្រាហ្មណ៍តែបើព្រាហ្មណ៍ បានធ្វើជាព្រះរាជាក៏ប្រហែលជាកាន់ទំនៀមក្សត្រនេះដែរ ។

ការផឹកទឹកលាងអាវុធនេះក្សត្រអំពីបូរាណលោកកាន់ថាជាសេរីសួស្តីជ័យមង្គលដល់អ្នកផឹកហាក់បីដូចជាផឹកទឹកមន្តដូចមានប្រាកដក្នុងទីយាវុធជាតកដូចមានពោលមកហើយហេតុនោះ

ទើបមាននៅទំនៀមមកដល់សម័យនេះ។ បុគ្គលជំពូកណាខ្លះដែលត្រូវផឹកទឹកពិភទ្ទសច្ចាតាមខត្តិយរាជប្រវេសីនៃប្រទេសកម្ពុជានេះគឺព្រះរាជវង្សានុវង្សទាំងក្សត្រាទាំងក្សត្រីមន្ត្រីនឹងអ្នករាជការគ្រប់ក្រុមគ្រប់ក្រសួងព្រមទាំងពួកខុនណាង«គឺភរិយារបស់មន្ត្រីធំៗ»នឹងសត្រីខ្ញុំរាជការក្នុងព្រះបរមរាជវាំងអំបាលនេះត្រូវផឹកទាំងអស់រៀវតែព្រះជាម្ចាស់ផែនដីនោះ មិនទ្រង់សោយផងទេតែបើនឹងទ្រង់សោយជាការសំដែងរិទ្ធព្រះហឫទ័យអោយឃើញថាទ្រង់ស្ម័គ្រត្រង់នឹងព្រះរាជវង្សានុវង្សរហូតដល់ប្រជារាស្ត្រផងក៏បាន ។ ការផឹកទឹកពិភទ្ទសច្ចានេះកំណត់ផឹកក្នុងពេលណាខ្លះ ? និយាយតាមទំនៀមបុរាណលោកកំណត់អោយផឹកក្នុងឱកាសចូលឆ្នាំថ្មី ដែលមានប្រជុំចតុរង្គសេនានេះម្តងក្នុងវេលាដែលមានពិធីរាជាភិសេកម្តងក្នុងវេលាដែលមានមនុស្សចូលធ្វើទាហានថ្មីម្តងក្នុងវេលារាជការមន្ត្រីថ្មីម្តងក្នុងកាលដែលពួកបច្ចាមិត្តរត់ចូលមកពឹងបុណ្យបារមីម្តង ។

យ៉ាងទី ១ : អំពីដើមមានព្រះរាជកំណត់អោយផឹកនៅថ្ងៃ៣កើតខែចេត្រជានិច្ចរាល់ឆ្នាំទៅហេតុដែលលោកកំណត់ខែចេត្រនោះ តាមសេចក្តីសន្និដ្ឋានថាក្នុងសម័យព្រេងនាយឯណោះនិយមថា ខែចេត្រចូលឆ្នាំនេះ ជាខែដែលមាននក្ខត្តឫក្សមហាជនគ្រប់ជាន់ថ្នាក់ រាប់តាំងពីក្សត្រចុះទៅរមែងឈប់សំរាកលែងធ្វើការងារទាំងពួងជាឱកាសសមជួបជុំទទួលទឹកពិភទ្ទសច្ចា ដោយព្រមព្រៀងគ្នាបានវេលាក្រោយមកកំណត់អោយផឹករួមគ្នាក្នុងពិធីបុណ្យចូលឆ្នាំតែមិនដឹងចាប់ផ្លាស់ពីត្រឹមរជ្ជកាលណាមកលុះមកដល់ពុទ្ធសករាជ២៤៤៧ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចស៊ីសុវត្ថិចមចក្រពង្ស ទ្រង់ព្រះមេត្តាប្រោសអោយទទួលទឹកពិភទ្ទសច្ចានោះនៅថ្ងៃហើយបុណ្យចំរើនព្រះជន្មវង្សាព្រោះសម័យនោះ ពិធីបុណ្យចំរើនព្រះជន្មវស្សាជាពិធីបុណ្យធំកំណត់ធ្វើ៥ថ្ងៃក៏មាន ៧ ថ្ងៃ ក៏មានពួកមន្ត្រីទាំងក្នុងស្រុក ទាំងក្នុងខែត្រក្រៅ គ្រប់ខែត្ររមែងមកជួបជុំព្រមដើម្បីថ្វាយជ័យមង្គល ហើយមានធ្វើរហូតមកដល់សព្វថ្ងៃនេះ « ព.ស ២៤៧៧ » ។

យ៉ាងទី ២ ៖ ក្នុងវេលាធ្វើពិធីភិសេក ផ្លាស់ព្រះរាជាថ្មីនោះមានមានព្រះរាជកាំណត់អោយអ្នករាជការទាំងពួងទទួលទឹកពិភទ្ទសច្ចាដែរ ដើម្បីអោយអ្នករាជការទាំងនោះតាំងចិត្តស្លូតត្រង់ស្វាមីភក្តិនឹងម្ចាស់ជីវិតថ្មីនោះ ។

យ៉ាងទី ៣ ៖ ក្នុងវេលាដែលមានទាហានថ្មីមកចូលធ្វើរាជការទោះក្នុងវេលាដែលស្រុកសាន្តត្រានក្តីនោះក្នុងវេលាដែលស្រុកកើតសឹកសង្គ្រាមក្តី ត្រូវអោយទទួលទឹកពិភទ្ទសច្ចាជាមុនសិនទើបប្រគល់គ្រឿងសាស្ត្រាវុធអោយកាន់ ។

យ៉ាងទី ៤ ៖ ក្នុងវេលាដែលតាំងរាជបុរសអោយមានយសសក្តិពេញជាមន្ត្រីតាំងពិធីហ្នឹងជាដើមទៅមានព្រះរាជប្រកាសកំណត់អោយទទួលទឹកពិភទ្ទសច្ចាដែរ ។

យ៉ាងទី ៥ ៖ ក្នុងវេលាដែលសឹកសង្គ្រាមនឹងប្រទេសឯណាមួយហើយមានទាហានជាដើមក្នុងប្រទេសនោះរត់ចូលមកពឹងបុណ្យបារមី ជ្រកក្រោមម្លប់ពោធិសម្ភារនោះត្រូវបង្គាប់អោយទទួលទឹកពិភទ្ទសច្ចាដែរ ។

របៀបដែលទទួលទឹកពិភទ្ទសច្ចា សម្រាប់ប្រចាំឆ្នាំយ៉ាងសម័យនេះក្រុមព្រះរាជមន្ទីរជាភ្នាក់ងារចាត់បង្គាប់អោយរៀបគឺក្រុមព្រះក្រាលត្រូវក្រាលព្រះសុច្ចនីនឹងព្រំតាមទីកន្លែងក្រុមព្រះឃ្លាំងបនីវ័តណ៍ត្រូវរៀបដាក់ក្អមទឹក២០ ថាំងទឹក២ ទឹករអប់១គូ ស្លាធម៌៥ ទៀន៥ ធូប៥ ក្រុមសង្ឃការីត្រូវនិមន្តព្រះសង្ឃមកចំរើនពុទ្ធមន្តប្រសិទ្ធិទឹករស់វារៈ៣ថ្ងៃ នៅក្នុងព្រះវិហារ ។

ដល់ថ្ងៃដែលនឹងទទួលទឹកពិភទ្ទសច្ចាវេលាម៉ោង៨ព្រឹកក្រុមបាគូបុរោហិតនឹងក្រុមព្រះរាជបណ្ឌិតហែរព្រះពុទ្ធរូប ព្រះត្រៃបិតក ព្រះខ័នរាជ ព្រះលំពែង ត្រីសព្រួញគ្រាប់កាំភ្លើងក្រុមមហាតលិកអញ្ជើញព្រះសែងក្របី៨ ព្រះសែងដាវ២ ព្រះទម្រង់អគ្គី២ក្រុម ព្រះសែងធ្នូអញ្ជើញព្រះសែងរាស្វលី២ ព្រះសែងង៉ាវ២ មកប្រជុំនៅព្រះវិហារ ។

កាលអស់លោកសេនាបតីនឹងមន្ត្រីទាំងពួងអញ្ជើញទៅ ជួបជុំព្រមហើយក្រុមបុរោហិតស្វូត្រវេរតាមតម្រាព្រាហ្មណ៍រួចហើយ យកគ្រឿងសាស្ត្រាវុធទាំងពួងដែលពោលហើយខាងលើក្លូរក្នុងថ្លាងក្អមទឹកនៅទីចំពោះព្រះភ័ក្រព្រះរាជវង្សានុវង្សនឹងមន្ត្រីទាំងអស់ ។ រួចហើយក្រុមព្រះរាជនិពន្ធស្វូត្រសច្ចាធិស្ឋាន ថ្វាយព្រះរាជវង្សានុវង្ស អោយមានបន្ទូលតាម។រួចក្រុមព្រះអាល័ក្ខណ៍ស្វូត្រសច្ចាធិស្ឋានជូនលោកសេនាបតីក្រុមព្រះអាល័ក្ខណ៍ ម្នាក់ទៀតស្វូត្រជូនមន្ត្រីធំតូចទាំងអស់មន្ត្រីទាំងនោះទទួលថាតាមដ៏រាបដល់ចប់ ។ លំដាប់នោះក្រុមព្រះរាជមន្ទីរយកផ្តិលមាសដាក់ទឹកពិភទ្ធសច្ចានោះថ្វាយព្រះរាជវង្សានុវង្ស នឹងលោកសេនាបតី យកផ្តិលថោងក្រឡៃមាសនិងផ្តិលប្រាក់សិតទឹកនោះជូនអស់លោកមន្ត្រីទទួលសោយនឹងពិសារបន្តិច១ម្នាក់វៀងទៅ ។

វេលារសៀលចៅភ្នាក់ងារហៃទឹក ពិភទ្ធសច្ចាដែលបម្រុងទុកទៅដាក់ក្នុងព្រះទីនាំសុភារមរិន្ទក្នុងព្រះបរមរាជវាំងដើម្បីថ្វាយព្រះរាជវង្សានុវង្សក្សត្រសោយនឹងជូនខ្ញុំរាជការស្ត្រីទទួលព្រះរាជទានតទៅមុខមានបណ្ឌិតនិមន្តព្រះពុទ្ធរូបទៅតាំងដំកល់លើតុគ្រានោះ នឹងជួបជុំដោយព្រះវង្សានុវង្សក្សត្រី នឹងខ្ញុំរាជការស្ត្រីជំទាវខុនណាងនឹងចៅ ភ្នាក់ងារក្រសួងព្រះបរមរាជវាំងមានសេនាបតីឬភ្ញូឈ្លួយអ្នកដំណាងជាដើម ដែលមានទាក់ទាមដោយកិច្ចនេះ។ពួកព្រះរាជវង្សានុវង្សក្សត្រីថ្វាយបង្គំព្រះតាំងព្រះហទ័យស្វាមីភក្តិ នឹងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងហើយចៅភ្នាក់ងារក្រុមវាំងត្រូវសិតទឹកថ្វាយសោយដោយមិនបាច់ចាំស្វូត្រសច្ចាធិស្ឋាន ក្រៅអំពីនោះត្រូវក្រុមព្រះអាល័ក្ខណ៍ស្វូត្រសច្ចាធិស្ឋានជូនហើយចៅភ្នាក់ងារក្រុមវាំងត្រូវសិតទឹកជូនខ្ញុំរាជការស្ត្រីចៅភ្នាក់ងារក្រុមព្រះរាជមន្ទីរត្រូវសិតទឹកជូនទៅជំទាវខុនណាងទាំងពួងពិសារ ។

ប៉ុណ្ណេះឈ្មោះថា ស្រេចកិច្ចទទួលទឹកពិភទ្ធសច្ចាហើយ ។

# បទពំនោល

សាស្ត្រាពីព្រះឥន្ទ្រា ទុកជាតិជា សណ្ដាប់ទម្លាប់ច្បាប់ច្បង សិទ្ធិការិយពិស្ដារដ៏កន្លង ទោះបីអ្នកផង ចង់ដឹងអស់បូពិនិរមិត្រ ។ ព្រះចន្ទ្រនូវ ព្រះអាទិត្យ កេតុរាហូស្ថិត នាវាពពកមេឃា ។ រន្ទះសូរសែងមហិមា ផ្លេកបន្ទោលវេហាស៍ បហាជន្ទនន្ទចរចុះ ។ គិរីបពត៌ធ្លាយធ្លុះ បាក់បែកដីលុះរលំរណ្ដុំខ្ទរខ្ទារ ។ ប្រថពីប្រេះបែកអស្ចារ្យ ទ្រោមទ្រុឌស្រុត ស្រាលរលំរលាយខ្ទេចខ្ទាត ។ ទោះសត្វទ្វេបាទចតុបាទ ឃើញពុំត្រូវខ្នាត អាស្រូវហើយត្រូវកាចក្រៃ ទក្សិណា និរតីឯងឮ បស្ចិមសោតនៃឧត្តរ ពុំបរិបូណ៌ឡើយ ។ ទិសបូពិឃើនយូរឯងហើយ អគ្នេយ៍ជាត្រើយពីងពាក់សំណាក់ ថ្កើនថ្កល់ ។ ទិសទីពាយ៍សានសោតសល់ ចំរើនមង្គលមកដល់កូនចៅផងជា ។ ឯទិសពាយ័ព្យនោះណា ពុំសូវកាចជាមើលនាលំនៅក្នុងក្រៅ ។ លក្ខិណាចរិយាឥតសៅ ចរចូលមកនៅពុំមានភ័យភិតឡើយណា ។ ត្រូវបក្សយាមពារវេលា មើលមុខមាត់វា ប្រែប្រាណឆ្ពោះថ្កាននៅឯណា ។ អោយរៀបប្រដាប់បូជា គ្រឿងគន្ធមាលា ប្រដាប់នូវផ្កាច្រាលសរ(១៤) ។ សំពត់ទាំងផ្ទត់សីងល្អឆ្វេងស្ដាំ ហើយយកគន្ធីរអប់ទឹកពីរផង ។ មាសប្រាក់ភ្លៅឆ្លាក់កែវកង ចង់ស្លាចង់រងកោក ពានសិងមានធូបទៀន ។ ចំណីបង្អែមទៅសែននៅទីនៅដែន ជុំញាតិសណ្ដានចាស់ទុំ ។ អោយសែបូជាទឹកឃ្មុំ សូត្រសែបរអាគមបន្សំប្រណោម្យសិទ្ធិសា «ឧមឥន្ទ្រានារាយណ៍សី គន្ធពួបរិវាយគ្រប់ព្យញ្ជនិស្វាយ» ។ ទោះនិមិត្រសូរ្យគ្រាសទាំងឡាយ ព្រះរាហ៍ខ្វល់ខ្វាយ ទៅចាប់ព្រះសូរ្យលេបណា ។ ងងិតទាំងផ្ទៃមេឃា ដូចយប់សោះសា អ្នកធំក្រេវក្រោធផងគ្នា ។ ជាទោសទាស់ទែងវាចា

នឹងបង់នគរា អោយរៀបបូជាជាធំ ។ ភ្លេងភ្លាត់សោតស្ទាត់ប្រគំ អោយសង់រារ ស្រម សោតសមបូជានូវពិណា ។ សូត្រហោមពិធីអាចិណ្ណ ធីបួសពិធិន ពិធីត បក្កោបារមី ។ អោយប្រកក់អស់ហោមស្តុតី ហើយសង្ឃការី និមន្តអស់តម្លែងសង្ឃ ។ គ្រប់វត្តសោតស្ទាត់ផ្ចិតផ្ចង់ បានបួសគ្រប់អង្គ ចំរើនទិព្វមន្តរម្ងាប់ ។ និមិត្រយល់ផ្កាយ ពុំគាប់ដុសកន្ទុយ ឆាប់ប្រញាប់កន្ទុយខ្ពស់ឡើង ។ ក្រហមដូចរងើកភ្លើង ក្សត្រពីរ កន្ទ្រើង ចចើងដណ្តើមគេជដៃ ។ ទោះកន្ទុយ ចុះក្រោមនូវប្រល័យ ខុនណាងចៅ ប្រុសស្រីនិងមរណៈពុំលែងនឹងកើត កង្វល់ទាស់ទែង ឧត្បាទវ៍នោះឯង អោយរៀប បូជាហោងណា ។ទោះផ្កាយនៅ បូពិទិសា រស្មីជ្រះថ្លា បូកល្អប្រសើរប្រាយប្រុះ ។ សិងមាន រាជទូតពីរភ្លោះ ថ្ងៃប្រាំចំពោះ នោះនឹងមកដល់វឹងឆាប់ ។ ទោះផ្កាយព្រោងព្រាយគួរគាប់ នៅទិសពាយ័ព្យ រស្មីល្អៗជ្រះថ្លា។ថ្ងៃប្រាំថ្ងៃនោះនៃនឹងឮ ពតិមានអងអឺ មានក្មេងអ្នកពន្លក ។ ពុំនោះ រាជទូតចូលមក ប្រសើរនឹងរក ស្រដីពិរោះសោះសា ។ ទោះផ្កាយទៅទិសទក្សិណា មានភ័យមមហិមា អោយរៀបបូជាស្តុតី ។សូត្រព្រះអាទិត្យមន្តមេត្រី១៥ ប្របដាប់សោតក្តី តាមក្បួនបង្គាប់នោះហោង ។ ទោះផ្កាយនិរតីនោះផង នឹងកើតនោះឆ្គង មានក្តីមានទោស ហៀបស្លាប់។ទោះផ្កាយ នៅទិសពាយ័ព្យ មានគេអោយទ្រព្យ ពុំនោះនៅសុខសាទរ ។ ទោះផ្កាយនៅទិសឧត្តរ មានលាភដ៏បវរ នឹងអរក្រៃឥតប្រមាណ ។ ទោះផ្កាយនៅ ទិសឦសាន នោះនៃនឹងមាន បងប្អូនអោយលាភសប្បាយ ។ ហើយអោយមើលនិរមិត្រផ្កាយ ទិសទីពណ៌ិនាយ ទក្សិណាបស្ចិមឧត្តរ ។ ល្អិតដូចផ្សែងភ្លើងអម្ពរ រាស្ត្រផងនឹង មរណ៍ នឹងបរនគរព្រាត់ព្រាយ ។ ទោះភ្លៀងឱរចុះព្រះពាយ បក់មកខ្ទាត់ខ្ទាយ ទីទិសទាំងបួនអប្រិយ៍ ។ ទិសទីបស្ចឹមផងក្តី ឧត្តរទោះបីរលើមទូទីមចម្លែក ។ ទីកធំ

ក្រៅខ្នាតពន់ពេក លេចលង់អង្គឯក អនេកនឹងស្លាប់ច្រើនផង ។ ទោះភ្លៀងឱរ ព្យុះហោង ក្សិណាស្រុករឹងកង ហោមហាកំណាចកាចក្រៃ ។ ទោះភ្លៀងធារានោះនៃ ប្រសើរបីប្រពៃ នឹងជាមង្គលសួស្តី ។ ទោះភ្លៀងឱរដូចម្សៅនៃ ប្រសើរឥតបីនៅទីស្ថាន លំនៅពណាភាយ ។ ទោះភ្លៀងសៀងសូរសព្ទសាយ គុក១ខ្ទរខ្ទាយ នឹង ក្បៀមកំកល់ផ្គរទ្រូង ។ ទោះភ្លៀងខ្មៅដូចធ្យូង ទិសបូពឹងត្បូង បស្ចិមឧត្តរពុំជា ។ នឹងខូចនឹងបង់នគរា អោយរៀប បូជា តាមដោយបង្គាប់នេះណា ។ ទោះភ្លៀង ឱរធ្លាក់ធារា ដូចទឹកដោះជា គុណាប្រសើរ ពេកពន់ ។ ស្រុកទេសពិសេសក្សេមសន់ ដោយសព្វតំបន់ នឹងកើតដំណាំភោជនា ។ ទោះភ្លៀងខ្មៅដូចរាចម៍គោណា ប្រសើផ្លែផ្កា សឹងជាមង្គលសួស្តី ។ ព្រះរាហ៍ចាប់ ចន្ទ្រឱរាប់រស់រស្មី អោយព្រះចក្រីស្អាងអង្គ ។ កក់ជ្រះជិរះស្រេចស្រង់ ហើយទើប ស្តេចទ្រង់ ព្រះពស្ត្រសរសុទ្ធហើយណា ។ ទ្រង់គ្រឿងរុងរឿងជា១ ប្រេងម្សៅអប់ផ្កា អើអោអៅថ្វាយបង្គំ ។ ព្រះស្រីរតនត្រ័យសោកសម សួស្តីឧត្តម ប្រកក់សេះដំរី សេះរោង ។ ព្រះរាហ៍ចាប់ព្រះសូរ្យផង ដូចគ្នាឯងហោង អោយចូល រៀបចំដូចគ្នា ។ ឥន្ទនូចុះបូព៌ា អោយរៀបបូជា នោះណានឹងសុខឯងឯ ។ ឥន្ទនូចុះអគ្នេយ៍ប្រសើរ លើសគេ វេរាបូជាព្រះឥន្ទ ។ ឥន្ទនូចុះទិសទក្សិណ ទិសនោះកាច លន់អោយរៀបបូជារឹងខ្មី ។ ឥន្ទនូចុះ ទិសនិរតី នឹងកើតអប្រិយ៍ អោយរៀបបូជា សន្សឹម ។ ឥន្ទនូចុះទិសបស្ចឹម កាចក្រៃឥតថ្លឹម អោយរៀបបូជាអោយឆាប់ ។ ឥន្ទនូចុះទិសពាយ័ព្យ ពុំកាចពុំគាប់ អោយរៀបបូជា គ្រែករអរ។ឥន្ទនូចុះទិសឧត្តរ មានលាភស្មោះសរ រំណររបូជាទើបបាន ។ ឥន្ទនូចុះទិសឦសាន ពលផងនឹងមាន ជម្ងឺដម្កាត់ស្លាប់ហោង ។ ពុំនោះមានអ្នកធំផង ធ្វើទោសអោយឆ្គង រងទុក្ខពុំសុខភិតភ័យ ។ ទោះផ្លេកបន្ទោលនោះនៃ ច្រវាត់ដោយព្វតំបន់ ទិសបូនពេកពន់។

ទោះផ្ដេកបន្ទោលទិសបូពិទក្សិណ បស្ចិមគ្រប់គ្រាន់ឧត្តរកុះករពុំជា ។ និរមិត្របណ្ដាលនោះណា កាចក្រៃមហិមា អោយរៀបបូជាតាមផ្កាយ ។ ទើបយើងព្រះ ឥស្សរសិល្បសាយ ប្រើគ្នាតទាំងឡាយមកទំដំបូលផ្ទះគេ ។ និរមិត្រទាំងនេះឯងឯ ទិសបូពិអគ្នេយ៍ វាវេរអោយយសសក្កា ។ បើបានចុះក្ដួតផងណា ប្រែមុខទិសជា អោយសាធុការស្រេចបាន ។ ទោះគ្នាតទំទិសព្យាសាន នោះសោតនឹងមាន កូនចៅផៅពណ៌គួរគាប់ ។ ទោះគ្នាតទំទិសពាយ័ព្យ ពុំខុសពុំគាប់ ពុំជាពុំកាចឡើយនែ ។ ទោះគ្នាតទំទិសនិរតី ទក្សិណនោះក្ដី បស្ចិមឧត្តរពុំជា ។ ទោះគ្នាតភ្លើងចឹកគ្នា ចូលក្នុងព្រះពន្លាជជ័យ អោយបូជាអោយទាន ។ បើពុំបានធ្វើដោយដាន ទំនងបូរាណ ឡើយនឹងព្រាត់ប្រាសដល់អង្គ ។ ទោះគ្នាតចូលក្រោមផ្ទះត្រង់ កណ្ដាលកំលុង អោយរៀបបូជាពៃថែង ។ សូនរូបស្នងខ្លួនឯកឯង ប្រដាប់តាក់តែង យកផ្ទះប្រគេនសង្ឃបាន ។ ទោះគ្នាតចូលក្នុងគ្រឹះស្ថាន នោះសោតនឹងបាន ក្របីគោសេះសិរី ។ នឹងបានខ្ញុំប្រុសខ្ញុំស្រីមានជ័យសួស្ដី អោយរៀបបូជាកុំយូរ ។ ទោះគ្នាតទំត្រង់ដំបូល ឯកើតពុំយូរមានលាភនូវបានធីស្រុក ។ ហើយបានមាសប្រាក់ផងទុក នូវបានក្សេមសុខស្រណុកសប្បាយសព្វកាល ។ ទោះគ្នាតទំដំបូលកណ្ដាល ម្ចាស់ផ្ទះអាសារ បណ្ដាលនូវក្ស័យជន្មា ។ តែប្រាំពីរថ្ងៃនោះឯងណា អោយរៀបបូជា ទេសនាកំសាន្តកំស្ដាយ ។ ឯផ្ទះអោយរុះខ្ចាត់ខ្ចាយ យកទៅថ្វាត់ថ្វាយ ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ។ ទោះគ្នាតទំដំបូលត្រង់ ឯលិចពុំលង់ ដូចកល់កណ្ដាលពុំរួច ។ ទោះគ្នាតចូលដោយបង្អួច បូជាអោយរួច កើតក្ដួចមាសប្រាក់ច្រើនណា ។ ឯរបៀបអោយរៀបបូជា មាសប្រាក់នន្ទូវផ្កា គ្រប់ពណ៌ដោយចារប្រាយផង ។ សំពត់សរខ្មៅប្រាល

បៃតង បាយទឹកសោតតោង ប្រដាប់ត្រីសាច់ញាំភ្លា ។ ទៀតធូបគន្ធមាលាថង់ដាក់ស្លា រៀបចំពែចែងអោយគ្រប់ ។ បំពង់ទឹកស្រាអោយសព្វ ឆ័ត្រទង់អោយបានដប់ ប្រសព្វ សួនរូបស្នងខ្លួន ។ អោយរៀបសង់រោងសង់ជួន អោយខ្ចាប់អោយខ្ជួន កម្រាលព្រៃព្រំ អោយសព្វ ។ បានទាំងតាំងយូបាំងម្លប់ បង្អែមផងគ្រប់នូវ ស្រូវអង្ករដាក់ផង ។ នូវល្ងរ សណ្តែកគ្រប់ហោរ ប្រដាប់ឥតឆ្គង បង្អែមសព្វហើយរៀបដាក់ « ខ្ញុមព្រះឥស្សូរស្រី » គន្ធព្វបរិវារាគ្រប់ព្យញ្ជនទិស្វាហាយ » ។ ទោះខ្លែងនូវកុកសម្ពាយ នាំគ្នាវើន វ៉ាយចុះជា កណ្តាលភូមិស្រុក ។ ពីថ្ងៃនោះនៃកើតទុក្ខ រត់ចេញចោលស្រុក ពុំសុខភ្លើង ឆេះផងណា ។ ទោះខ្លែងនូវក្អែកជាន់គ្នា ពុំត្រូវភាសា ពុំជាថ្ងៃពីរខែពីរ ។ នូវបង់អស់ស្រុកគល់ក្តើ ពុំនោះចងចេរ មានភ្លើងនូវឆេះផ្ទះសុះ ។ ទោះខ្លែង ឆាបស្មៅធ្លាក់ចុះ ក្នុងរាងទឹកនោះ ចំពោះខុនណាងឫស្សា ។ ប្រាំខែកើតទោសផង គ្នាអោយរៀបបូជា ដូចគ្នាអស់ខ្លែងស្រឡះ ។ ទោះខ្លែងមកទំលើផ្ទះ មានចោរមានះ នឹងលួចនឹងប្លន់មិនលែង ។ តែ១៤ថ្ងៃជាក់ស្តែង ភ្លើងឆេះពុំលែង អោយរៀប បូជាដូចគ្នា ។ ទោះខ្លែងសូះស្វែងហើយណា ឆាប់ឆក់ម្ទីម្នាកូនចាន់ទៅជាអាហារ ។ បរិភោគនឹងច្បារត្រពាល នឹងកើតភស្តុភារ អ្នកផងអោយទ្រព្យស្រឡះ ។ ទោះខ្លែងក្លូក ចូលក្រោមផ្ទះ ឥតជ័យជំនះ នឹងកើតកង្វល់ផងគ្នា ។ នូវកើតជម្ងឺរោគា ពុំនោះសោតណា នឹងមរណាដល់ខ្លួន ។ អោយរៀបធ្វើ បុណ្យអោយជូន អោយមាំអោយមួន បូជាតាម ក្បួននេះណា ។ ទោះខ្លែងស្រាកទំផ្ទះពុំជា នឹងកើតទោសា អាត្មានឹងក្ស័យពុំលែង ។ នូវបាត់ទ្រព្យធនជាក់ស្តែង អោយអ្នកនោះឯង គិតប្រុងប្រយ័ត្នបូជា ។ ទោះក្អែកយំ យប់ជុំគ្នា ស្រុកទេសនោះណា អោយជាកង្វល់មានហ្មង ។ ទោះក្អែកយំថ្ងៃអឹងកង

ប្រចឹកគ្នាដឹរពង នោះហោងនិរមិត្រមានសឹក ។ ទោះក្អែកកាចក្រែពន្លឹក ចុះស្រោចទទឹក ពន្លឹកត្រូវអង្គរាត្នា ។ ដូច្នេះចង្រៃមហិមា បើពុំបូជា ព្រាត់ប្រាស់និវាសឯងហោង ។ ទោះក្អែកចូលក្នុងផ្ទះផង ឧត្បាទរ៍សៅហ្មង មានបងនូវប្អូននឹងស្លាប់ ។ ពីថ្ងៃនោះនៃប្រញាប់ បើពុំចេញឆាប់ រណ្តាប់បូជា សូត្រមន្ត ។ ទោះនឹងមានទោសទុក្ខធ្ងន់ អោយរកទីស្ថានតំបន់ លំនៅឯទៀតទើបជា ។ ទោះក្អែកនូវមាន់ជាន់គ្នា ប្រាំបីទិវា នឹងខូចនឹងខាតបង់ស្រុក ។ នឹងកើតកង្វលកល់យុគ ហើយនឹងកើតទុក្ខ ពុំសុខសប្បាយបរិបូណ៌ ។ ទោះក្អែកពាំក្អែក មួយចូល ក្នុងស្រុកពុំយូរ នឹងប្រាសលំនៅទីស្ថាន អោយរម្ងាប់ស្ពុងពីកំសាន្ត សូត្របន្តអោយ ទាន ធ្វើបុណ្យរម្ងាប់ទើបជា ។ ទោះក្អែកនូវក្រលែងវេកណា ត្រេកសោមនស្សា ស្គាល់គ្នាក្នុងភូមិក្នុងស្រុក ។ ពីថ្ងៃនោះនៃកើតទុក្ខហើយ នឹងបង់ស្រុក ពុំសុខភ្លើងឆេះ គ្រឹះហា ។ ទោះក្អែកនូវកុកផងគ្នា នឹងមានអ្នកឯណា ប្រាថ្នាអំពីចម្ងាយ ។ ទិសបូពិពុំយូរមិន ងាយ យកស្រុកអន្តរា អោយរៀបបូជាស្រឡះ ។ ទោះកុកនូវត្អូមទំផ្ទះ ចឹកគ្នាតតះ ម្ចាស់ផ្ទះអោយរៀបបូជា ។ ធ្វើបុណ្យអោយទានផងណា ចោលផ្ទះទើបជា មិម្នាយក ទៅថ្វាយព្រះ ។ ទោះឳឡូរចូលភូមិដ៏ស្រឡះ អោយគរជិរធ្វើបុណ្យអោយទានបូជា ។ បើពុំដូច្នោះណា នឹងនាំរាត្នា បង់ស្រុកកើត ទុក្ខភ្លើងឆេះ ។ ទោះទោមដក់រនាល នោះជុំគ្នាវា ដោយស្រែសព្វថ្ងៃឯណា ទោះនឹងកើតហេតុកោលាហល ហើយពុំជា នោះណាអោយសូត្រមន្តជំរះ ។ ទោះទុងក្អែកទឹកទំផ្ទះអគ្នេយ៍គេហះ និរតីអប្រិយ៍សឹងកាច។ បស្ចិមទក្សិណគួរខ្លាច ទិស៤ឯងអាច អោយរៀបទានបូជា ។ ទោះទុងចុះពាសទន្លេណា ទាំងទូកនាវា ខាងនាលំនៅជ្រិះស្រុក ។ មានហេតុច្រវាក់អុកឡុក គ្នាហើយពុំសុខ ខុនណាង នូវក្សត្រច្បាំងណា ។ ទោះមាន់មានកូនហើយយណា ពុំស្រឡាញ់គ្នា រត់ចោល

កូនឯងសាត់ព្រាត់ ។ តែប្រាំពីរថ្ងៃទៀងទាត់ បើពុំប្រយ័ត្ន នូវពុំបូជានឹងប្រាស ។ អំពី លំនៅដេរដាស ទឹកភ្នែកពេញពាស ចោលភូមិលំនៅខ្ចាត់ខ្ចាយ ។ ទោះមានព្រៃរត់ព្រាត់ព្រាយ ចូលភូមិខ្វល់ខ្វាយ ពព្លឹមពព្លាមស្លើតស្លក់ ។ មកអំពីទិសទីអាក្រក់ នោះនឹងមានទុក្ខ ពុំសុខសប្បាយឡើយហោង ។ អោយប្រថាប់គ្រប់ គ្រឿងនោះផង បូជាចម្លងឯ ព្រះគ្រោះ ហើយប្រកក់ទើបជា ។ ទោះមានពង អស់ហើយណា ក្រាបយូរលង់ជា ខាប់ខះគ្មាន កូនចៅជីវ ។ ទោះមានថ្ងៃ១ពងពីរ ពុំលុងចុងចិរ នូវស្លាប់កូនចៅផៅពណ៌ ។អោយរៀបបូជា អស់អាថិ បង្គាប់អំបាល ជូនអស់សត្វស្លាបនោះណា ។ មាន់ញីរងាវពុំជា ចង្រៃមហិមា អោយរៀបបូជា វឹងខ្មី ។ ទោះមានចឹកកូនឯងក្តី ឧត្បាទវិអប្រិយ៍ ព្រាត់គ្នាខ្ចាត់ខ្ចាយ បង់ស្រុក ។ អោយរៀបបូជា ទើបសុខគ្រាន់បើគ្មានទុក្ខហើយ និងស្រណោកវិញណា ។ ទោះលលកទំផ្ទះពុំជា នឹងបង់ទ្រព្យា អោយរៀបបូជាកុំយូរ ។ ទោះឃ្មុំទំផ្ទះទិសបូព៌ ព្រះរាហ៍បន្ទូល អោយមកធ្វើទោសធ្វើគុណា ។ បើអ្នកឯណាដឹងបុណ្យ អោយរៀបសូត្រមន្ត ប្រកក់បូជាអោយជ័យ ។ ទោះឃ្មុំទំនៅអគ្នេយ៍ គេដៀលគេជេរ នឹងកើតជំលោះពេកក្រៃ ។ ព្រួយចិត្តតែងគិតសព្វថ្ងៃ បារម្ភមែៗ សន្ទែសន្ទឹកពុំជា ។ ទោះឃ្មុំទំផ្ទះនិរតី នឹងកើត អប្រិយ៍ ដូចដល់អំពល់អាត្មា ។ ទោះឃ្មុំទំផ្ទះបច្ចិមា នឹងកើតទោសា អោយរៀបបូជា ទើបបាន ។ ហើយអោយ ប្រយ័ត្នខ្លួនប្រាណា ធ្វើបុណ្យអោយទាន ប្រគេនផ្ទះនោះ ទៅឆាប់ ។ ទោះឃ្មុំទំផ្ទះពាយ័ព្យ ប្រសើរគួរគាប់ អោយរៀបបូជាមង្គល ។ គេយកទ្រព្យ ធនមកដល់ នោះពុំអម្ពល់ មង្គលសឹងតែត្រេកអរ ។ ទោះឃ្មុំទំផ្ទះឧត្តរមង្គលដ៏បវរ អរអោយ តេជះក្សេមក្សាន្ត ។ ទោះឃ្មុំទំផ្ទះឦសាន នោះសោតនឹងបាន ខ្ញុំប្រុសខ្ញុំស្រីកែវកង ។ ឯរបៀបអោយ រៀបសោតហោង តាមដោយគន្លង អស់សត្វមានស្លាបឯងបាន ។

ទោះឃ្មុំហើរពីព្រៃសាន ទំក្រោមផ្ទះប្រាណ នូវបានជោគជ័យជំនះ ។ ទោះឃ្មុំទ្រហឹងទុំផ្ទះ ហើរចេញស្រទ្បះ នោះកាចអោយរៀបបូជា ។ ព្រះរាហ៍ប្រើមកម្មីម្នា បើ ពុំបូជា នោះណាមានភ័យពុំជ្រះ ។ ទោះឃ្មុំចូលខាំក្នុងផ្ទះ អោយបូជាជំរះ នូវមាន មាសប្រាក់ទ្រព្យផង។ ទោះឃ្មុំផ្ដិតទំផ្ទះហោង ទិសទីទំនង ដំណើរហើរចូល ទិសឯណា។ ទាំងបួនបីសឹងមានកាចជា មើលលំនាំវា អោយរៀបបូជាស្ពានស្មោះ ។ ទោះឃ្មុំទំដោយច្បារនោះ ព្រះរាហ៍ចំពោះ ប្រើ មកធ្វើទោសឯងណា ។ អោយរៀបប្រដាប់ប្រដា សត្វស្លាបដូចគ្នា បូជាបង្គាប់ដូច្នេះ ។ ទៀនធូបលាជផ្កា នូវក្រចេះប្រេងម្សៅសំណោះ ចំអាបបង្អែមផ្លែឈើ។ថង់រងសឹងមានដាក់ឈើ តោករងហើយ ធ្វើស្លាធមិពិពណ៌ពិសី ។ ប្រដាប់មាសប្រាក់រតន៍មណី សំពត់អាវថ្មី នូវស្បៃ កាសាយមនា ។ ស្រាបពានមែនមានដាក់ផ្កា ប្រដាប់ផងគ្នា នូវលាជរាបសាចផង ។ នូវប្រេងព្រះគោលោតហោង បូជាដោយគន្លង កន្លងលំនៅខាងជិត ។ ទោះព្រួតទំផ្ទះឯង ស្និទ្ធអោយរិះគន់គិត អោយរៀបបូជាសព្វសាយ ។ «ឱមព្រះរាហូ ទេវតា អាគន្តុ ភុញ្ជន្តុ ស្វាហាយ» ម្រោមព្រួតទំផ្ទះមិនងាយនូវព្រាត់ខ្ចាត់ខ្ចាយ អន្តរាយខ្លួនឯងកូនចៅ ។ អោយ រៀបបូជាប្រេងម្សៅ ប្រដាប់នេះនៅ ដូចលលក សត្វស្លាបឯងណា ។ ទោះសេកផ្អើល យប់សន្ធិយា ព្រាត់ប្រាស់ពីគ្នា អោយរៀប បូជាសន្ទីយ៍១៦ ។ បើពុំបូជាស្ដុតី ហើយនឹងអប្រិយ៍ ចោលភូមិចោលស្រុកជាម្ដង ។ ទោះពស់ពីសពន់ដ៏គន្លង ឡើងផ្ទះឥតឆ្គងទិសបូព៌អគ្នេយ៍មង្គល។ ឡើងមកពេនព័ន្ធ ដឹកលល់សុខសប្បាយអស់ ដល់អោយទាំងសំណាកផង ។ នឹងបានកូនចៅតបស្នង មាសប្រាក់កែវកង សម្បត្តិសម្បូណ៌ស្ងួស្ដី ។ ចូលទិសទក្សិណនិរតី បស្ចឹមអប្រិយ៍ ឧត្ដរនោះ សោតពុំជា ។ អោយរៀបធ្វើបុណ្យទេសនា ប្រដាប់ប្រដា អោយ រៀបសូត្រមន្តរំដោះ ។ អោយជៀសពីលំនៅនោះ នឹងស្បើយអស់គ្រោះ នឹង សុខសប្បាយសព្វគ្រា ។

ហើយអោយសូត្រមន្តបូជា ព្រះឥន្ទ្រចេស្តា នូវមន្តគាថា ពស់ពាយ « ឱ្មព្រះឥន្ទ្រា ស្រីសន្ធបបរិវារាយ សព្វព្យញ្ជននិស្វាហាយ » ។ ទោះពស់ចូលក្នុងឆ្នាំងបាយ ព្យាធិទាំងឡាយ រោគាបៀបបៀនដល់អង្គ ។ អោយរៀបបូជាផ្ចិតផ្ចង់ កុំទុកបង្អង់ អោយជ្រះស្រឡះលំហែ ។ ទោះពស់ចូលទិសបូពិអគ្នេយ៍ ឮសានឯងឯង សឹងតែប្រសើរថ្លាថ្លៃ ។ ទក្សិណនិរតីចង្រៃ បស្ចឹមសោតនៃ ឧត្តរទិសបូពិដូចគ្នា ។ ឯទិសពាយ័ព្យសោតណា ពុំសូវកាចជាចន្លោះលង្វែកតែឯង ។ អោយរៀបបូជាតាក់តែង ប្រយ័ត្នគិតក្រែង និរមិត្រដូចមាត់គេថា ។ ទោះថ្លាន់គោមភ្លឺក្តីណា ឡើងលើនាវា លេលាលើផ្ទះសព្វថ្ងៃ ។ បូជាព្រះកេតុនោះនៃ ស្លៀកខ្មៅប្រពៃ របៀបប្រដាប់ដូចគ្នា ។ នូវមានមាសប្រាក់នានា បើដុះហើយណាអោយទាំងសំណាកនោះផង ។ បើត្រូវទិសបូពិឯងហោង អគ្នេយ៍ ទំនង ដំណើរទិសពីរសឹងជា ។ អោយយកទុកដាក់រក្សា ចំរើនសុខា អោយរៀបបូជាសាទរ ។ ចូលទិសទក្សិណឧត្តរ ចូលពុំស្មោះសរ និរមិត្របស្ចឹមសឹងកាច។ ឯទិសពាយ័ព្យ ឯងកាច ពុំជាពុំកាច បូជាដូចគ្នារៀងរាយ ។ «ឱ្មស្រីគន្ធប បរិវាគ្រប់ ព្យញ្ជនិ ស្វាហាយ » ពស់ព្រៃ នូវនៃពស់ក្រាយឡើងផ្ទះគឃ្លាយ អោយរៀប បូជាឆាប់ៗ សំពត់សរច្រាលខ្មៅញាប់ អោយរៀបប្រដាប់ដង្វាយព្រះឥន្ទ្រខ្មី ។ ចំរាប ផ្លែឈើនូវចំណី មាសប្រាក់ផងក្តី ទៀនធូបភ្លឺច្រាលប្រេងម្សៅ ។ ទោះពស់វាកើតកូនចៅ ក្នុងភូមិលំនៅ ថ្ងៃប្រាំបង់ស្រុកគលកើ្ត ។ ពស់ចូលក្នុងចរម្ធូរកន្ទេល នឹងកើតចុងចេរ គេនឹងធ្វើទោសកាចក្តាត់ ។ អោយរៀបបូជាប្រសិទ្ធី ហើយអោយគន់គិត តាមដោយបង្គាប់សព្វសាយ ។ ទោះបីស្រីផងទាំងឡាយ ប្រសូត្រកូន ក្លាយជាពស់១ឆ្នាំបង់ស្រុក ។ ទោះជាកូនជាឆ្កែអោយទុក្ខ ឆ្នាំពីរបង់ស្រុកបង់ភូមិលំនៅដ្ឋាន ។ ទោះបុរសនោះ សោតមែនមាន កូនចៅពីរប្រាណនោះ ជាត្រមោចវិញហោង ។ ចង្រៃនូវ

កើតសៅហ្មង ឧត្បាទនេះហោង ថានូវបង់ស្រុក ពុំលែង ។ ទោះហោញីខ្មៅចូលស្រុកស្តែង អោយរិះតាក់តែងបូជាប្រាក់មាសនូវសេះ ។ ឯបន្តប្រដាប់នៅនេះ កុំបង្អង់ទុកស្លេះ សឹងរៀបប្រដាប់ដូចគ្នា ។ ទោះត្មាតចូលស្រុក នោះណោ អោយរៀបបូជា មានស្រូវនូវអង្ករផង ។ ពោះទោចចូលស្រុកឯងហោង បង់ស្រុកតែម្តង ពុំនោះមានភ្លើងនូវឆេះ ។ អោយរៀបបូជាវត្តរិះ តាមដោយក្បួននេះ តាមមនុស្សតាមសត្វស្រឡះ ។ ទោះឆ្កែឡើងដំបូលផ្ទះ ចិត្តនោះមនោហោះ ប្តាត់នឹងស្លាប់បង់ស្ពាន ។ អោយរៀបបូជាកុំខាន ទើបនឹងក្សេមក្សាន្តស្ពោះពែងទុក្ខភ័យ ។ ពោះពពែនូវផ្កេជាន់គ្នា ឆ្នាំ១ពុំជា នោះណោនឹងបង់ ស្រុកត្រៃ ។ ឧត្បាតវីបូមកពិញឯផ្កេ ពុំត្រូវដូវផែ ត្មាតគ្នាពុំចាំហេតុ ។ ទោះក្របីព្រៃចូលតំបន់ក្នុងស្រុកកាចពេន តព្រោមក្ដួរនៅឯងហោង ។ ឧត្បាទ ដល់ឆ្នាំពីរផង នឹងកើតមានប្លងក្បត់ក្បិណោហិនហេតុស្រុកត្រៃ ។ ពោះឆកចូល មកឯងឯ ក្នុងស្រុករវេ រវល់ចល់កើតកាច ។ បូជាពាយ័កនូវកោដ ពោតព្រាកដ៏សព្វាច រណ្តាប់បូជាអោយថៃ ។ និរមិត្រសត្វពោធនូវផ្កេដេញគ្នាឯងនៃ នឹងព្រាត់ វិនាសពីស្ពាន ។ អោយយកដីរសេះយាន ខែលដាវគ្រឿងមានអោយពោង ក្នុងទឹកបើមណោ ។អោយរៀបប្រដាប់ប្រដា ថ្កល់ផ្តើងបូជា សូមតេជះជោគជ័យ។ ទោះព្រួសចូលភូមិឯង្គ សឹងកាចពេកក្រៃ បីថ្ងៃពេកក្រៃ បីថ្ងៃនឹងក្តៅស្ពោះ ។ នឹងព្រាសពីលំនៅនោះ កើតទុក្ខសូន្យស្ពោះ ចំពោះអោយរៀបបូជា ។ ពោះគោសម្រាមកូនណោ កើតជាមនុស្សឧត្បាទពុំជានៃ ។ នឹងមានហេតុភេទទុក្ខភ័យ ខុនណោចៅមេអោយចាំលើហោ ។ អោយប្រាំពីរមេវា បើពុំធ្វើណោ នូវបង់ខុន ពលនូវខ្លួន ។ បង់ខុនណោងនូវចៅចៀងផៃធូន បូជាអោយបួន កុំអោយប្រហែស ឡើយណោ ។ ទោះត្រកួតចូលគ្រឹះបញ្ញើសានណោ បូពិធសពីរចង្រៃ ។ អោយរៀប បូជានោះនៃ ពាសប្រាក់នូវចំណី

ស្រាលោជប្រេងម្សៅគន្ធ ។ នូវស្រូវអង្ករផ្កាភ្ញី សំពត់ សរថ្មីនូវល្អរសណ្តែកនោះផង ។ ទោះមនុស្សបាត់ស្រមោលហោង ឧត្បាទក្បាលជាម្តង នូវក្ស័យជីវិតវិញណា ។ ធ្វើបុណ្យបង្សុកូលអនិច្ចា អោយទានផងណា លំដោះរស់គ្រោះកាចបាន ។ ទោះផ្សិតដុះក្នុងចង្រ្កាន នោះសោតនូវមាន សិរីសួស្តីឯងហោង ។ នឹងបានមាសប្រាក់កែវកង អំពីមិត្រផង សំឡាញ់សំលូតអោយទ្រព្យ។អោយរៀបបូជាស្រេចស្រាប់ តាមក្បួនបង្គាប់ មាសប្រាក់សំពត់ច្រាលសរ។ សំពត់ខ្មៅម្សៅប្រេងល្ងរ នូវស្រូវអង្ករ ផ្កាសរទៀនធូបបួរស្លា ។ ចំណីចំអាបញ៉ាំភ្លាបង្អែមគ្រប់ណា យកទៅបូជាឆាប់វៃ ។ ទោះបាយឆ្អិនហើយដុះក្តី នឹងមានរាជភ័យ អោយរៀបបូជាអោយទាន ។ សំពត់ស្រូវអង្ករ បានចំណីផងមានបួរស្លា ទៀនធូបភ្ញីច្រាល ។ ទោះអង្ករត្រាំនដុះដាល នឹងកើតសឹកសាមកដេញ អោយបែកគ្រប់គ្រា ។ ទោះផ្សិតដុះក្នុងឆ្នាំងបាយណាជម្ងឺរោគាជរាស្លាប់បាត់ខ្ចាត់ខ្ចាយ ។ អោយរិះគិតខ្វល់ខ្វាយ បូជាសព្វសាយ អោយចេលឆ្នាំងបាយនោះចេញ ។ ទោះដង្កូវដុះ លើខ្លួនមិញអោយ រំដោះគ្រោះចេញស្រូវពេញកញ្ជើ១ណា ។ អោយរៀបរណ្តាប់បូជា បានបីទេវា អាត្មាភរិយាសួស្តី ។ទោះឃើញក្នុងធ្នះ ក្នុងផ្ទះក្តី បូជាផ្កាភ្ញីមាសប្រាក់ នឹងមានលាភវិញ ។ ទោះដីដុះក្រោមផ្ទះពេញ អោយបូជាចេញស្រឡះ នឹងមានលាភក្រៃ ។ ទោះត្បាល់ដើរឯងយប់ លែងលំនៅនៃ អោយរៀបបូជាឯងឯ ។ ទឹកឃ្មុំនូវទឹកទន្លេ ទឹកដូងចាក់ពៃ យកព្រហ្មចារីអង្គុយឯង ។ នូវស្រូវមួយផ្ទែកតាក់តែង ពៃរូតពៃចែង សំពត់សរក្រហម ។ បើពុំបូជាអោយព្រម រៀបចំអោយល្មម ម្ចាស់ផ្ទះនឹងស្លាប់ពុំខាន ។ ទោះឆ្នាំដើរពីក្រាន ម្ចាស់ឆ្នាំងនឹងមានទុក្ខអោយ ហិនហោចព្រទ្យា ។ អោយរៀបប្រដាប់បូជា ដូចត្បាល់នោះណា នឹងបានប្រកបសាន្តសុខ ។ ទោះរទេះដើរឯងក្នុងស្រុក ថ្ងៃ១សុខកើតទុក្ខ ចោលស្រុកទីស្ថាន

ស្រុកទីស្ថាន ។ អោយរៀបបូជាទើបបាន សូត្រមន្តកំសាន្ត ប្រគេនរទេះចេញទៅ ។ ទោះស្រមោចសង្ហារឡើងនៅ ចោមផ្ទះចៅរៅ ប្រសេចប្រសាចសោះសា ។ ក្រែងខុនណាង នូវរាស្ត្រប្រជា ស្រដីផងគ្នា ពុំត្រាពុំស្តាប់ពាក្យគ្នាឡើយ ។ នូវលំអៀងពុំទៀង ប្រងើយ កាចពេកណាចស់ហើយ ថ្ងៃប្រាំនូវបង់ស្រុកពិត ។ ដូច្នេះយល់ ទុច្ចរិត ខុនណាងព្រួយចិត្ត ចាស់ព្រិទ្ធាចារ្យកង្វល់ ។ អស់រាស្ត្រប្រជាអំពល់ នាងជីដេរខ្វល់របស់ពុំស្រុកឡើយ ទោះទូកលើ បង្គងជាស្រែកហ៊ោរោ ហើយ ល្បូនលឿនពីបង្គងចេញ នឹងស្លាប់ខ្លួនកូនចៅវិញ ។ នឹងកើតទុក្ខម្ទិញ អោយរៀបបូជារំដោះ ។ អោយសូត្រទិព្វមន្តរំ ដោះគ្រោះហើយ អោយចំពោះ ប្រគេនទូកនោះទៅឆាប់ ។ បើឈប់យូរទៅពុំស្តាប់ ប្រាំពីរថ្ងៃពុំគាប់ កុំអោយប្រហែលអោយក្រែង ។ ទោះដឹងបែកភ្លុកដែងឯង បូជាតាក់តែង ដីរសេះ អោយទ្រព្យផង ។ ទោះដួងជ្រុះទាំងធ្លាយបោង បង់ខ្លួនជាម្តង ៖ អាយផ្សង់បូជាអោយគ្រប់ ។ អោយប្រជាប់បាយទឹកអោយសព្វ ទៀនផ្កាទឹកអប់ សូត្រមន្ត អោយទានចម្លែក ។ ទោះដួង ដុះច្រូងជាមែក ជាពីរចុងព្រែក នូវបង់កូនចៅផៅពណិ ។ ទោះអំពៅខ្មៅផ្កា សោតនូវប្រាសជា ម្តងអំពីលំនៅទីស្ថាន ។ ទោះដំបូកទិស បូពិនូវបាន គោក្របីយាន ដីរសេះសោតរក្សា ។ ទោះដំបូករស្មេយ៍ទិសា ភ្លើងឆេះពុំជា ជួយគ្នាប្រដាប់អោយគ្រប់ ។ អោយរៀបបូជាសាយសព្វ ស្រេចហើយផ្តផ្តាប់រំលាយដំបូកចេញជា ។ ទោះដំបូកនៅទិសទក្ខិណានៅបង់ទ្រព្យាបូជារំលាយ ចេញខ្ចី ។ ទោះដំបូកនៅទិសនិរតី អោយទោសឯងក្តី ហើយអោយរំលាយចេញណា ។ ទោះ ដំបូកនៅទិសបច្ឆិមា អោយផ្តត់រក្សា បូជាថ្ងៃសៅរ៍អង្គារ ។ អោយគុណលើសលន់ក្តាត់ ណា នឹងមានបរិវារ បរិពារខ្ញុំប្រុសខ្ញុំស្រី ។ រទេះនូវសេះដីរ នឹងមានសួស្តី មានទ្រព្យ ធនច្រើនគួរគាប់ ។ ទោះដំបូកនៅទិសពាយ័ព្យ នោះនឹងគួរគាប់ បានខ្ញុំអាយាត់វេះវរ ។

ទោះដំបូកនៅទិសឧត្តរ មង្គលដ៏បវរ នូវបានមាសប្រាក់កែវកង ។ បូជាផ្កាភ្ញីលាជផង ទឹកឃ្មុំ សោតហោង ទៀនធូបប្រេងម្សៅអោយបាន ។ ទោះដំបូកនៅទិសឦសាន នោះសោតនឹងបាន ទ្រព្យធនពេកពន់មហិមា ។ អោយរៀបប្រដាប់បូជា គ្រឿងគន្ធមាលា ផ្កាភ្ញីទៀនធូប លាជផង ។ បើពុំដូច្នេះឡើយហោង ដំបូកខឹងផង អាវក្តនូវធ្វើទោសា ។ អោយស្លាប់បាត់ បង់ជន្មា បង់ទាំងទ្រព្យា បង់ភូមិលំនៅស្រឡះ ។ ទោះដំបូកនោះដុះក្រោមផ្ទះ មានជ័យជំនះ អ្នកផងអោយ ទ្រព្យត្រៀបត្រា ។ ទោះបីក្នុងខ្ទោះគ្រានណា ប្រេះបែកចេញជាពីរបីជំពូក ពុំគាប់ ។ អោយរៀបបូជាដោយសណ្តាប់ សំពត់ស្រេចស្រាប់ ដ៏វីនូវសេះភោជនា ។ បើពុំធ្វើដូច្នេះណា នឹងកើតទោសា បាត់បង់ទ្រព្យខ្លួនកូនចៅ ។ ចោលស្រុកទីស្ថានលំនៅ អោយកើតទុក្ខក្តៅ ព្រាត់ប្រាសវិនាសពុំក្សាន្ត ។ ទោះស្រា ពុះក្នុងដបដាន នឹងផឹកពុំបាន អោយរៀបបូជាមាសប្រាក់ ។ សំពត់សរខ្មៅទៅពាក់ ស្រូវអង្ករដាក់ កន្ទោងសណ្តែកនូវល្ងូរ ។ បើពុំបូជាទល់ទ្រ នឹងកើតទោសមរណៈ ដល់ខ្លួនដល់ស្រុកបង់ទ្រព្យ ។ទោះខ្លឹងចូលស្រុកគួរគាប់ អោយរៀបប្រដាប់ស្លៀក សរហើយប្រកក់ណា ។ ទោះត្រកួតឡើងផ្ទះសឹងជា អោយ រៀបម្ហូបម្ហា បូជា មាសប្រាក់គ្រប់ហោង ។ នឹងកើតសួស្តីដ៏កន្លង នូវមួយស្រូវផង ពេញ តឹកពេញឃ្លាំងឯណា ។ ទោះអណ្តើកចូលភូមិពុំជា អោយយករស់គ្នា ម្ហូបម្ហាបូជាក្នុងស្រុក ។ បើពុំបូជានូវកើតទុក្ខ នោះនឹងចោលស្រុក ប្រាកដពុំលែងឡើយហោង ។ ទោះ កណ្តៀវ នៅសសរផង កើតទុក្ខសៅហ្មង អោយរៀបបូជាឯងឯ ។ ទោះកណ្តៀវ នៅទិសអគ្នេយ៍ធ្មី មកណ្តាលទេប្រមែកណ្តាលកាចក្រៃ ។ នៅសសរកណ្តាលចង្ក្រៃ នឹងកើតទុក្ខភ័យ អំពល់នូវ ទ្រព្យពេកពន់ ។ ទោះកណ្តៀវនៅសសរ ទក្សិណកាចក្រៃលើសលន់ នឹងមានរាជភ័យ ជិតដល់ ។ អោយទានចាំសិលសោតសល់ ហើយអោយខ្វាយខ្វល់ និមន្តសូត្រមន្តផងខ្មី ។

ទោះកណ្តៀវនៅសសរនិរតី នឹងកើតអប្រិយ៍ គេនឹងធ្វើទោសឥតថ្មឹម ។ ទោះកណ្តៀវនៅទិសបស្ចឹម ជាកាចសន្សឹម ឫជាសន្សំឯងឯក ។ ស្រូវអង្ករនូវល្វរសណ្តែក លាជផ្កាអនេកប្រេងម្សៅទៀនធូបគួរគាប់ ។ ទោះកណ្តៀវនៅសសរពាយ័ព្យ គេនូវអោយទ្រព្យសម្រាប់ប្រសើរបវរ ។ ទោះកណ្តៀវនៅសសរឧត្តរ មានលាជអំណរ កុំបីសន្ទឹកនឹងបាន ។ ទោះកណ្តៀវនៅទិសឦសាន នោះសោតនឹងមាន សាច់ញាតិបងប្អូនសំណាក់ ។ ឧត្បាទទី១២ ជើងជាក់ ព្រះឥន្ទ្រាររក្ស ព្រះកេតុទេវតាសំដៅ ។ ប្រើអ្នកអោយដឹងខុសត្រូវ អោយអ្នកផងកូវរៀបចាំទទួលបូជា ។ ទៀនធូបគន្ធមាលាគ្រឿងបាយ គ្រឿងបាយគ្រឿងស្លា ផ្កាស្លាពីរពណ៌អតិរេក ។ សំពត់សរខ្មៅក្រាលពេក នូវល្វរសណ្តែក ម្សៅប្រេងលាជសឹងព្រមគ្នា ។ បង្អែមសោតផែរញាំភ្លា ទឹករបស់ផងណោ សំពត់អង្កាញ់ឆ្វេងស្តាំ ។ មាសប្រាក់ ដាក់ពានប្រចាំ កន្ទោងបូរណ៍ តែទៅដោយទិសសម្ពាយ ។ អោយសូត្របាន មួយដងថ្វាយ១៧គ្រប់គ្រឿងទាំងឡាយ ថ្វាយទៅព្រះឥន្ទ្រទេវតា ។ រំដោះទុក្ខ ទោសភ័យា សែនព្រេនបូជារម្ងាប់និរមិត្រកាចក្រៃ ។ អំពិលអំពែកនោះនៃ ចូលផ្ទះសព្វថ្ងៃ មានលាភអោយបូជា ។ ទើបបានដូចចិត្តចិន្តាបើពុំបូជា ឡើយលុះអំពើសៅហ្មង ។ ស្រេចចប់គ្រាន់គ្រប់ហើយហោង តាមតម្រាផងសឹកលើកជាល្បើកតទុក ។ អោយបានកេរ្តិ៍កបទៅមុខ ជាច្បាប់ក្បួនទុកអ្នកផងដឹងឧត្បាទទាំងឡាយ ។ សូមជ័យព្រះឥសូរ ព្រះនារាយណ៍ឥន្ទ្រ ព្រហ្មសម្ពាយចំរើនអាយុយឺនហោង ។ ហើយអោយមហាជនផង បានស្តាប់ហើយយោង អោយស្បើយជម្ងឺទុក្ខភ័យ ។ អោយស្បើយអស់ទាំងចង្រៃ គ្រោះកាចនោះនៃ នូវសូមស្រាកស្រាន្តរោគា ។ ទោះផ្ទះទ្រោមទ្រុឌក្តីណា សូមអស់ទេវតា មកជួយដម្រង់ជ្រោមជ្រែង ។ ទោះភ្លើងឆេះចង្រានស្តែង សូមជួយពាក់តែង បន្សាត់ចំបាត់ចង្រៃ ។ ទោះកុកឃ្មុំពពស់នោះ

នៃពង្រួលពស់ព្រៃ នូវសត្វអណ្តើកតិរច្ឆាន ។ រន្ធះបាញ់ទីភូមិស្ថាន អ្នកផងមែនមានមនុស្ស នា លោកីយ៍នេះណា ។ មហាជ័យនេះថ្លៃសោតជា បន្សាបអស់អាថិ នូវពីសកម្មអប្រីយ៍ ។ អោយមនុស្សនាផងមានឫទ្ធី ដូចតេជះអំពីព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃផង ។ កុំអោយកើត ក្តៅក្រហាយហោង ត្រជាក់ជាម្តង ដូចទឹកអម្ពតវិស័យ ។ ព្រះព្រហ្មឥស្វរនោះនៃ សឹងអោយ ពរជ័យ រក្សាសព្វថ្ងៃទៅហោង ។

# សេចក្តីអធិប្បាយ

របស់ដែលជាឧត្បាទរឺដែលពោលហើយមកនេះ ក៏ពិស្តារសមគួរហើយតែងនៅមិនទាន់អស់ជើងនៅឡើយ នៅមានហេតុរបស់សត្វយ៉ាងដទៃទៀត ដែលទោសបណ្តាលអោយកើតមានឡើងហើយ ក៏រាប់ជាឧត្បាទរ៍ដូចគ្នានោះក៏មានអ្នកនឹងបូជាគប្បីបូជាទៅតាមប្រភេទសត្វស្លាប ឬ សត្វចតុប្បាទជាដើម ។

ន័យ១ទៀត សូម្បីពួកឧត្បាទរឺដែលពោលចេញមកហើយទាំងប៉ុន្មាននោះប្រការខ្លះនៅមានសេចក្តីល្អិតពិស្តារចេញទៅទៀត គួរនឹងអធិប្បាយទុក ដើម្បីអោយអ្នកដែលបានប្រទះហេតុនោះនឹងបានចាត់ការបូជាត្រូវតាមរបៀបអំពីបូរាណដូចមានតទៅនេះ -

ជំពូកសត្វពីស គឺឃ្មុំ ឪម៉ាល់ពស់ ជាដើមបើចូលមកហើយវាដេញទិចដេញ ខាំកុំអោយនៅក្នុងផ្ទះនោះឡើយអោយបូជាប្រកក់ហើយអោយចុះចេញចោលផ្ទះចោលភូមិនោះ ។

ឯឃ្មុំសោតបើវាមកទំបែកគ្នា ឯណេះខ្លះឯណោះខ្លះសឹងពុំជាឡើយអោយរៀបបូជាប្រកក់ហើយអោយចុះចេញអំពីភូមិនោះ តែបើនឹងរើយកផ្ទះនោះទៅសង់នៅទីដទៃបាន ។ បើវាមកមូលគ្នាមកទំនៅទិសណាក្តីសឹងជាហោងអោយរៀបបូជាដូចក្នុងក្បួន ។ បើឆ្កែមកកូនលើផ្ទះកុំអោយរៀបធ្វើរានទេវតាឡើយអោយរកឈើចន្លល់បាន១០០មកទល់ ក្រោមកន្លែងដែលឆ្កែកូននោះ អោយរៀបបូជាដូចពោលក្នុងក្បួននឹងស្បើយឧត្បាទរ៍ចង្រៃឧបទ្រពទំងនោះហើយនឹងត្រឡប់កើតលាភសក្ការះអំពីខុនណាងហោង។ បើឆ្កែស្ការគ្នាលើផ្ទះក្តីលើទូកលើសំពៅក្តីអោយ រៀបបូជាដូចក្នុងក្បួន នឹង បានទ្រព្យចូលពុំលែងឡើង ។ បើឃើញឆ្កែវាមកកូនលើផ្ទះក្តីវាពាំកូនមកឡើងលើផ្ទះក្តី បានបណ្តេញបរវាហើយពុំឈ្នះវាឡើងមកបានអោយរៀបបូជា

ប្រកក់ខ្លួនរួចហើយអោយចុះចោលទាំងផ្ទះទាំងភូមិ។បើផ្តែមកកូនក្តីពាំកូនមកក្តី ឬស្គារគ្នាលើផ្ទះលើទូកលើសំពៅក្តីតែម្ចាស់ផ្ទះម្ចាស់ទូក - សំពៅពុំបានឃើញវាទេលោកថា ជាមធ្យមពុំសូវកាចទេអោយរៀបបូជាប្រកក់ប៉ុណ្ណោះ ក៏បានហើយ ។ បើវាចូលមកអំពីទិសដែលពុំជាហើយវាចេញទៅខាងទិសដែលជានេះក៏ជាមធ្យមដែរ ។ បើវាចូលមកអំពីទិសពុំជាហើយចេញទៅខាងទិសពុំជានោះលោកអោយរៀបបូជាប្រកក់ដូចក្នុងក្បួននេះនៅបានហោង ។ បើវាចូលមកអំពីទិសជាហើយចេញតាមទិសជានោះជាឧត្តមប្រសើរពេកហោង ។

បើចេកលេចបណ្តូលក្តីត្រយូងក្តីអំពីកណ្តាលដើម ពុំជានឹងកើតឈឺថ្កាត់ដល់អ្នកម្ចាស់ចេកបើលេចបណ្តូល១-២-៣រហូតដល់១០០ក្តី នឹងពុំជាឡើយព្រាយមកបង្កើតជាឧត្បាទរ៍នៅក្នុងស្រុកនោះនោះនឹងកើតជាជម្ងឺរលេះរំបល់ជាដើម នឹង បង្កើតជាខ្មោចព្រាយចាំជាន់ប្រុសស្រីទំនាយផ្ទៃក្រោមនឹងពុំសុខសប្បាយឯម្ចាស់ចេក នឹងកើតអំពល់ច្រើន កុំអោយប្រហែសឡើយបើឃើញឧត្បាទរ៍កាលណាហើយ អោយធ្វើរានពីរថ្នាក់នៅក្រោមដើមចេកនោះហើយធ្វើពែចែង៩រូតធ្វើរូបព្រាយ៧កន្ទោង២០ ចំអាប១ស្តក បង្អែម១ស្តក ពែរាយ៨ ច្រមុ៨ដោយជុំរានគ្រប់ ទិសទាំង៨ ធ្វើកំណាល់ស្លាជម៤ ស្លាម្លូរ៩២៧ ស្លាត្រួយ៤ ទៀន៤ សំពត់សរ១ផ្ទត់ហើយធ្វើឆ័ត្ររំយោលជាភ្ញីហើយ នឹងមានសំពត់លឿងបញ្ចពណ៌ប្រេងម្សៅ រួចហើយរកអាចារ្យមកបូជាប្រកក់លាងឧត្បាទរ៍នោះហោងលេងភ្លេងតូរ្យតន្ត្រីយ៍កំសាន្ត ឧត្បាទរ៍នោះនឹងរសាយទៅហោងនឹងកើតសិរីសួស្តីហើយនឹងកើតមាសប្រាក់វិញហោង។បើបូជាហើយនឹងយកចេញពីទីនោះបាន ។

ឯនឹងបូជាដំបូងក្តី កណ្តៀវក្តី ហើយនឹងរំលាយចេញនោះអោយធ្វើពែ៩រូត កន្ទោង១៥ដាក់ បង្អែម ចេក អំពៅ លាជ ហើយបូជាប្រកក់ជូនទៅទិសបូពិ ហើយរំលាយចេញបាន ។

១ទៀតឯកណ្ដៀវពូនក្រោមផ្ទះ ក្ដកក្រោមជង្រុកស្រូវក្ដី លើនរាបលើក្ដារក្ដី អោយគង់នៅបានតែត្រឹម១ឆ្នាំ ៧ខែ យ៉ាងក្រៃ យ៉ាងពេក រំលងអំពីនោះទៅនឹងត្រមប់អោយទោសវិញ កាលទើបនឹងកកើតឡើងអោយយកប្រេងម្សៅទៅលោបរក្សាបូជាទៅហោង ។ កាលនឹងបូជាអោយធ្វើរានពីរថ្នាក់គឺ១ថ្នាក់ ត្រឹបដើមទ្រូង ១ថ្នាក់ទៀត ត្រឹមភ្នែក ហើយចំរាប១ស្លក បង្អែម១ស្លក ទង់៤ឆ័ត្រ ៤ប្រេងម្សៅខ្លស់ ខ្មើយសំពត់គ្រប់ពណ៌ បាយសរបាយក្របាប ស្រូវអង្ករ ។ ឯថ្នាក់ក្រោមមានតែរូត៩ ពៃច្របុះជ្រូក២ ទង់ឆ័ត្រដាក់លើរានពៃចែងកន្ទោង៩ ដាក់ចំរាបពៃច្របុះជ្រូក កន្ទោង៤ ដាក់បង្អែមកន្ទោង១០ទៀត ដាក់ចំណីអោយកប់ក្រោមជើងជណ្ដើរ១កណ្ដាលភូមិ១សល់ក្រៅអំពីនេះ អោយកប់ទិសទាំង៨ពៃរាយ៨ ច្រម៨ អោយដោតទាំង៨ទិសជុំរាននូវស្លាជប សំពត់១ផ្ទត់ ស្រូវ១កញ្ចើ រៀបប្រកក់ប្រសិទ្ធិបូជាលេងភ្លេងតូរ្យតន្ត្រីយ៍នឹងត្រឡប់កើតជាសិរីសួស្ដិ៍វិញហោង ។

សេចក្ដីឧត្បទទាំងឡាយ តាមដែលពោលមកខាងលើនេះលោកថា ទេវតាវរង្គគឺព្រះឥន្ទ្រ១ ព្រះភ្លើង១ ព្រះយម១ ព្រះនារាយណ៍១ ព្រះភិរុណ១ ព្រះពាយ១ ព្រះសោម១ ព្រះពៃស្រពណ៍១ជាអ្នកបណ្ដាលអោយកើតឡើងជាឧត្បាទផ្សេង១គ្នា មកអោយមនុស្សអ្នកដែលទទួលសេចក្ដីឧបទ្រពអន្តរាយនោះ ឃើញជាក់ស្ដែងដោយខ្លួនឯង ។ ក៏ក្នុងឧត្បាទអំបាលនោឧត្បាទណាជារបស់ទេវតាណាបណ្ដាលអោយកើតឡើងរឿងនេះ មានក្បួនញែកប្រភេទទុកដែរ តែឃើញហាក់ដូចជាមិនល្អិតសព្វគ្រប់តាមក្នុងក្បួនឧត្បាទនោះទេជួនកាលក្នុងក្បួនឧត្បាទដែលពោលមក ហើយខាងលើនេះគ្មានឈ្មោះឧត្បាទបែបនោះ ស្រាប់តែមកមានក្នុងបែបញែកប្រភេទនេះក៏មានដែរដូចមានតទៅនេះ -

## «១»ឧត្បាតព្រះឥន្ទ្រ

រន្ទះបាញ់ផ្ទះ_ភូមិ_ក្លោងទ្វារ_រោងសេះ_រោងដំរី_ដើមឈើ ដែលទេព្តារក្ខនៅ_ឥន្ទធ្នូចុះផ្លែកកំឡែក - ស្តេចធ្លាក់ពីព្រះទែនពីសេះពីដំរី_សត្វព្រៃចូលស្រុក_គោញី ញាក់គោឈ្មោល_ដងវែកបាក់នៅដៃ។ល។ជាឧត្បាទព្រះឥន្ទ្រ ។

## «២» ឧត្បាតព្រះភ្លើង

ផែនដីប្រេះកណ្តាលស្រុកស្រុតកណ្តាលនគរខែពរលំពែងព្រះខ័នបាក់ឬឆែបឆាដោយឥតបានហេតុដ៏សមគួរ បានទង្គិចគ្នាឯងដល់ទៅឆែបឆាកណ្តុរបិនខ្លាច បនុស្សចេញបករត់ ច្រវាត់ពេញទាំងផ្ទះ ចេកចេញត្រួយ ឬ ត្រយូងកណ្តាលដើមឬ មានត្រួយមានត្រយូងច្រើនខុសប្រក្រតីរស្មីព្រះចន្ទ្រត្រឡប់ជាក្តៅស្អុះស្អាប់ គិម្ហគ្គរដូវត្រឡប់ជាភ្លៀងផ្គរ ជោរជន់ភ្លើងក្នុងចង្ក្រានគ្មានហើយបណ្តាលឆេះឡើងឯងក្នុងផ្ទះគ្មានភ្លើង តែមើលពីក្រៅឃើញជាពន្លឺភ្លើងវេលាយប់ដេកមិនលក់ អោយរសាប់រសល់ហាបក់ដូចជាមានស្រមោច ស្រមើល ឬ ធូលីធ្លាក់ពាសទាំងខ្លួនសេចក្តីដែលអោយនឿយណាយមិនចង់នៅក្នុងផ្ទះ ។ល។

## «៣» ឧត្បាតព្រះយម

គោក្របីគាប់កំពុងទីមរទេះឬកំពុងព្យួរស្រែសេះជាដើមកូនមកមានក្បាលពីរឬក៏អវះយវះឯទៀតមានខុសប្រក្រតីខ្មោចចោលផ្ទះបានទាំងឮមាត់ស្រែកហៅឬសើចផងស្រមោចឬស្រមើលកើតក្នុងផ្ទះច្រើនពេកសត្វខ្លែងស្រាករលកខ្មោចមាន់ព្រៃ ឈ្លូស ពស់ ឯណាមួយមូលផ្ទះចូលភូមិ ។ល។

## «៤» ឧក្សាធព្រះនារាយណ៍

គង-ស្គរ-រគាំង-ជួង-ស័ង្ខ ឯណានិច្ចយឥតមានគេវាយស្រាប់តែឮឡើងឯងក្នុងខែបួយ មានទាំងសូរិយគ្រាះ ទាំងចន្ទ័គ្រាះទឹកជន់ចករោយឃើញជាពណ៌ក្រហម ដូចជាឈាម គ្រឿងសាស្ត្រាវុធប្រកាប់ប្រចាក់គ្នាឯងត្បាល់រង្រែវាយគ្នាឯងដំបូកដុះនៅផ្ទះព្រះអាទិត្យបាំងឆ័ត្រមានសម្បុរដូចផ្សែងភ្លើង ពោកតវង្សសាងសាស្ត្រាអាវុធគ្រឿងចំបាំងទុកដាក់នៅក្នុងកុដិ ។ល។

## «៥» ឧក្សាធព្រះភិរុណ«ភ្លៀង»

ផ្លែលើដែលធ្លាប់ផ្អែម ត្រឡប់ជាជូរ ភ្លៀងធ្លាក់ជោរជន់ ក្នុងរដ្ឋីរដូវកាល បេយងផឹតរួររាប់ក្នុងរដ្ឋី រដូវកាលបមនុស្សកើតកូនជាសត្វផ្សេង ។ សត្វចិញ្ចឹមកើតកូនជាមនុស្សតិង្គក់ចូលចង្រ្កាន ។ល។

## «៦» ឧក្សាធព្រះពាយ«ខ្យល់»

ខ្យល់ព្យុះខ្លាំងដល់ទៅបាក់ផ្ទះសំបែងនូវព្រៃព្រឹក្សា សត្វម្រឹគបក្សីផ្អើលឆោ ឡោរត់ទីជ្រកកោនពពួនពពានលើគ្នា ឬ ក៏ឃើញប្រាកដជារូបមនុស្សរូបសត្វដំរី-រាជសីហ៍-ខ្លា-សេះ -គ្រុឌ-ក្អែកជាដើមនៅលើផ្ទៃមេឃ ។ល។

## «៧» ឧក្បាធព្រះសោម

ទឹកឃ្មុំទឹករំពៅដែលដាក់ក្នុងដបក្នុងឪទិនជាដើម ពុះដូចជាដាំដោយភ្លើងផ្លែឈើពោះ នេះត្រឡប់ប្រែក្លាយជាផ្លែដទៃ ផ្កៃឡើងកូនលើផ្ទះ - លើទូក -លើសំពៅ ដែលមនុស្សនៅ ឬផ្កៃឡើងដំបូលផ្ទះឮសម្លេងខ្មោច និយាយក្នុងព្រៃកញ្ច្រៀវឡើងចង្ក្រានភ្លើង ជាដើមផ្សិតដុះ នៅចង្ក្រានឬនៅឆ្នាំង ។ល។

## «៨» ឧក្បាធព្រះវៃស្រពណ៍

សំពត់មិនគួរបើកណ្ដុរកាត់ក៏មាកកណ្ដុរកាត់សំពត់ មិនគួរបើនឹងមានភ្លើងឆេះស្រាប់ តែមានភ្លើងឆេះដូង-លូវជា ដើមត្រឡប់ជាគ្មានប្រេងស្រូវត្រឡប់ជាគ្មាន គ្រាប់ប្រាក់មាសទុក នៅក្នុងផ្ទះសុខ១ត្រឡប់ទៅជាឃើញធ្លាក់រាត់រាយនៅទីដទៃរណ្ដើកចូលផ្ទះ ឆ្មាចូលកូន លើដំ ណេករអ្នកម្ចាស់ផ្ទះក្នុងរណ្ដូងមានក្រពើផុសឡើង អង្ករដុះសសរចេញជាហូរលប្ងកដុះក្រោមផ្ទះ បបែលបកងាប់ក្រោមផ្ទះឃ្លាំងទ្រព្យ ក្ដៅរាប់រ្ហួដលទៅបាក់បែកផ្ទះធ្លាយ ។ល។

## ពាក្យស្ដូត្របូជាធេវតា

កាលឧត្បាទអំបាលនោះយ៉ាងឯណានីមួយកើតឡើង បុគ្គលត្រូវការនឹងបូជាទេវតាដែលជាអ្នកបណ្ដាលឧត្បាទអំបាលនោះអោយកើតឡើង ដើម្បីរំងាប់គ្រោះកាចនោះចេញអោយប្រែក្លាយកើតមានតែសេចក្ដីសុខសម្រាន្តវិញសោតត្រូវរៀបគ្រឿងប្រដាប់សម្រាប់បូជាតាមក្បួនតម្រា ហើយគប្បីសូត្របូជាភាសារបស់ខ្លួនឬក៏ នឹងសូត្របូជាទាំងជាភាសារបស់ខ្លួន នឹងភាសាបាលីផងក៏បាន។ក៏រៀបសូត្របូជាជា ភាសាបាលីនោះដូចមានតទៅនេះៈ-

## ពាក្យបូជាព្រះអាទិត្យ

ឳមបុព្វទិសឥន្ទទេវតា សហាគណាបរិវា ភរអាគច្ឆន្តុ បរិភុញ្ជន្តុស្វាហ ។

ឳមសព្វទុក្ខ សព្វលោក សព្វរោគ សព្វឧត្បាទវិនាសសាយ សព្វសត្រូហិមបុច្ឆតិ ។

ឳមឥន្ទទេវតា សទារក្ខន្តុ ស្វាហាយ ។

## ពាក្យបូជាព្រះភ្លើង

ឳមអាគនេយ្យទនសអគ្គនិទេវតា សហាគណាវិវាភា អាគច្ឆន្តុបរិភុញ្ជន្តុ ស្វាហ ។

ឳមសព្វទុក្ខសព្វលោកសព្វរោគ សព្វឧត្បាទវិនាយសព្វត្រូហិបមុច្ឆតិ។

ឳមអគ្គនិទេវតា សទារក្ខន្តុស្វាហាយ ។

## ពាក្យបូជាព្រះយម

ឳមទក្ខិណាទិសយមទេវតា សហាគណាបរិវាភា អាគច្ឆន្តុបរិភុញ្ជន្តុ ស្វាហ ។

ខ្ញុំមសព្វទុក្ខសព្វសោកសព្វរោគ សព្វឧត្បាទវិនាសាយសព្វសត្រូហិបមុច្ចតិ ។

ខ្ញុំមយមទេវតា សទារក្ខន្តុ ស្វាហាយ។

## ពាក្យបូជាព្រះនារាយណ៍

ខ្ញុំមហរិតិទិស នារាយណ៍ទេវតា សហាគណាបរិវារា អាគច្ឆន្តុ បរិភុញ្ជន្តុ ស្វាហ ។

ខ្ញុំមសព្វទុក្ខ សព្វសោកសព្វរោគ សព្វឧត្បាទវិនា សាយសព្វត្រូ ហិបមុច្ចតិ ។

ខ្ញុំមនារាយណ៍ទេវតា សទារក្ខន្តុ ស្វាហាយ ។

## ពាក្យបូជាព្រះភិរុណ

ខ្ញុំមបច្ចិមទិសវរុណទេវតា សហាគណាបរិវារា គច្ឆន្តុបរិញ្ជន្តុស្វាហ ។

ខ្ញុំមសព្វទុក្ខសព្វសោក សព្វរោគ សព្វឧតប្បាទវិនា សាយសព្វសត្រូ ហិបមុច្ចតិ ។

ខ្ញុំមវរុណទេវតា សទារក្ខន្តុ ស្វាហាយ ។

## ពាក្យបូជាព្រះពាយ

ខ្ញុំមពាយទិសវាយោទេវតា សហាគណាបរិវារា អាគច្ឆន្តុ បរិភុញ្ជន្តុស្វាហ ។

ខ្ញុំមសព្វទុក្ខ សព្វសោក សព្វរោគសព្វឧត្បាទវិវិនាសាយ សព្វសត្រូ ហិបមុច្ចតិ ។

ខ្ញុំមវាយោទេវតា សទារក្ខន្តុ ស្វាហាយ ។

## មន្តសម្រាប់បូជាព្រះសោម

ខ្ញុំមឧត្តរទិសសោមទេវតា សហគណបរិវារា អាគច្ឆន្តុ បរិភុញ្ជន្តុ ស្វាហា ។

ខ្ញុំមសព្វទុក្ខ សព្វសោក សព្វរោគ សព្វឧត្បាទវិវិនាសាយ សព្វសត្រូ ហិបមុច្ចតិ ។

ខ្ញុំមសោមទេវតា សទារក្ខន្តុ ស្វាហាយ ។

## មន្តសម្រាប់បូជាព្រះពៃស្រពណ៍

ខ្ញុំមព្សានទិសវេស្សវណ្ណទេវតា សហគណបរិវារា អាគច្ឆន្តុ បរិភុញ្ជន្តុ ស្វាហ ។

ខ្ញុំមសព្វទុក្ខ សព្វសោក សព្វរោគ សព្វឧត្បាទវិវិនាសាយ សព្វសត្រូ ហិបមច្ចតិ ។

ខ្ញុំមសោមទេវតា វេស្សវណ្ណទេវតា សទារក្ខន្តុ ស្វាហាយ ។

# ព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងខែពិសាខ

ទំនៀមច្រត់ព្រះនង្គ័លនេះ ជារាជប្រវេណីរបស់ព្រះមហាក្សត្រ តាំងពីបុរាណកាលមក មិនមែនជាទំនៀមរបស់ព្រាហ្មណ៍តែមិនមែនជារបរចិញ្ចឹមរបស់ក្សត្រដោយត្រង់តែម្តងទេគ្រាន់តែក្សត្រនោះទ្រង់ដំណែងជាម្ចាស់ស្រែទូទៅក្នុងព្រះរាជាណាចក្រ សម្រាប់ចែកចាយទីដីអោយរាស្ត្រធ្វើ ដោយកន្លែង១ រាល់គ្នាទៅតាម ដែលអាចនឹងធ្វើបានសល់ក្រៅអំពីនោះ ទុកជាដីហ្លួង។ កាលរាស្ត្រធ្វើបានផលប្រយោជន៍មកហើយត្រូវបែងផលប្រយោជន៍ ថ្វាយជារាជព្រលឹងដល់ព្រះមហាក្សត្រ ដែលយើងហៅថាថ្វាយសួយសារអាករក្សត្រនោះ ពិតម៉ែនតែបានផលប្រយោជន៍ដែលរាស្ត្របែងធ្វើហើយតែក៏នៅត្រូវធ្វើស្រែបន្តិចបន្តួចអោយគ្រាន់តែជាពិធីដើម្បីជាសិរីមង្គលដល់ការធ្វើស្រែរបស់រាស្ត្រផង ។

ទំនៀមនេះក្សត្រអំពីបុរាណជាច្រើនប្រទេសទ្រង់ធ្លាប់ធ្វើមកហើយ ដូចយ៉ាងក្នុងរឿងរាមកេរ្តិ៍ដំណាលថាគ្រាមួយនោះព្រះបាទជនកព្រះចៅក្រុងមិថិលា ទ្រង់ទៅច្រត់ព្រះនង្គ័លនៅឆ្នេរទន្លេយមុនាទ្រង់រើសបានកូនក្មេងស្រីមួយយកមកចិញ្ចឹមជាព្រះធីតា ព្រះរាជទាននាមថាសិតាតាមហេតុដែលរើសបានក្នុងវេលាកំពុងញួរស្រែ ។វេលាក្រោយមកនាងសិតានោះបានជាមហេសីព្រះរាម ។

ក្នុងរឿងព្រះបឋមសម្ពោធធិកថាដំណាលថាគ្រាមួយនោះព្រះបាទសុទ្ធោទនៈព្រះចៅក្រុងបិលភស្តុនៅក្នុងដែនជម្ពូទ្វីបស្តេចយាងទៅច្រត់ព្រះនង្គ័ល ទ្រង់អោយយកព្រះសិទ្ធត្ថកុមារ១៨ គឺព្រះពុទ្ធអង្គរបស់យើងនេះ កាលនៅជាកុមារតូច « ទៅផង ។ ពួកព្រះស្នំមេនំរៀបគ្រែនឹងបិទបាំងវាំងននអោយផ្ទុំក្រោមដើមព្រីងហើយ នាំគ្នាចេញទៅមើលស្តេចច្រត់ព្រះនង្គ័ល ។

គ្រានោះរាជកុមារក្រោចឡើងគង់ពៃនភ្នែនចំរើនសមាធិ ក៏អណ្តែតទាំងព្រះអង្គទៅស្ថិតនៅលើចុងដើមព្រីង។ ពួកនាងព្រះស្នំបេនំត្រឡប់មកវិញមិនឃើញព្រះកុមារក៏ផ្អើលនោឡោឡើងនាំគ្នារត់ទៅឃើញអណ្តែតនៅលើដើមព្រីង ។ព្រះបាទសុទ្ធោទនះស្តេចមកថ្វាយបង្គំព្រះរាជបុត្រហើយហើយ១៩ព្រះរាជកុមារទើបស្តេចយាងចុះមក ។

ក្នុងសេចក្តីកត់ហេតុរបស់ចិននិយាយ អំពីទំនៀមទម្លាប់ចិនថា ក្នុងសម័យរវាងបួនពាន់ឆ្នាំកន្លងទៅហើយនោះកាលដល់រដូវធ្វើស្រែព្រះរាជាម្ចាស់ផែនដីចេញ ច្រត់ព្រះនង្គ័លព្រះអគ្គមហេសីចិញ្ចឹមនាង ។ រឿងអំបាលនេះនាំមកសំដែង ដើម្បីអោយឃើញការច្រត់ព្រះនង្គ័លជារាជប្រវេណីរបស់ព្រះមហាក្សត្រអំពីបុរាណរៀងមកហើយមិនតែក្នុងប្រទេសកម្ពុជានេះទេប្រទេសប្រទេសដ៏ទៃក៏មានពិធីច្រត់ព្រះនង្គ័លដែរ ។ ក្នុងជាន់ដើមនោះព្រះមហាក្សត្រទ្រង់ ច្រត់ដោយអង្គឯងតែម្តងដូចពោលមកហើយខាងលើនោះ លុះអំណរតមកកក្សត្រទាំងឡាយក្នុងប្រទេសផ្សេងៗដែលកាន់តាមទំនៀមនោះ ទ្រង់ច្រត់ដោយអង្គឯង ក៏មានទ្រង់អោយព្រះរាជវង្សាឬមន្ត្រីដែលមានបណ្តាស័ក្តិធំដូចយ៉ាងមន្ត្រី ដែលជាអធិបតីក្នុងក្រសួងក្សេត្រាធិការឬស្តេចមាយជាដើមក៏មានទំនៀមក្នុងប្រទេសកម្ពុជាយើង ក៏មានអនុវត្តន៍ទៅតាមលំអាននោះមកហើយដែរគឺក្នុងសម័យជាន់ដើម ដែលស្តេចគង់នៅក្រុងនគរធំនោះប្រហែលជាទ្រង់ច្រត់ព្រះនង្គ័លដោយព្រះអង្គឯងព្រោះក្នុងវេលានោះនៅកាន់ទំនៀម ដើមព្រីងតមកក្នុងសម័យកណ្តាល ប្រហែលជាទ្រង់ច្រត់ដោយព្រះអង្គឯងខ្លះ ទ្រង់អោយជំនួសខ្លះដល់មកសម័យបច្ចុប្បន្ននេះទ្រង់អោយជំនួសព្រះអង្គរាល់ ៧ ឆ្នាំ ។

កាលដែលព្រះមហាក្សត្រ ចេញទ្រង់ច្រត់ព្រះនង្គ័លដោយព្រះអង្គឯងនោះដើម្បីជាតួយ៉ាងដល់អ្នកនគរព្រោះព្រះអង្គទ្រង់ដំណែងជាអធិបតី ក្នុងការធ្វើស្រែត្រូវផ្តើមធ្វើការនោះ

ជាដំបូងអោយអ្នកទាំងពពួងយល់យ៉ាងតាមនឹង ដើម្បីជាការស័ក្តសិទ្ធិដល់ការធ្វើស្រែរបស់អ្នកនគរផងព្រោះព្រះមហាក្សត្រម្ចាស់ផែនដីនោះ ជាអ្នកមានបុណ្យបារមីធំកាលស្តេចចេញច្រត់ព្រះនង្គ័ល ហើយគង់ជាបំនួលដល់វណណកទេវបុត្រដែលជាទេវតាប្រចាំភ្លៀង ក៏នឹងបណ្តាលអោយភ្លៀងធ្លាក់ចុះមកត្រូវតាមរដូវកាលជាហេតុអោយធញ្ញជាតិមានផលបរិបូណ៌ជាប្រយោជន៍បានជាអាហារចិញ្ចឹមជីវិតនឹងចំរើនសម្បត្តិរបស់អ្នកនគរ ។

ហេតុនេះ កាលព្រះមហាក្សត្រអង្គឯណាមួយមិនទ្រង់ចេញច្រត់ដោយព្រះអង្គឯងដោយមានព្រះរាជធុរៈដូចម្តេចក្តី ឬ ដោយមានព្រះរាជបំណងដូចម្តេចក្តី នោះត្រូវតែងតាំង ព្រះរាជវង្ស ឬ មន្ត្រីអ្នកមានបណ្តាស័ក្តិធំចេញទៅច្រត់ព្រះនង្គ័ល ជំនួសព្រះអង្គ ដើម្បីនឹងអោយការនោះ សក្តិសិទ្ធិដូចយ៉ាងដែលចេញច្រត់ដោយព្រះអង្គឯង ដោយហេតុនេះទើបទ្រង់បន្ថយព្រះរាជឥស្សរិយយសព្រះរាជអំណាចច្រត់ ប្រការខ្លះចេញ គឺក្នុងរវាងបីថ្ងៃ ឬ ប្រាំពីរថ្ងៃដែលជាថ្ងៃធ្វើព្រះរាជពិធីច្រត់ព្រះនង្គ័លនោះ ទ្រង់បន្ថយព្រះរាជឥស្សរិយយសចេញមិនទ្រង់សំរេចការផែនដីផ្សេងៗទ្រង់គង់ចាំសីលស្ងៀមតែក្នុងព្រះបរមរាជវាំង មិនតែប៉ុណ្ណោះទ្រង់ព្រះរាជទានអំណាចគ្រប់ប្រការ ខ្លះអោយអ្នកតំណាងព្រះអង្គអោយមានឫទ្ធិមាំអំណាចឡើងដូចយ៉ាងស្តេច ផែនដីមែនៗគឺទ្រង់ព្រះរាជទានព្រះខ័នរាជ្យអោយអ្នកនោះកាន់ក្នុងវេលាហែទៅច្រត់ព្រះនង្គ័លនឹងទ្រង់ព្រះរាជទានសួយសារអាករប្រការខ្លះ គឺចំពោះតែបណ្តាសួយសារអាករដែលមាននៅក្នុងទីក្រុងអោយអ្នកនោះមានអំណាចហូតយកភាសីអំពីពួកឈ្មួញគ្រប់ជំពូកដែលលក់ដូរតាមផ្សារនៅទីក្រុង នឹង អំពីពួកឈ្មួញរទេះទូកសំពៅជាដើមដែលមកអំពីទិសផ្សេងៗ មកដល់ដូរនៅទីក្រុងក្រៅអំពីនេះគង់នៅជារបស់ព្រះរាជទ្រព្យដូចដើមហើយកំណត់អោយហូតបានតែក្នុងរវាងបីថ្ងៃឬប្រាំពីរថ្ងៃប៉ុណ្ណោះហួសថ្ងៃនោះទៅផុតអំណាច ។

កាលដល់រដូវនោះហើយ មានក្រុមស្នួយសារាករចេញទៅប្រកាសប្រាប់អ្នកផ្សាយអោយដឹងជាមុន ។ ចំណែកឯស្តេចទាយកាលដល់ថ្ងៃដែលព្រះរាជទានរំណាចនោះហើយក៏តែងក៏តែងតាំងចំណាយរបស់ខ្លួនជាស្រីខ្លះប្រុសខ្លះអោយចេញទៅហូតពន្ធតាមទំនៀមដែលរាជាធ្លាប់ហូតមករំពីដើមតែសេចក្តីលោភរបស់មនុស្សរមែងមានជាធម្មតា កាលបានរំណាចនោះមកហើយរមែងកាន់យករំណាចនោះទៅកំហែងអ្នកឈ្មួញហូតពន្ធយកថ្លៃ ហួសព្រះរាជកំណត់ពេកតែជាហេតុអោយកើតវិវាទគ្នាជារាល់ឆ្នាំ តែរមែងកាន់យកចាញ់ពួកអ្នកហូតពន្ធជាធម្មតាទំនៀមនេះមានមករហូតដល់រជ្ជកាលព្រះករុណាព្រះបរមកោដ្ឋ ហើយឈប់លើកលែងព្រះរាជទានរំណាចយ៉ាង នេះតាំងរំពីរជ្ជកាលនោះមកដល់រជ្ជកាលបច្ចុប្បន្ន មិនតែឈប់រឿងព្រះរាជទានរំណាចអោយហូតពន្ធប៉ុណ្ណោះ បានឈប់ទាំងការព្រះរាជទានព្រះខ័នរាជ្យ អោយកាន់ក្នុងវេលាហែទៅច្រត់ព្រះនង្គ័លនោះផងសព្វថ្ងៃនេះអ្នកជំនួសព្រះអង្គ នៅមានតែរំណាចទាំងពួងលើកលែងព្រះរាជទានអស់ហើយ ដោយហេតុសេចក្តីគ្រប់គ្រងរបស់លោករមែងប្រែប្រួលទៅតាមសម័យមិនចំពោះតែប្រទេសកម្ពុជានេះទេប្រទេសទាំងឡាយដែលកាន់ទំនៀមនេះក៏ឈប់ព្រះរាជទានរំណាចអស់ហើយដូចគ្នា ។

ពិធីច្រត់ព្រះនង្គ័លនោះមានទំនៀមរើសរកឫក្សល្អ ថ្ងៃល្អដែរ តែក្នុងជាន់ដើមឯណោះវាមានទំនៀមដូច្នេះដែរ ឬ ទេមិនអាចដឹងបានជាប្រាកដតែបើសង្កេតមើល ក្នុងរឿងរាមកេរ្តិ៍ដែលតែងជាភាសាខ្មែរគ្រង់រឿង ដែលព្រះបាទជនកច្រត់ព្រះនង្គ័លនោះថា « ដងនោះព្រះបាទមិថិលាស្តេចធ្វើចរិយាបីដោយនូវក្រិតដ៏ពិធី។លុះពិសាខសុភតិត្ថិផ្ដុំមុខមន្ត្រី ប្រយោជន៍នូវប្រែពសុធា ។ដើម្បីនូវធ្វើអោយក្សេមដ៏ប្រជារាស្ត្រ រដ្ឋដោយធាក្រិតាធិការដ៏បុរាណ » ។ ស្តាប់មើលតាមពាក្យនេះ ឃើញថា រើសរកឫក្សសុភតិត្ថិដែរ ឬ មួយក្នុងជាន់នោះមិនបានរើស

រកឫក្សទេតែអ្នកតែងរឿងនេះតែងបង្ហានទៅតាមទំនៀមទម្លាប់ក្នុងប្រទេសរបស់ខ្លួនក៏មិនអាចដឹងបានៗក៏បើកក្បួន មើលឫក្សក្នុងឱកាសធ្វើស្រែ តាមទំនៀមបុរាណនោះលោកកំណត់ទុកអោយបានឫក្សបួនយ៉ាង គឺ ១អោយចៀសចាកឫក្សអាក្រក់ដែលហៅថាឫក្សខ្មោចស៊ីមនុស្ស ២អោយបានតែក្នុងឫក្សសុភតិត្ថិគឺថ្ងៃល្អ ៣ អោយបានតែក្នុងបណ្ណឫក្សគឺឫក្សពេញ ៤អោយបានតែក្នុងថ្ងៃសម្ភគ្រោះហ៍ឫក្សតិត្ថិខាងអាក្រក់ « ដែលថាខ្មោចស៊ីមនុស្ស»នោះខាងកើតគឺថ្ងៃ ១,៥,៧,៨,៩,១០,១១,១៥កើត ។ ខាងរនោចគឺ្ល១,៥,៦,៧,៨,១០,១៣,១៤រោច ថ្ងៃអំបាលនេះប្រើមិនបានអោយវៀរចេញ។ឫក្សសុភតិត្ថិគឺឫក្សដែលប្លតចាកឫក្សអាក្រក់ដែលពោលមកហើយនោះ។ណ្ណឫក្សនោះគឺឫក្ស២,៤,៥,៦,៨,១១,១៤,១៧,២២,២៤,២៦,២៧ ។ថ្ងៃសម្ភគ្រោះហ៍នោះគឺថ្ងៃច័ន្ទ ពុធ ព្រហស្បត៍សុក្រ នឹង កំណត់យកធាតុមួយយ៉ាងទៀត តាមថ្ងៃដែល ហោរចែកជាបថវីអាបោតេជោវាយោអោយបានភាគគ្នាហើយទុកជាប្រើបាន។ក្បួននេះមិនចំពោះមើលឫក្សភ្ជួរស្រែប៉ុណ្ណោះទេ មើលឫក្សសាបព្រួស ស្ទូង ច្រូត នឹងជញ្ជូនស្រូវដាក់ជង្រុកទៀតផងក៏បាន។ តែតាមក្នុងក្បួនព្រហ្មជាតិមានន័យខុសគ្នាខ្លះ និង ក្បួនដែលពោលមកហើយខាងលើនេះខ្លះ គឺ ថ្ងៃអាទិត្យអោយផ្ដើមភ្ជួរស្រែល្អ ថ្ងៃច័ន្ទអោយផ្ដើមសាបព្រួសល្អ ថ្ងៃអង្គារ៍អោយផ្ដើមបកព្រើងស្រូវល្អថ្ងៃ ពុធ នឹង សៅរ៍ អោយផ្ដើមធ្វើលានស្រូវលថ្ងៃព្រហស្បត៍អោយផ្ដើមជញ្ជូនស្រូវដាក់លានថ្ងៃច័ន្ទ និងពុធអោយផ្ដើមបោកបែនស្រូវល្អ ។ ក្បួនក្រោយនេះជាទំនៀមទម្លាប់របស់រាស្ត្រក្បួនទាំងពីរនេះជាក្បួនរោយរាយហើយមានតាំងអំពីបុរាណកាលមកដែរ តែកមដល់សម័យនេះគេលើកលែងកាន់ជាច្រើនណាស់ទៅហើយ ។

របៀបច្រត់ព្រះនង្គ័លបែបក្បួនបុរាណ ដែលក្រុមបារគូបរោហិតរក្សាទុកមាននៅដរាបតរៀថ្ងៃនេះនិយាយដោយសង្ខេបថា:

« ខែពិសាខ បើព្រះបាទអ្នកជាអម្ចាស់នឹងរៀបច្រត់ព្រះនង្គ័លនោះ » ត្រូវធ្វើរោងមណ្ឌល៥នៅទីព្រះស្រែ«អោយចៅហ្វាយឃ្លាំងមណីរតនៈដាក់ប្រាក់ដង្វាយទេវតា ដំឡឹង៥គ្រប់មណ្ឌលទាំងប្រាំ ទៀនធំមួយទម្ងន់ដំឡឹង៥ទៀនបៃរបក២៥ទៀន ត្រែង៦០ធូបសំណុំ៣អោយរៀបដូច្នេះគ្រប់មណ្ឌលទាំងប្រាំនឹងរៀបកន្ទេលពីរថ្លាងពីរក្អមពីរដាក់គ្រប់រោងទាំងប្រាំ ។ ចៅហ្វាយឃ្លាំងកោសៃយរាស្ត្រអោយដាក់សំពត់ ក្រាលអាសនៈ អាវពីរ សំពត់វាន់បំពុងអាវប្អូរសំពត់ថ្វាយអ្នកតាអាវ៨ឆ្នេង៤ស្លាំ៤ កន្ទេល២ ស្លាធមិ៨ ស្លាត្រួយ១០ ជម២ដង ឡៀ ១ល្ង. សណ្តែកកន្ទោង១អោយរៀបដាក់គ្រប់រោងមណ្ឌលទាំង៥ ក្នុងរោងមណ្ឌលមួយៗមានចំនួនដូចពោលមកនេះហើយត្រូវរៀបតាំងគ្រប់៣ថ្ងៃ។ ឯចៅហ្វាយឃ្លាំងភោជន៍សាលីអោយដាក់ផ្លែបើតោក៨មានអង្ករទ្រាប់ក្រោមបាយបញ្ចតាប?សម្រាប់មួយបាយសី៦០លាជ ៣នប្លួយប្បៀកន្ទោងមួយរបស់អំបាលនេះអោយរៀបតាំងដូចគ្នាគ្រប់មណ្ឌលទាំង៥ តាំងគ្រប់បីថ្ងៃ » ។ចូរបើយថ្ងៃច្រត់ព្រះនង្គ័លស្តេចមាយចេញច្រត់ព្រះនង្គ័លនឹងផ្សងគោឧសុភរាជ អោយស៊ីរបស់៧យ៉ាងដូចពោលទៅខាងមុខ ។

ឯទំនៀមទម្លាប់នឹងរបៀបដែលធ្វើក្នុងសម័យបច្ចុប្បន្ននេះ រៀបរៀងតាមសេចក្តីកត់ហេតុកម្មវិធីដែលធ្វើសព្វឆ្នាំនោះគឺមុនថ្ងៃ១រោចខែពិសាខ ចៅភ្នាក់ងារក្រុមមេការត្រូវរៀបធ្វើរោងមណ្ឌល ពិធីនៅទីព្រះស្រែអន្លើគឺនៅត្រង់ទិសបូពិ១ ត្រង់ទិសអគ្នេយ៍១ ត្រង់ទិសនិរតី១ត្រង់ទិសពាយ័ព្យ១ត្រង់ទិសឦសាន១រោងមួយៗទំហំទទឹងពីរហត្ថកន្លះបណ្តោយបួនហត្ថក្រាលរនាបជញ្ជាំងផ្តល់ប្រក់ស្លឹក ។

នឹងធ្វើព្រះពន្លាមួយខ្នងទទឹង១៤ហត្ថបណ្តោយ៦ហត្ថពាស់សំពត់បាំងដោយសំពត់វាំងននរៀបតាំងកៅអីព្រះទីនាំងនឹងកៅអីសម្រាប់ខ្ញុំរាជការនឹងប្រជាប់ដោយទង់ផ្សេងៗតាមសមគួរ ។

រោងទិសបូពិ ជាភ្នាក់សេនាបតីទី១ រៀបចំតែងតាំង

រោងទិសអគ្នេយ៍ ជាភ្នាក់សេនាបតីទី២ រៀបតែងតាំង

រោងទិសនិរតី ជាភ្នាក់សេនាបតីទី៣ រៀបតែងតាំង

រោងទិសពាយ័ព្យ ជាភ្នាក់សេនាបតីទី៤ រៀបតែងតាំង

រោងទិសឦសាន ជាភ្នាក់សេនាបតីទី៥ រៀបតែងតាំង

ដល់ថ្ងៃ១រោចខែពិសាខ ត្រូវព្រាហ្មណ៍បរោហិតនិមន្តទៅរូបទៅតាំងនៅរោងទាំងប្រាំ ៥ ហើយធ្វើហោមពិធី៣ថ្ងៃតាមរបៀបព្រាហ្មណ៍ គឺរោងទិសបូពិត្រូវព្រះរាជគ្រូនិមន្តព្រះកច្ចាយន៍ទៅតាំងនិងធ្វើហោមពិធីរោងទិសនិរតីត្រូវព្រះជៃយាធិបតីនិមន្តព្រះចន្ទីទៅតាំងនឹងធ្វើហោមពិធី រោងទិសពាយ័ព្យត្រូវព្រះចិន្ទធិបតីនិមន្តព្រះឥសូរទៅតាំងនឹងធ្វើហោមពិធី រោងទិសឦសានត្រូវព្រះកប្បរាជធិបតីនិមន្តព្រះពិឃណោ ទៅតាំងនឹងធ្វើហោមពិធីគឺ នៅវេលារសៀលម៉ោង៥ ព្រាហ្មណ៍រំបាលនោះរៀបសែនក្រុងពលីនិងពលីការទេវតារួចហើយទើបចូលតាំងធ្វើហោមពិធី ២០គ្រប់រោង ទាំងប្រាំដ៏រាបគ្រប់បីថ្ងៃ ។

ដល់គ្រប់បីថ្ងៃហើយវេលាព្រឹករវាងម៉ោង៧ ព្រះករុណាស្តេចចេញច្រត់ព្រះនង្គ័លដោយក្បួនហែតែសម័យនេះមិនដែលស្តេចច្រត់ដោយព្រះអង្គឯងទេច្រើនតែជំនួសព្រះអង្គឯអ្នកជំនួសព្រះអង្គ ក្នុងការនេះច្រើនយកស្តេចមាឃ២១ពុំនោះ សោតក៏យកឧកញ្ញាពហុលទេពអធិបតីក្រុមក្រុមព្រាធិការអ្នកដំណាងនេះ បើតាមសេចក្តីប្រាវព្ធទោះបីមិនមែនជាស្តេចក្នុងពេលនោះក៏ត្រូវហៅថា«ស្តេច» ដើម្បីនឹងអោយការ ដែលធ្វើទៅនោះស័ក្តិសិទ្ធិដូចពោលមកហើយខាងដើមទំនៀមនេះច្រើនប្រើស្តេចមាឃជំនួសព្រះអង្គហេតុនេះទោះបីអ្នកដទៃជំនួសព្រះអង្គ គេក៏ច្រើនហៅអ្នកនោះថាស្តេចមាឃ២២ ។ វេលានោះស្តេចដំណាងនោះតែងខ្លួនតាមរបៀបបុរាណពាក់

អាវពណ៌ក្រហមពាក់មួកប្រពាតភរិយាស្តេចដំណាងនោះសន្មត់ជាព្រះទេពីហៅថា ព្រះមេហ្វតែងខ្លួនតាមរបៀបបុរាណ គឺស្លៀកសំឡុយពាក់អាវបំពង់វែងដល់វេលាស្តេចដំណាងជិះសាលៀងនាងព្រះមេហ្វជិះអង្រឹងហែរចេញពីព្រះបរមរាជវាំងដោយក្បួនហែ គឺភ្លេងពិណពាទ្យមួយវង់ហែរមុខនឹងមនុស្សអ្នកហែប្រមាណ៥០នាក់ ហែរទៅកាន់ទីព្រះស្រែ វេលានោះព្រះករុណាក៏ស្តេចយាងទៅនគង់នៅព្រះពន្លាដើម្បីទតព្រះនេត្រច្រត់ព្រះនង្គ័លជួបជុំដោយព្រះរាជវង្សានុវង្សនឹងសេនាបតីមន្ត្រី ធំតូចជាច្រើនជួនកាល មិនស្តេចចេញទ្រង់ព្រះមេត្តាប្រោស អោយព្រះរាជវង្សអង្គណាមួយជំនួសព្រះអង្គ និយាយតាមសម័យនេះលោកឡឺវេស៊ីដង់សុប៉េរីយើរ៍ឬក៏អ្នកដំណាងអញ្ជើញមកដែរ ។ កាលទៅដល់ព្រះស្រែហើយស្តេចមាឃនឹងព្រះមេហ្វចូលទៅថ្វាយបង្គំទេវរូបនៅរោងមណ្ឌលទិសនិរតីរួចចេញច្រត់ព្រះនង្គ័ល មាននង្គ័លយោងមុខមួយនង្គ័លតាមក្រោយមួយព្រះមេហ្វដើរតាមក្រោយមកទៀត ចាប់ស្រូវពូជនៅកញ្ច្រែងដែលស្រីម្នាក់ទៀតកណ្តៀតបាចទៅឆ្វេងទៅស្តាំច្រត់គ្រប់បីជុំព្រះស្រែហើយ ព្រះនង្គ័លទៅឈប់ទៀបរោងមណ្ឌលទិសបូព៌ស្តេចមាឃចូលថ្វាយបង្គំទេវរូបនៅរោងមណ្ឌលនោះហើយ ចេញមកលំដាប់នោះក្រុមបុរោហិតសូត្រពាក្យអធិដ្ឋានផ្សងឧសភរាជដែលទឹមច្រត់ព្រះនង្គ័ល អោយស៊ីរបស់៧យ៉ាងដែលចៅភ្នាក់ងាររៀបដាក់តុប្រាក់តាំងទុកនៅទីមុខព្រះពន្លាសូត្រចប់ហើយក៏ដឹកគោអោយស៊ីរបស់អំបាលនោះគឺទឹកមួយតុគ្រាប់ស្រូវមួយតុ គ្រាប់សណ្តែកមួយតុ គ្រាប់ពោតមួយតុ គ្រាប់ល្ងរមួយតុស្មៅស្រស់មួយតុស្រាមួយតុ។បើគោស៊ីរបស់អ្វីឬផឹកទឹកនោះ ត្រូវព្រាហ្មណ៍ទំនាយផលរបស់វត្ថុនោះទំនៀមទំនាយនោះសម្បូរប្លែកតែបើស៊ីស្មៅទំនាយថានឹងកើតជម្ងឺគោ ។ បើផឹកស្រាត្រូវទំនាយថាក្នុងឆ្នាំនោះនឹងកើតមានមនុស្សពាលមនុស្សស្រវឹងស្រានឹងចោរលួចប្លន់ច្រើន។ ក្រោយពីនោះទៅរាស្ត្រ អ្នកនគរទើបនាំគ្នាធ្វើស្រែរបស់ខ្លួន តទៅតាមទំនៀម ។ - .

# កំណត់ហេតុ

១- អ្នកខ្លះគេរៀបសូត្រនៅទីសង់ផ្ទះហើយទើបសែនក្រុងពលី

២- ជួនកាលអ្នកខ្លះគេរៀបសូត្រមន្តនៅទីសង់ផ្ទះហើយ ទើបសែនក្រុងពលីជាក្រោយ។

៣- ពលីជាឈ្មោះស្តេចយក្ខ១ តែងមានរិទ្ធគេថា ជាម្ចាស់ទឹកម្ចាស់ដីចូលរមឹលក្នុង រឿងនារាយណាវការ ។

៤- ពាក្យនេះចម្លងមកច្រើនតហើយគង់ជាខុសឃ្លៀងឃ្លាតច្រើន ។

៥- បើធ្វើការក្រៅអំពីសង់ផ្ទះមានមង្គលការជាដើមអោយថាចេញឈ្មោះការនោះ។

៦- បើធ្វើការក្រៅពីសង់ផ្ទះអោយថាចេញឈ្មោះការនោះ ។

៧- ខ្មោចអារក្ខនេះមានភាសាហៅឈ្មោះរបស់ នឹងហៅមនុស្សជំពូកខ្លះផ្សេង ពីមនុស្សយើងដូចយ៉ាងកូនសិស្សបើមនុស្សធំហៅថាផ្កាឈូកបើក្មេងតូចហៅ ថាកូនចាបលោកសង្ឃហៅថា តាបុណ្យផ្លែចេកហៅថាក្រទន់បាក់គណ្ឌ៏ប្រាក់ ហៅថាក្រប៉ាងអ្នកសួរយកការខ្មោចហោថាស្នំ ។ល។

៨- ចូរមើលសេចក្តីពិស្តារក្នុងរឿងសាសនា ប្រវត្តិរបស់ព្រះមហាពិធូក្រសេម ដែលបោះពុម្ពនៅព្រះរាជបណ្ណាល័យ ។

៩- ព្រះពោធិវង្សថេរតែងទុកជាភាសារអមកធ :និយាយពីពង្សាវតារស្រុក ហរិភុញ្ជ័យ ។

១០- ជាប់ជាទំនៀមមកដល់សព្វថ្ងៃនេះ អ្នកដែលថ្វាយមាន់ដល់អ្នកតាច្រើនតែ

យកមាន់សទៅថ្វាយ ។

១១. ចូរមើលសាស្ត្រាប្រណិធានដែលសម្រាប់សូត្រស្បថ នៅសាលាតុលាការសព្វថ្ងៃនេះ ។

១២. ជូនកាលគេធ្វើពែមឈូស១ទៀតផងដូចពោលហើយក្នុងរឿងបណ្ដោះគ្រោះ។

១៣. សេនាទាហានជើងទឹកក៏មានប្រជុំបង្វិកបង្កាន់ដែរតែគេធ្វើក្នុងខែកក្ដិក ។

១៤. ផ្កាច្រាលសគឺផ្កាពណិក្រហមនឹងពណិស ។

១៥. មេត្រីជាឈ្មោះទិព្វមន្តគឺមហាមេត្រី ។

១៦. សន្ទីយ៍ប្រែថាយប់ ។

១៧. មានពាក្យសម្រាប់សូត្របូជាថ្វាយទេវតាដូចមានសំដែងទុកខាងក្រោយ ។

១៨. ព្រះសិទ្ធត្ថកុមារប្រសូតិមុនពុទ្ធសករាជ៨០ឆ្នាំគិតពីនោះមកដល់ឥឡូវនេះត្រូវជា២៥៥០ប្លាយឆ្នាំហើយ ។

១៩. ព្រះបាទសុទ្ធោទនជាបិតាទ្រង់សំពះព្រះរាជបុត្រក្នុងគ្រានេះជាដំបូងដោយទ្រង់ឃើញថាជាមនុស្សមានបុណ្យអស្ចារ្យណាស់ ។

២០. របៀបធ្វើហោមពិធីនឹងពោលពិស្ដារក្នុងរឿងព្រះរាជពិធីសម្រាប់ខែផល្គុន ។

២១. រឿងស្ដេចហោរនឹងរោនពោលល្អិតក្នុងរឿងព្រះរាជពិធីសម្រាប់ខែមាឃ ។

២២. រឿងស្ដេចហោរនឹងរោនពោលក្នុងព្រះរាជពិធីដុតភ្នំស្រូវ ។

២៣. ដើរស្បៀទុកជាឯកតា រយើងសូមបន្ថែមនូវអត្ថបទស្ដីពីក្រុងពារាណសីដែលបាន

ប្រារព្ធធ្វើឡើងនៅជំរំដារីដ្ឋនៅឆ្នាំ១៩៨៣ៈ

# អក្ខបទសែនក្រុងពាលី

«១. ថ្ងៃនេះថ្ងៃជា ពេលាល្អបា ន ជួបជុំសន្តា ន អស់ទាំងប្រុសស្រី
រៀបចំពលីការ អាហារចំណី គ្រប់ស្លកប្រាំបី លៃលកគ្រប់មុខ ។

២. បង្អែមចំរាប រៀបតាមរបៀប ចងចាំដាក់ទុក បើមានខ្វះខាត
សូមតែក្តីសុខ ទៀនធូបនេះទុក ជាគ្រឿងពលីការ ។

៣. ខ្ញុំសូមអញ្ជើញ យាងមកទតឃើញ ពលីការនេះណា ស្តេចក្រុងពាលី
មានរិទ្ធិចេស្តា ទាំងនាងលក្ខិណា នាងហ៊ីងធរណី ។

៤. ខ្ញុំសូមរំលឹក ដល់ព្រះគុណធំត្រួអង្គព្រះព្រហ្ម មានគុណតេជះ
ច្បាស់មានរិទ្ធិ ជាទីខ្លបខ្លាច អំណាចខ្លាំងក្រៃ ។

៥. សក្កៈទេវរាជ លោកមានអំណាច ឥន្ទកោសិយ ចតុលោកបាល
ទាំងបួននោះនៃ រិទ្ធីខ្លាំងក្រៃ លើអស់ទេវតា ។

៦. ទាំងលោកមានរិទ្ធិ ច្បាស់ៗពិតៗ មហាអស្ចារ្យ លោកតាបាំងបាត់
អារក្ខអ្នកតា នៅស្រែចំការ ទីវាភាបស្មើ ។

៧. នៅទីជ្រោះជ្រង ព្រៃជ្រៅហាត់ហោង ខ្ពស់ស្រោងទៅលើ
គិរីបពិត នោះហ្មំហើយតើ ផ្លូវភ្នំដងរែក ។

៨. ភ្នំស្រួចភ្នំស្រង់ ខ្ពស់ត្រដែងត្រង់ នោះខ្ពស់ចម្លែក ឯភ្នំក្រវាញ
វែងខ្ពស់ពន់ពេក ចម្លែកខ្លាំងណាស់ នៅភ្នំកំចាយ ។

៩. ដីររមាល នៅចំទីវាល ក៏ល្អឆើតឆាយ មានប្រាង្គប្រាសាទ
នៅជិតមិនឆ្ងាយ សប្បាយខ្លាំងណាស់ ហៅភ្នំជីសូរ ។

១០. មានរូបចម្លាក់ បុរាណលោកឆ្លាក់ ទុកជាគំរូ អ្នកខ្លាំងពូកែ
លោកអ្នកតស៊ូ មានមកយាយូ ហៅភ្នំសន្ទុក ។

១១. វត្ថុស័ក្តិសិទ្ធិ មានប្លែកពិត១ មានទាំងគ្រប់មុខ អ្នកស្វែងរកធមិ
ប្រាថ្នាយកសុខ គឺមានគ្រប់មុខ ហៅភ្នំគូលេន ។

១២. ប្រាសាទអង្គរ ខ្ពស់ធំជ្រងោ ក្បាច់ក្បូរពន់ពេក មានកំពូលប្រាំ
នោះល្អមែនទែន ល្បីប្រាកដមែន លើសាកលលោក ។

១៣. លោកមានរិទ្ធី ពូកែពេញទី សូមអញ្ជើញមក តាផងឃ្លាំងមឿង
លោកមានជ័យជោគ សូមអញ្ជើញមក នៅទីនោះណា ។

១៤. អស់លោកមុនីរតន៍ រិទ្ធិឆ្នើមប្រាកដ មហាអស្ចារ្យ នាងពៅពណ្ណរាយ
នោះទៀតឯងណា រិទ្ធីចេស្តា សែនអស្ចារ្យក្រៃ ។

១៥. លោកក្រហមក ទាំងលោកតេជោ ពីរនោះឯងនៃ លោកដំបងដែក
សីឯសុទ្ធតែល្បី ឯប្អូននោះនៃ គឺលោកតាឃ្លង់ ។

១៦. នាងចេកនាងចម សេនាហៃហាម រឿងរិទ្ធីរុង បើបានឮហើយ
សូមកុំបង្អង់ អញ្ជើញស្មោះត្រង់ កាន់ទីនេះណា ។

១៧. អស់លោកដទៃ សូមលោកអភ័យ កុំយកទោសា ព្រោះពុំបានរាប់
សព្វគ្រប់ឡើយណា សូមលោកមេត្តា អញ្ជើញទាំងអស់ ។

១៨. យើងខ្ញុំរៀបចំ ពលីការចេកនំ មិនអោយមានទាស់ ជ្រូកក្បាលប្រាំបី

ចំណីសព្វមុខ រៀបចំដាក់ទុក ជាគ្រឿងពលីការ ។

១៩. អុជធូបអុជទៀន ដប់ទិសក៏មាន ព្រោងព្រាតភ្ញីផ្កា សូមទទួលយក
នូវគ្រឿងពលីការ ចំណីអាហារ សូមសុខសួស្តី ។

២០. យើងខ្ញុំលើកសង់ នូវគ្រឿងសំណង់ នូវសំណាក់ថ្មី ថ្វាយអង្គសម្តេច
ធនធិបតី ស្តេចគ្រគងទឹកដី រដ្ឋកម្ពុជាយើង ។

២១. សូមបានក្តីសុខ ជោគជ័យគ្រប់មុខ សម្តេចឪយើង កុំអោយមានទុក្ខ
គ្រោះថ្នាក់កើតឡើង ឯករាជ្យថ្កុំថ្កើង តរៀងទៅហោង ។

២២. ជ័យយោៈជ័យ ថ្ងៃសៅរ៍ លើកតំណាក់ ថ្វាយសម្តេចឪ
ពេលាបានមែនហោង មែន បានធ្វើបន្ទាល់ ហ៊ោង ។

២៣. ថ្ងៃនេះថ្ងៃជា ពេលាឧត្តម លោកមកជួបជុំ សេពសោយអាហារ
មានឱជារស យ៉ាងឆ្ងាញ់ពិសា ចំណីអាហារ ឥតមានខ្វះអ្វី ។

២៤. ស្តេចក្រុងពាលី លោកមានរិទ្ធី លើរស់ទឹកដី នាងគង្ហីងធរណី
នេះជាសក្ខី សេពសោយចំណី យ៉ាងឆ្ងាញ់ពិសា ។

២៥. ទេវតាឥន្ទព្រហ្ម ទាំងតូចទាំងធំ សូមត្រៀបត្រា សុទ្ធតែមានបុណ្យ
រិទ្ធីចេស្តា ទទួលពលីការ សាទរពេកក្រៃ ។

២៦. អារក្សអ្នកតា មានរិទ្ធិចេស្តា មហាជោគជ័យ លោកតាបាំងបាត់
ប្រាកដនោះនៃ សេពសោយចំណី សប្បាយក្រៃលែង ។

២៧. ទាំងតូចទាំងធំ បានមកជួបជុំ សុខដុមជាក់ស្តែង សុទ្ធតែមានរិទ្ធិ
អំណាចធំធេង ប្រាកដជាក់ស្តែង ក្នុងកម្ពុជា ។

២៨. ថ្ងៃនេះមានសេរី មានជោគមានជ័យ មង្គលនានា
លោកបានសេពសោយ នូវភោជនាហារ ពលីបូជាច្រើនណាស់ឥតខ្វះ។

២៩. ទាំងបាយចំណី ជ្រូកក្បាលប្រាំបី មាន់គួរឆ្ងាញ់ណាស់ មានចេកមានក្រូច
ទឹកក្រូចផ្អែមណាស់ ល្មុតទុំល្អណាស់ ផ្អែមឆ្ងាញ់រសសាយ ។

៣០. បារីស្លាម្លូ រៀបសុទ្ធតែគូរ ជមផងទាំងឡាយ ជមទិសប្រាំបី
ជុំវិញមិនឆ្ងាយ បាយសីទាំងឡាយ ប៉ាកឆាមឥតឃ្លាត ។

៣១. មានទាំងខោអាវ កន្ត្រៃកាំបិតកោរ កញ្ចក់ឆ្លុះទៀត អុជទៀនអុជធូប
ភ្លឺច្បាស់ព្រោងព្រាត ជឿច្បាស់ឥតរវាត សូមសុខសាន្តគ្រាន់ ។

៣២. ពិធីបួងសួង លើកដៃសំបូង លោកទាំងប៉ុន្មាន លើកសង់តំណាក់
ថ្វាយអង្គក្សត្រក្សាន្ត សីហនុថ្កើនថ្កាន សម្ដេចឪយើង ។

៣៣. ជ័យហោង ជ័យ ថ្ងៃសៅរ៍ លើកតំណាក់ សម្ដេចឪ
ពេលាឧត្ដមមែនហោង មែន បានអ្វីធ្វើបន្ទាល់ មង្គលថ្កើងថ្កាន ។

៣៤. ថ្ងៃនេះថ្ងៃជា ពេលាជោគជ័យ បានសុខសួស្ដី មង្គមថ្កើងថ្កាន
ឈ្នះអស់សត្រូវ ទាំងអម្បាលម៉ាន បានសុខក្សេមក្សាន្ត ទាំងគ្រប់ទិសទី។

៣៥. ខ្ញុំសូមបួងសួង លើកដៃសំបូង ប្រណមអញ្ជលី ចំពោះលោកធំ
ស្ដេចក្រុងពាលី នាងគង្ហីងធរណី នោះជាសក្ខី ។

៣៦. ចំពោះគុណដ៏ធំ សូមថ្វាយបង្គំអង្គព្រះព្រហ្ម ព្រះឥន្ទ្រកោចក្រ
ទេវតា ទេវតាសួគ៌ា សោឡស្សគិឋាន ។

៣៧. លោកអារក្សអ្នកតា លោកថែរក្សា ទឹកដីប៉ុន្មាន គីរីបពិត

ដងព្រៃស្មសាន វាលរាបភូមិស្ថាន ទីស្រែចំការ ។

៣៨- សូមលោកឱយពរ ជោគជ័យបវរ ល្បីល្បះអស្ចារ្យ លើកសាងតំណាក់ បហាក្សត្រា រដ្ឋកម្ពុជា សីហនុរាជ ។

៣៩- បានសុខបានជ័យ មានជោគសួស្តី ថ្លាថ្លៃអង់អាច លើកសាងតំណាក់ ថ្វាយសីហនុរាជ ព្រះអង្គជារាជ បិតារាស់យើង ។

៤០- សូមកុំកើតមាន គ្រោះថ្នាក់ប៉ុន្មាន កុំកកើតឡើង ទោះបីតិចតួច ភ្លាត់ភ្លាំងដៃជើង កុំអោយកើតឡើង ជាធ្ងន់ពិការ ។

៤១- អស់លោកតូចធំ សូមប្រមូលផ្តុំ ដោះស្រាយបញ្ហា សូមរួមចំណែក ដេញយួនមោហា ចេញពីសីមា កម្ពុជាឧត្តម ។

៤២- លោកសុទ្ធតែមាន រិទ្ធិចំណាន ប្រានយួនខិតខំដេញគ្រប់មធ្យោបាយ អោយវាសោកយំ ត្រជាក់ក្តៅងំ កើតទុក្ខខ្លាចភ័យ ។

៤៣- បើវារឹងត្អឹង សូមលោកខំប្រឹង កុំត្រាប្រណី បង្កើតចលាចល ខ្វក់ខ្វល់ក្នុងផ្ទៃ បាញ់ចាក់កាប់វៃ តែឯងគ្នាវា ។

៤៤- ទ្រាំទៅពុំបាន អាយួនឈ្លានពាន ដីកម្ពុជា កើតក្តៅក្រហាយ ទាស់ទែងគ្នាវា ដករត់ម្ទឹម្ទា ត្រឡប់ទៅស្រុក ។

៤៥- សូមជួយការពារ ក្សត្រកម្ពុជា អោយបានក្តីសុខ ដោះស្រាយកម្ពុជា ដែលមានស្មាញស្មុក អាយួនអុកឡុក ឈ្លានពានទឹកដី ។

៤៦- អោយវាបាក់បប ភិតភ័យខ្លាចខ្លប តបះមានជ័យ អាយួនឈ្លានពាន កើតទុក្ខកើតភ័យ អោយវាបរាជ័យ កុំបីខកខាន ។

| ថ្ងៃខែសង Due Date | លេខបណ្ណអាន Card Number | បណ្ណារក្ស Librarian |
|---|---|---|
| 26 JAN 2010 | 8363 | [illegible] |
| 24 FEB 2011 | 9901 | [illegible] |
| 02 MAR 2011 | 10546 | [illegible] |
| 27 APR 2011 | 15217 | [illegible] |
| 18 JUL 2011 | 012691 | [illegible] |
| 20 AUG 2011 | 15896 | [illegible] |
| 08 DEC 2011 | 001159. | [illegible] |
| 14 JAN 2012 | 002996 | [illegible] |
| 06 MAR 2012 | 1562 | [illegible] |
| 13 MAR 2012 | 1548 | [illegible] |
| 20 DEC 2012 | 4485 | Shapi' [illegible] |
| 19 MAR 2013 | 4996 | [illegible] |
| 29 APR 2013 | 546 | [illegible] |
| 31 MAR 2014 | 005355 | [illegible] |
| 26 FEB 2016 | 969 | [illegible] |
| 04 JUN 2016 | | [illegible] |

Hun Sen Library
K011668

CATALOGED IN ALEPH
No : 29867
Date : 21-06-13

## បទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យហ៊ុន សែន

១- អាចខ្ចីសៀវភៅបានពីរក្បាលរយៈពេល១៤ថ្ងៃ ។

២- អាចពន្យារបានពីរ រឺបីដងប៉ុន្តែត្រូវមកបំពេញបែបបទថ្មីជាមួយ
បណ្ណារក្សផ្នែកខ្ចី ។ 11668

៣- ផាកពិន័យចំពោះសៀវភៅដែលសងលើសថ្ងៃកំនត់ ១ថ្ងៃ
៥០០រៀល ចំពោះសៀវភៅ១ក្បាល ។

៤- ក្រៅពីនិស្សិត បុគ្គលិកសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទ
ភ្នំពេញ បណ្ណាល័យតំរូវអោយកក់លុយ២០ដុល្លារអាមេរិកក្នុង
ករណីខ្ចីសៀវភៅចេញ ។

៥- សូមជួយថែរក្សាសៀវភៅអោយបានល្អ ។

មានលក់ដុំ និង រាយនៅ
តូបលេខ ៨៦ ផ្សារធំថ្មី
តូបលេខ ៧៨ ផ្សារអូរឬស្សី
Tel: 015 834 721